# المفتاح لفهم الإسلام

ដោយ អាប់ឌុលរ៉ស់ម៉ាន ពិន អាប់ឌុលការីមអាល់ស៊ែហ្យា

បកប្រែ និងត្រួតពិនិត្យដោយគណៈកម្មការបកប្រែ
សមាគមសប្បុរសធម៌ដើម្បីអភិវឌ្ឍន៍កម្ពុជា

សហការបោះពុម្ព និងចែកចាយដោយ
អង្គការវប្បធម៌ អារ្យធម៌កម្ពុជា_អារ៉ាប់

المؤلف/ د. عبدالرحمن بن عبد الكريم الشيحه
ترجمة ومراجعة / لجنة الترجمة
جمعية البركة الخيرية في كمبوديا

# មាតិកា

សេចក្ដីផ្ដើម..............................................................១
កំណត់សម្គាល់៖...........................................................១
តើឥស្លាមជាអ្វី?...........................................................៣
ពាក្យសច្ចាទាំងពីរ.........................................................៨
តើអ្នកនាំសារឥស្លាមជាអ្នកណា?.......................................៩
គេបាននិយាយអំពីអ្នកនាំសារមូហាំម៉ាត់ថា...............................១១
សឡាត (ការថ្វាយបង្គំ)...................................................១១
ហ្សាកាត់ (ការបរិច្ចាគទ្រព្យ)............................................១២
បួសខែរ៉ម៉ាហ្ទន (តមអាហាររយៈពេល១ខែក្នុង១ឆ្នាំ)................១៣
បុណ្យហាជ្ជ (ការធ្វើធម្មយាត្រា).........................................១៣
ការគោរពសក្ការៈផ្នែកជំនឿដែលគេហៅថាគោលជំនឿឥស្លាម......១៤
ភស្តុតាងបញ្ជាក់ថាមានអល់ឡោះជាម្ចាស់...............................១៥
គម្ពីរអាល់គួរអានជាអ្វី?...................................................៣៤
សាសន៍ដទៃនិយាយអំពីគម្ពីរអាល់គួរអាន...............................៣៥
គោលការណ៍គ្រឹះរបស់ឥស្លាម...............................................៣៩
ក្រមសីលធម៌ឥស្លាម..........................................................៤០
សាសន៍ដទៃនិយាយអំពីឥស្លាម.............................................៤៤
ឥស្លាម និងទ្រព្យសម្បត្តិ.....................................................៤៤
ឥស្លាម និងស្ត្រី...............................................................៤៦
ឥស្លាម និងផ្លូវភេទ...........................................................៤៩
ឥស្លាម និងអ្នកមិនមែនមូស្លីម..............................................៥១

ឥស្លាម និងការគោរពសិទ្ធិសាសនាដទៃ..................................៥២
ឥស្លាម និងសង្គ្រាម....................................................................៥៥
ឥស្លាម និងបរិស្ថាន....................................................................៦២
ឥស្លាម និងអនាម័យ...................................................................៦៤
ឥស្លាម និងចំណេះវិជ្ជា...............................................................៦៦
ឥទ្ធិពលអរិយធម៌ឥស្លាមចំពោះការអភិវឌ្ឍផ្នែកវិទ្យាសាស្ត្រទំនើប..៦៨
លក្ខណៈពិសេសនៃអរិយធម៌ឥស្លាម......................................៧១
ព្រះបន្ទូលខ្លះទាក់ទងនឹងវិទ្យាសាស្ត្រពិតក្នុងគម្ពីរអាល់គួរអាន.....៧២
តើអ្នកដឹងអ្វីខ្លះអំពីៈ...........................................................១១១
ចងកំហឹង និងភ័យខ្លាចពីឥស្លាម ហេតុអ្វី?............................១២៦
ហេតុអ្វីបានជាអ្នកចាំបាច់ត្រូវក្លាយជាមូស្លីម...........................១៣៣
សេចក្តីបញ្ចប់...........................................................................១៣៨

## សេចក្ដីផ្ដើម

ការនិយាយបរិយាយក្នុងកូនសៀវភៅមគ្គុទេសក៏ដ៏សង្ខេបអំពីសាសនាចុងក្រោយបង្អស់ ដែលគេបញ្ចុះមកពីលើមេឃ។ ជាមួយនឹងសាសនានេះ អល់ឡោះជាម្ចាស់បានបំពេញលក្ខណៈសាសនាមូសា និងអ៊ីសា (សូមសន្តិភាពកើតមានចំពោះពួកគាត់) ទ្រង់បានទុកសាសនាមុនៗជាមោឃៈ ហើយបានបញ្ចប់ការបញ្ចុះសារពីលើមេឃដោយសាសនានេះ។ បើយោងតាមស្ថិតិកម្រិតពិភពលោកចុងក្រោយបង្អស់ សាសនាឥស្លាមមានអ្នកចូលច្រើនជាងមួយពាន់លាននាក់។ សាសនានេះ មានមនុស្សប្រណាំងប្រជែងគ្នាចូលយ៉ាងច្រើនទោះបីជាមានភាពខ្វះខាតក្នុងការឧបត្ថម្ភផ្នែកសម្ភារៈ និងធនធានមនុស្សក៏ដោយ គឺមនុស្សភាគតិចណាស់អ្នកដែលចូលសាសនានេះហើយចាកចេញទៅវិញនោះ។

## កំណត់សម្គាល់

មុននឹងអានសៀវភៅនេះ ចាំបាច់អ្នកត្រូវដឹងថាគម្ពីរអាល់គួរអានមិនមែនជាគម្ពីរវិទ្យាសាស្ត្រ ប៉ុន្តែជាគម្ពីរដែលឱ្យតម្លៃទៅលើចំណេះដឹង និងអ្នកប្រាជ្ញ ហើយលើកឋានៈពួកអ្នកប្រាជ្ញឱ្យខ្ពង់ខ្ពស់ក្នុងសង្គមឥស្លាម និងបង្គាប់ឱ្យគេលើកតម្កើង និងផ្ដល់តម្លៃដល់ពួកអ្នកប្រាជ្ញ។

គម្ពីរអាល់គួរអានគឺជាក្បួនច្បាប់រៀបចំផែនទីផ្លូវសម្រាប់ជីវិតនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច សីលធម៌ និងការអប់រំដែលរៀបចំ

សណ្ដាប់ធ្នាប់របៀបរស់នៅរបស់អ្នកមូស្លីម ការទំនាក់ទំនងរបស់ពួកគេជាមួយនឹងសង្គមដទៃ ដើម្បីឱ្យពួកគេរស់នៅប្រកបដោយភាពសុខដុមរមនា ពួកគេស្គាល់ពីសិទ្ធិខ្លួនឯង និងសិទ្ធិអ្នកដទៃ។

ក្នុងសៀវភៅនេះ ខ្ញុំមិនភ្ជាប់គម្ពីរអាល់គួរអានទៅនឹងរបកគំហើញ និងវិទ្យាសាស្ត្រទំនើប ឬក៏ផ្ទុយមកវិញ។ ប៉ុន្តែខ្ញុំនិយាយពីអ្វីដែលមានចែងក្នុងគម្ពីរអាល់គួរអាននៃកថាខណ្ឌមួយចំនួន ដែលនិយាយអំពីអ្វីដែលគេបានរកឃើញថ្មីៗនាពេលបច្ចុប្បន្ន។ ពិតប្រាកដគម្ពីរអាល់គួរអានមានកថាខណ្ឌខ្លះ ដែលនិយាយពីអ្វីដែលនៅក្នុងលោកនេះដូចជា ព្រះអាទិត្យ ព្រះច័ន្ទ ផ្កាយ ថ្ងៃ យប់ មេឃ ដី សត្វ រុក្ខជាតិ បរិយាកាស។ល។ អំពាវនាវឱ្យមនុស្សគិតពិចារណាដែលនាំទៅរកការស្គាល់ម្ចាស់ដែលបង្កើត វិសាលភាពនៃកម្លាំងអំណាចរបស់ទ្រង់ និងភាពសុក្រិតឥតខ្ចោះនៃចំណេះដឹង និងពុទ្ធិរបស់ទ្រង់។

សង្ឃឹមថាសៀវភៅនេះនាំឱ្យអ្នកអានស្គាល់ពីគម្ពីរអាល់គួរអានដែលសុក្រិតឥតខ្ចោះ គ្មានភាពខ្វះចន្លោះត្រង់ណាឡើយ។ ជាការបញ្ចុះមកអំពីព្រះជាម្ចាស់ដ៏មហាខ្លាំងពូកែ។ គម្ពីរអាល់គួរអានផ្ទុកពោរពេញដោយក្បួនតម្រាចង្អុលបង្ហាញឱ្យស្គាល់ពីចំណេះដឹងពិតដែលគេមិនដឹង ឬអ្វីដែលគេមិនទាន់រកឃើញអំពីសាសនាឥស្លាម ។

## តើឥស្លាមជាអ្វី?

ឥស្លាមគឺជាការប្រគល់ខ្លួនជូនអល់ឡោះជាម្ចាស់ គោរពប្រតិបត្តិចំពោះទ្រង់ដោយសេចក្តីស្មោះស និងជៀសវាងការគោរពផ្សេងក្រៅពីទ្រង់។ ជាសាសនាដែលមានសេចក្តីសន្តោសប្រណី និងងាយស្រួល ។ ដូចអល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា:

﴿ يُرِيدُ ٱللَّهُ بِكُمُ ٱلْيُسْرَ وَلَا يُرِيدُ بِكُمُ ٱلْعُسْرَ ﴾ البقرة: ١٨٥

មានន័យថា: «អល់ឡោះទ្រង់ចង់ឱ្យពួកអ្នកទទួលបាននូវភាពងាយស្រួល ហើយទ្រង់មិនចង់ឱ្យពួកអ្នកពិបាកនោះឡើយ»។

- សាសនាដែលធ្វើឱ្យមនុស្សស្កប់ស្កល់ និងស្ងប់ចិត្ត ដូចជាអល់ឡោះ**បាន**មាន**ព្រះ**បន្ទូលថា៖

﴿ ٱلَّذِينَ ءَامَنُوا۟ وَتَطْمَئِنُّ قُلُوبُهُم بِذِكْرِ ٱللَّهِ ۗ أَلَا بِذِكْرِ ٱللَّهِ تَطْمَئِنُّ ٱلْقُلُوبُ ﴿٢٨﴾ ﴾ الرعد : ٢٨

មានន័យថា៖ «ពួកអ្នកដែលមានជំនឿ ហើយចិត្តរបស់ពួកគេនឹងនរ ដោយសារតែការរំឭកទៅចំពោះអល់ឡោះជាម្ចាស់។ តើមិនមែនទេឬការរំឭកចំពោះអល់ឡោះធ្វើឱ្យចិត្តនឹងនរ?» ។

- សាសនាដែលនាំឱ្យមានក្តីមេត្តាករុណា ដូចជាអ្នកនាំសារបានមានប្រសាសន៍ថា៖

عَنْ عبد الله بن عمرو قال قال رسول الله صلى الله عليه وسلم: ( الرَّاحِمُونَ يَرْحَمُهُمْ الرَّحْمَنُ ارْحَمُوا أَهْلَ الْأَرْضِ يَرْحَمْكُمْ أَهْلُ السَّمَاءِ ) حسن صحيح سنن الترمذي.

មានន័យថា៖ «ពួកអ្នកដែលចេះអាណិតស្រឡាញ់ចំពោះមនុស្ស អល់ឡោះនឹងអាណិតស្រឡាញ់ពួកគេ ចូរអាណិតស្រឡាញ់ចុះចំពោះអ្នកនៅលើដី នោះអ្នកនៅលើមេឃនឹងអាណិតស្រឡាញ់ពួកអ្នក» ។

❖ ជាសាសនានៃសេចក្ដីស្រឡាញ់ និងមេត្តាករុណា ហើយស្រលាញ់សេចក្ដីល្អសម្រាប់មនុស្សទូទៅ អ្នកនាំសារលោកបានមានប្រសាសន៍ថា៖

عن ابن عمر رضي الله عنهما قال قال رسول الله صلى الله عليه وسلم: ( أَحَبُّ النَّاسِ إِلَى اللهِ تعالى أَنْفَعُهُمْ لِلنَّاسِ) المعجم الكبير

មានន័យថា៖ «អល់ឡោះស្រឡាញ់ចំពោះមនុស្សណា ដែលផ្ដល់ផលប្រយោជន៍ច្រើនជាងគេចំពោះមនុស្សទូទៅ» ។

❖ សាសនាដែលគ្មានភាពស្រពេចស្រពិល និងគ្មានភាពប្រប្ញូកប្របល់ ដូចអល់ឡោះជាម្ចាស់**ទ្រង់បានមានព្រះ**បន្ទូលថា៖

﴿ وَمَآ أَرۡسَلۡنَا مِن قَبۡلِكَ إِلَّا رِجَالٗا نُّوحِيٓ إِلَيۡهِمۡۚ فَسۡـَٔلُوٓاْ أَهۡلَ ٱلذِّكۡرِ إِن كُنتُمۡ لَا تَعۡلَمُونَ ٤٣ ﴾ النحل : ٤٣

មានន័យថា៖ «យើងមិនបាបបញ្ជូននរណាម្នាក់មុនអ្នកឯង (មូហាំម៉ាត់) លើកលែងតែជាបុរសដែលយើងត្រាស់បង្គាប់ចំពោះពួកគេ ។ ចូរសួរពួកអ្នកដែលចេះដឹងចុះ ប្រសិនបើពួកអ្នកទាំងអស់គ្នាមិនដឹងនោះ» ។

❖ សាសនាដែលមានសមធម៌ពេញលេញសម្រាប់មនុស្សទាំងអស់ ហើយភាពល្អប្រសើរជាងគ្នានោះគឺស្ថិតនៅលើការគោរពវិន័យសាសនាតែប៉ុណ្ណោះ។ អ្នកនាំសារបានមានប្រសាសន៍ថា៖

عن سهل بن سعد قال قال رسول الله ( اَلنَّاسُ سَوَاسِيَّةٌ كَأَسْنَانِ الْمُشْطِ ) اسناده ضعيف

មានន័យថា៖ «មនុស្សទាំងអស់មានភាពស្មើគ្នាដូចជាធ្មេញក្រាសសិតសក់» ។

អ្នកនាំសារលោកបានមានប្រសាសន៍ទៀតថា៖

قال رسول الله صلى الله عليه وسلم: ( لاَ فَضْلَ لِعَرَبِيٍّ عَلَى أَعْجَمِيٍّ... إِلاَّ بِالتَّقْوَى ) مسند أحمد بن حنبل

មានន័យថា៖ «ជនជាតិអារ៉ាប់មិនល្អប្រសើរជាងជនជាតិដទៃលើកលែងតែមានការគោរពវិន័យសាសនា» ។

❖ សាសនាដែលមានភាពយុត្តិធម៌ដាច់ខាតសូម្បីចំពោះសត្រូវក៏ដោយ។ អល់ឡោះបានមានព្រះបន្ទូលថា៖

﴿ وَلَا يَجۡرِمَنَّكُمۡ شَنَـَٔانُ قَوۡمٍ عَلَىٰٓ أَلَّا تَعۡدِلُواْۚ ٱعۡدِلُواْ هُوَ أَقۡرَبُ لِلتَّقۡوَىٰ ﴾ المائدة : ٨

មានន័យថា៖ «ចូរកុំព្រោះតែការស្អប់ខ្ពើមរបស់ក្រុមមួយ ធ្វើឱ្យពួកអ្នកប្រព្រឹត្តអំពើអយុត្តិធម៌ឱ្យសោះ។ ចូរពួកអ្នកប្រកាន់ខ្ជាប់នូវភាពយុត្តិធម៌ ព្រោះភាពយុត្តិធម៌នៅកៀកបំផុតជាមួយនឹងការកោតខ្លាចចំពោះអល់ឡោះ» ។

- សាសនាដែលមានសេរីភាពទូលំទូលាយ សេរីភាពខាងជំនឿ។ ដូចអល់ឡោះបានមានព្រះបន្ទូលថា៖

﴿ لَآ إِكۡرَاهَ فِي ٱلدِّينِۖ ﴾ البقرة : ٢٥٦

មានន័យថា៖ «គ្មានការបង្ខិតបង្ខំទេក្នុងសាសនា» ។

សេរីភាពក្នុងការបញ្ចេញគំនិតស្ថាបនា ដើម្បីឈានទៅរកសេចក្តីចំរុងចំរើន និងការស្គាល់អល់ឡោះជាម្ចាស់។ អល់ឡោះបានមានព្រះបន្ទូលៈ

﴿ قُلِ ٱنظُرُواْ مَاذَا فِي ٱلسَّمَٰوَٰتِ وَٱلۡأَرۡضِۚ ﴾ يونس : ١٠١

មានន័យថា៖ «មូហាំម៉ាត់ចូរពោលថា ចូរពួកអ្នកពិចារណាមើលចុះថា តើមានអ្វីខ្លះនៅលើមេឃ និងផែនដី» ។

សេរីភាពខាងការនិយាយស្តី។ អ្នកនាំសារបាន**មាន**ប្រសាសន៍ថា៖

عن أبي سعيد الخدري رضي الله عنه قال قال رسول الله صلى الله عليه وسلم: ( أَفْضَلُ الْجِهَادِ كَلِمَةُ عَدْلٍ عِنْدَ سُلْطَانٍ جَائِرٍ أَوْ أَمِيْرٍ جَائِرٍ ) سنن أبي داود

មានន័យថា៖ «ការតស៊ូដ៏ល្អប្រសើរនោះគឺការនិយាយពាក្យពិតនៅចំពោះមុខមេដឹកនាំផ្តាច់ការ» ។

- សាសនាដែលមានការឯកភាព និងរួបរួមសាមគ្គីគ្នា អល់ឡោះបានមានព្រះបន្ទូលថា៖

﴿ وَٱعۡتَصِمُواْ بِحَبۡلِ ٱللَّهِ جَمِيعٗا وَلَا تَفَرَّقُواْۚ ﴾ آل عمران : ١٠٣

មានន័យថា៖«ចូរពួកអ្នកប្រកាន់ខ្ជាប់នឹងមាគ៌ារបស់អល់ឡោះ (សាសនាឥស្លាម)ទាំងអស់គ្នា ហើយកុំបែកបាក់គ្នាឱ្យសោះ» ។

❖ សាសនាដែលជួយសហការគ្នាលើអំពើល្អ។ អល់ឡោះបានមានព្រះបន្ទូលថា៖

﴿وَتَعَاوَنُوا۟ عَلَى ٱلْبِرِّ وَٱلتَّقْوَىٰ ۖ وَلَا تَعَاوَنُوا۟ عَلَى ٱلْإِثْمِ وَٱلْعُدْوَٰنِ﴾ سورة المائدة : ٢

មានន័យថា៖ «ចូរពួកអ្នកជួយសហការគ្នាក្នុងការធ្វើអំពើល្អ និងសេចក្តីកោតខ្លាចចំពោះអល់ឡោះ ហើយចូរពួកអ្នកកុំជួយសហការគ្នាក្នុងការធ្វើអំពើបាប និងចងសត្រូវនឹងគ្នាឱ្យសោះ» ។

❖ ជាសាសនាសកល អំពាវនាវដល់ពិភពលោកទាំងមូលដោយគ្មានការប្រកាន់ពូជសាសន៍។ អល់ឡោះបាន**មានព្រះ**បន្ទូលថា៖

﴿وَمَآ أَرْسَلْنَٰكَ إِلَّا كَآفَّةً لِّلنَّاسِ بَشِيرًا وَنَذِيرًا وَلَٰكِنَّ أَكْثَرَ ٱلنَّاسِ لَا يَعْلَمُونَ ﴿٢٨﴾﴾ سبأ : ٢٨

មានន័យថា៖ «យើងគ្មានចាត់តាំងអ្នក លើកលែងតែទៅកាន់មនុស្សលោកទូទៅ ដើម្បីផ្តល់ដំណឹងរីករាយ និងការព្រមានដាស់តឿនដល់ពួកគេ ក៏ប៉ុន្តែមនុស្សលោកភាគច្រើនមិនបានដឹង» ។

❖ សាសនាដែលបុគ្គលណាបានចូល អល់ឡោះនឹងអភ័យទោសនូវកំហុសឆ្គង និងអំពើបាបរបស់គេដែលកន្លងផុត។ អ្នកនាំសារបានមានប្រសាសន៍ថា៖

عن عمرو بن العاص رضي الله عنه قال أن رسول الله صلى الله عليه وسلم قال: (...أَنَّ الْإِسْلَامَ يَهْدِمُ مَا كَانَ قَبْلَهُ ) صحيح مسلم

មានន័យថា៖ «...ឥស្លាមជាសាសនាដែលអត់ឱននូវអ្វីដែលកន្លងផុត» ។

❖ ជាសាសនាពេញលេញបរិបូរ។ ជាមួយនឹងសាសនានេះ អល់ឡោះបានបំពេញលក្ខណៈដល់សាសនាសម័យមុនៗ ហើយបញ្ចប់សាសនាផ្សេងៗដោយសាសនាឥស្លាមនេះដែរ។ អល់ឡោះបានមានព្រះបន្ទូលថា៖

﴿ ٱلۡيَوۡمَ أَكۡمَلۡتُ لَكُمۡ دِينَكُمۡ وَأَتۡمَمۡتُ عَلَيۡكُمۡ نِعۡمَتِي وَرَضِيتُ لَكُمُ ٱلۡإِسۡلَٰمَ دِينٗاۚ ﴾ المائدة : ٣

មានន័យថា៖ «ថ្ងៃនេះយើងបានបំពេញសាសនារបស់ពួកអ្នក និងបានបង្គ្រប់ពរជ័យរបស់យើងជូនពួកអ្នក ហើយយើងបានជ្រើសរើសសាសនាឥស្លាមជាសាសនារបស់ពួកអ្នក» ។

ខាងក្រោមនេះជាប្រភេទនៃការគោរពសក្ការៈដែលមាន (កាយ វាចា ចិត្ត) តួនាទីយ៉ាងសំខាន់ក្នុងការកសាងសីលធម៌ប្រពៃថ្លៃថ្លា ជម្រះសំអាតចិត្តគំនិត និងការប្រកាន់ខ្ជាប់ម៉ឺងម៉ាត់ ការកែប្រែតម្រង់ខ្លួនឱ្យក្លាយជាបុគ្គលល្អ ហើយការរក្សាការពារឯកភាព និងចំណងមេត្រីភាពនៃសង្គមឥស្លាម។

ការគោរពសក្ការៈដោយកាយវាចា ដែលហៅថាឥស្លាមនោះមាន៖

## ពាក្យសច្ចាទាំងពីរ

ទី១សច្ចាទទួលស្គាល់ថា គ្មានម្ចាស់ដែលត្រូវគេគោរពសក្ការៈយ៉ាងពិតប្រាកដ លើកលែងតែអល់ឡោះ ហើយសច្ចាថា ពិតប្រាកដ

ណាស់មូហាំម៉ាត់ជាខ្ញុំបំរើ និងជាអ្នកនាំសាររបស់អល់ឡោះ។ ពាក្យនេះជាកូនសោសម្រាប់ចូលសាសនាឥស្លាម។

អត្ថន័យនៃពាក្យ៖ «គ្មានព្រះដែលត្រូវគេគោរពសក្ការៈយ៉ាងពិតប្រាកដ លើកលែងតែអល់ឡោះ» ។

- គ្មានម្ចាស់ដែលជាអ្នកបង្កើតចក្រវាលទាំងមូល លើកលែងតែអល់ឡោះ
- គ្មានអ្នកកាន់កាប់ និងចាត់ចែងរៀបចំចក្រវាឡ លើកលែងតែអល់ឡោះ។
- អល់ឡោះតែមួយគត់ជាម្ចាស់ដែលសក្តិសមគេគោរពសក្ការៈ។ អត្ថន័យនៃពាក្យសច្ចាថា« ពិតប្រាកដមូហាំម៉ាត់ជាអ្នកនាំសាររបស់អល់ឡោ »ប្រតិបត្តិតាមអ្វីដែលលោកបានបង្គាប់ប្រើជឿជាក់ចំពោះអ្វីដែលលោកបានប្រាប់ ជៀសវាងពីអ្វីដែលលោកបានហាមឃាត់ និងស្អប់ខ្ពើម។

**តើអ្នកនាំសារឥស្លាម ជាអ្នកណា?**

គាត់គឺជាឪពុករបស់ កសឹម ឈ្មោះម៉ូហាំម៉ាត់ ចៅរបស់អាប់ឌុលឡោះ ចៅទួតរបស់អាប់ឌុលម៉ូតោលិប កូន ហាសឹម មកពីកុលសម្ព័ន អារ៉ាប់គូរេស្ស ជាប់ត្រកូល អាត់ណាន ជាកូនរបស់ អ៊ីស្មាអែល ជាអ្នកនាំសាររបស់អល់ឡោះ ជាកូនរបស់អ៊ីព្រហីម ដែលជាសំណព្វចិត្តរបស់អល់ឡោះ។ ម្តាយរបស់គាត់ឈ្មោះ អាមីណះ កូនវ៉ាហាប់ ជាប់ត្រកូលអាត់ណាន ជាកូនរបស់ អ៊ីស្មាអែល អ្នកនាំសាររបស់អល់ឡោះ ជាកូនរបស់អ៊ីព្រហីម ។ គាត់បានប្រសូតនៅឆ្នាំ ៥៧១ គ.ស នៅទីក្រុងម៉ាកះ ដែលជាមជ្ឈមណ្ឌលសាសនាសំរាប់

ឧបទ្វីបអារ៉ាប់។ មានកៈហ្ពះ ដែលកសាងឡើងដោយ អ្នកនាំសារឈ្មោះអ៊ីព្រហីម និងកូនរបស់គាត់ឈ្មោះអ៊ីស្មាអែល។

គេបានទទួលស្គាល់ថា គាត់ជាមនុស្សដែលមានភាពស្មោះត្រង់ ហើយគេមានជំនឿទុកចិត្តលើរូបគាត់ នៅពេលដែលពួកគេចង់ធ្វើដំណើរ ពួកគេបានយកបញ្ញើរបស់ពួកគេមកផ្ញើនឹងគាត់ ហើយគេបានទទួលស្គាល់ថា គាត់ជាមនុស្សដែលប្រកាន់នូវភាពសច្ចៈ មិនចេះកុហក គេមិនដែលឮថា គាត់ក្បត់នឹងពាក្យសន្យា បោកប្រាស់ ពោលគឺគាត់ស្រលាញ់សេចក្តីល្អ និងភាពចំរុងចំរើនដល់មនុស្សលោកទូទៅ ។

អល់ឡោះបានប្រទានសារដល់គាត់ខណៈដែលគាត់មានអាយុ ៤០ឆ្នាំ គាត់បានប្រាប់ប្រពន្ធឈ្មោះ ខទីជះថា (ពិតប្រាកដណាស់ ខ្ញុំមានការបារម្ភចំពោះខ្លួនខ្ញុំ ប្រពន្ធគាត់បានឆ្លើយថា៖ ពុំដូច្នោះទេ! អល់ឡោះមិនធ្វើឱ្យអ្នកអាម៉ាស់មុខជាដាច់ខាត តាមពិតអ្នកបានផ្សារភ្ជាប់សាច់ញាតិ ជួយគាំទ្រពួកអ្នកទន់ខ្សោយ ឧបត្ថម្ភដល់អ្នកទីទ័លក្រ ទទួលឱ្យភ្ញៀវអាស្រ័យនៅ និងជួយជនរងគ្រោះ ។

គាត់បានស្នាក់នៅទីក្រុង ម៉ាកៈ អស់រយៈកាល ១៣ឆ្នាំ អំពាវនាវមនុស្សឱ្យជឿចំពោះអល់ឡោះ បន្ទាប់មក គាត់បានភៀសខ្លួន ទៅម៉ាទីណះ ហើយបានអំពាវនាវអ្នកស្រុកនោះឱ្យកាន់សាសនាឥស្លាម។ ពួកគេក៏បានចូលឥស្លាម ហើយអល់ឡោះនៅតែបញ្ចុះច្បាប់សាសនាដែលនៅសេសសល់ផ្សេងៗទៀតដល់គាត់ជាបន្តបន្ទាប់។ គាត់បានរំដោះក្រុងម៉ាកៈ បន្ទាប់ពីគាត់បានភៀសខ្លួនបាន៨ឆ្នាំ។ គាត់បានទទួលមរណភាពនៅអាយុ៦៣ឆ្នាំ ក្រោយពីគេបានបញ្ចុះគម្ពីរ

អាល់គួរអានទាំងមូល និងច្បាប់ឥស្លាមបានចប់សព្វគ្រប់ ហើយពួកអារ៉ាប់ទាំងមូលក៏បានចូលសាសនាឥស្លាមផងដែរ។

## គេបាននិយាយអំពីអ្នកនាំសារម៉ូហាំម៉ាត់ថា

លោកបណ្ឌិត ចច លីបូន បាននិយាយនៅក្នុងសៀវភៅអរិយធម៌អារ៉ាប់របស់លោកថា៖ ពេលណាគេចង់ប្រៀបធៀបគុណសម្បត្តិពួកវីរជន តាមរយៈស្នាដៃដ៏អស្ចារ្យរបស់ពួកគេ គឺម៉ូហាំម៉ាត់ជាបុគ្គលអស្ចារ្យដែលប្រវត្តិសាស្ត្របានទទួលស្គាល់។ ជាកាពិតណាស់ អ្នកប្រាជ្ញលោកខាងលិច បានផ្តល់យុត្តិធម៌ជូនម៉ូហាំម៉ាត់ ថ្វីបើសាសនានិយមបានធ្វើឱ្យពួកប្រវត្តិវិទូជាច្រើនបាត់បង់ឧត្តមគតិ មិនទទួលស្គាល់ឧត្តមភាពរបស់គាត់..។

លោកបណ្ឌិត ម៉ៃឃើល ហាត បាននិយាយនៅក្នុងសៀវភៅ "ការស្វែងយល់អំពីវីរជនកំពូលទាំង ១០០" ថា៖ ខ្ញុំបានជ្រើសយកម៉ូហាំម៉ាត់ មកដាក់លេខរៀងទីមួយនៃបញ្ជីឈ្មោះដែលមានបុគ្គលជាច្រើន សុទ្ធតែមានឥទ្ធពលជាសកល ក្នុងវិស័យជាច្រើន ប្រហែលជាមានអ្នកអានជាច្រើន មានការងឿងឆ្ងល់ ..ក៏ប៉ុន្តែតាមទស្សនៈរបស់ខ្ញុំ ម៉ូហាំម៉ាត់ គឺជាវីរជនតែមួយគត់ក្នុងប្រវត្តិសាស្ត្រ ដែលទទួលជោគជ័យ លេចធ្លោនិងឧត្តុង្គឧត្តមជាងគេ ទាំងផ្នែកសាសនាចក្រ និងអាណាចក្រ ។

## សឡាត (ការថ្វាយបង្គំ)

ការផ្សារភ្ជាប់រវាងខ្ញុំបំរើ និងម្ចាស់របស់ខ្លួន គេបួងសួងសុំអភ័យទោស សុំជំនួយ និងភាពសុក្រឹតត្រឹមត្រូវ។ គឺជាសឡាតទាំង

ប្រាំពេលក្នុងមួយថ្ងៃ មួយយប់ តាមពេលវេលាកំណត់។ អ្នកមូស្លីមនៅតែផ្សារភ្ជាប់នឹងម្ចាស់របស់ខ្លួន រៀងរាល់ពេល ។ ចំណែកឯពួកប្រុសៗត្រូវប្រតិបត្តិសឡាតជាក្រុមនៅឯម៉ាស្ជិត លើកលែងអ្នកដែលគ្មានលទ្ធភាព។ក៏ដូចេ្នះដែរ សឡាត ជួយពង្រឹងចំណងនៃសេចក្តីស្រលាញ់ភាពជិតស្និទ្ធ ហើយជួយលុបបំបាត់ទាំងស្រុងនូវការបែងចែកវណ្ណៈក្នុងសង្គម។ ព្រោះអ្នកឥស្លាមឈរជាជួរ ជាប់ៗគ្នា ហើយសំដៅទៅរកទិសតែមួយ ក្នុងពេលតែមួយ ពោលគឺ ពួកគេទាំងអស់ស្មើភាពគ្នាក្នុងការគោរពឱនលំទោន និងឈរសក្ការៈចំពោះអល់ឡោះជាម្ចាស់។

**ហ្សាកាត់ (ការបរិច្ចាគទ្រព្យ)**

ជាទ្រព្យសម្បត្តិមួយភាគតូច ដែលអ្នកមានត្រូវបង់តាមលក្ខខណ្ឌកំណត់ ដោយចិត្តជ្រះថ្លា ជាការអនុវត្តតាមបទបញ្ជារបស់អល់ឡោះសម្រាប់ចែកជូនដល់បងប្អូនរបស់ខ្លួនដែលក្រីក្រ និងពួកអ្នកខ្វះខាត។ ឥស្លាមបានដាក់កាតព្វកិច្ចនេះក្នុងគោលបំណងដើម្បីបណ្តុះស្មារតីចេះទទួលរ៉ាប់រងក្នុងសង្គម រវាងអ្នកឥស្លាម និងអ្នកឥស្លាម លុបបំបាត់ភាពក្រីក្រ និងទប់ស្កាត់ហានិភ័យទាំងឡាយដែលកើតចេញពីភាពក្រីក្រ។ មិនត្រឹមតែប៉ុណ្ណោះ ហ្សាកាត់ជួយជម្រះសម្អាតចិត្តពួកអ្នកមានពីភាពរិះកំណាញ់ លោភលន់ និងជម្រះសម្អាតចិត្តអ្នកក្រពីការច្រណែនឈ្នានីស ការចងគំនុំគុំកួននឹងអ្នកមាន។ នៅពេលដែលពួកគេឃើញអ្នកមានយកចិត្តទុកដាក់ចំពោះពួកគេក្នុងការផ្តល់ជាលុយកាក់ និងការផ្តល់ជាសប្បុរសធម៌ដល់ពួកគេ ..។

**បួសខែរ៉ម៉ាហ្ទន (ការតមអាហារមួយខែក្នុងមួយឆ្នាំ)**

អ្នកឥស្លាម បួសមួយឆ្នាំម្តង ដោយតមប្រការដែលនាំឲ្យខូចបួស ដូចជាការហូបចុក ផឹកទឹក រួមសង្វាស ដែលគិតចាប់ពីពេលអារុណរះរហូតដល់ថ្ងៃលិច។ បួសពុំមែនជាប្រការដែលទើបនឹងកើតមានឡើងក្នុងសាសនាឥស្លាមនោះទេ។ តាមពិត អល់ឡោះបានដាក់កាតព្វកិច្ចនេះដល់ពួកប្រជាជាតិជំនាន់មុនផងដែរ។ ដូចទ្រង់បានមានព្រះបន្ទូលថា៖

﴿ يَٰٓأَيُّهَا ٱلَّذِينَ ءَامَنُواْ كُتِبَ عَلَيۡكُمُ ٱلصِّيَامُ كَمَا كُتِبَ عَلَى ٱلَّذِينَ مِن قَبۡلِكُمۡ لَعَلَّكُمۡ تَتَّقُونَ ١٨٣ ﴾ البقرة : ١٨٣

មានន័យថា៖ "ម្នាលពួកអ្នកដែលមានជំនឿទាំងឡាយ យើងបានដាក់កាតព្វកិច្ចឱ្យបួស ដូចដែលយើងបានដាក់កាតព្វកិច្ចលើពួកអ្នកជំនាន់មុនដែរសង្ឃឹមថាពួកអ្នកនឹងកោតខ្លាចមកចំពោះយើង» ។

បួសគឺជាការតស៊ូជំនះរវាងខ្លួនឯងនិងតណ្ហា ហើយនិងចំណង់អូសទាញ។ បួសធ្វើឱ្យអ្នកមូស្លីមមានអារម្មណ៍ដឹងពីភាពខ្វះខាតរបស់បងប្អូនដែលក្រីក្រ តោកយ៉ាក។ ដូច្នេះ ធ្វើឱ្យរូបគេមានចិត្តអាណិតអាសូរ ចេះចូលរួមរំលែកទុក្ខលំបាក និងជួយបំពេញតម្រូវការរបស់ពួកគេ។

**បុណ្យហ័ជ្ជ (ការធ្វើធម្មយាត្រា)**

ការធ្វើដំណើរទៅកាន់វិហារកៈហ្បះជាទឹកដីពិសិដ្ឋដើម្បីបំពេញពិធីបុណ្យមួយយ៉ាងពិសេស នៅទីកន្លែងមួយដ៏ពិសេស ក្នុងពេលវេលាមួយកំណត់ដោយប្រតិបត្តិតាមក្តីបង្គាប់របស់អល់ឡោះជាម្ចាស់។ ចាំ

បាច់លើមូស្លីមគ្រប់រូបមានបញ្ញា គ្រប់អាយុដឹងក្តី ត្រូវបំពេញពិធីនេះឱ្យបានម្តងក្នុងមួយជីវិត ដោយមានលក្ខខណ្ឌកំណត់ត្រូវមានលទ្ធភាពទាំងសុខភាពផ្លូវកាយ និងធនធានទ្រព្យសម្បត្តិ អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿وَلِلَّهِ عَلَى ٱلنَّاسِ حِجُّ ٱلۡبَيۡتِ مَنِ ٱسۡتَطَاعَ إِلَيۡهِ سَبِيلٗاۚ وَمَن كَفَرَ فَإِنَّ ٱللَّهَ غَنِيٌّ عَنِ ٱلۡعَٰلَمِينَ ٩٧﴾ آل عمران : ٩٧

មានន័យថា៖ «ពិតប្រាកដ អល់ឡោះជាម្ចាស់បានដាក់កាតព្វកិច្ចលើមនុស្សឱ្យប្រារព្វពិធីបុណ្យហាជ្ជ នៅវិហារកះហ្ពះចំពោះនរណាដែលមានលទ្ធភាព។ រីឯអ្នកដែលប្រឆាំងបដិសេធនោះ ពិតប្រាកដណាស់ អល់ឡោះទ្រង់មិនត្រូវការអ្វីពីពិភពលោកនោះឡើយ"។

គេចាត់ទុកបុណ្យហាជ្ជជាការប្រមូលផ្តុំពួកអ្នកមូស្លីមដ៏ធំបំផុតនៅកន្លែងតែមួយ ក្នុងពេលតែមួយ ពួកគេនាំគ្នាបួងសួងចំពោះព្រះជាម្ចាស់តែមួយ ពួកគេប្រើសំលៀកបំពាក់តែមួយ ប្រារព្វពិធីតែមួយ មិនមានការបែងចែករវាងអ្នកមាន និងអ្នកក្រ វណ្ណៈខ្ពស់ទាប ពណ៌សម្បុរអារ៉ាប់ និងជនជាតិដទៃឡើយ។ នេះជាសក្ខីភាពមួយបញ្ជាក់ពីភាតរភាព ភាពជាបងប្អូននឹងគ្នារវាងពួកអ្នកមូស្លីមទូទៅ។

**ការគោរពសក្ការៈផ្នែកជំនឿដែលគេបញ្ញត្តិហៅថា គោលជំនឿឥស្លាម៖**

១- ជឿចំពោះអល់ឡោះជាម្ចាស់៖ ត្រូវមានជំនឿថាមានព្រះជាម្ចាស់ ជាព្រះតែមួយគ្មានដៃគូទាំងភាពជាម្ចាស់ ទាំងភាពជាព្រះ ទាំង

ព្រះនាម និងព្រះលក្ខណៈរបស់ទ្រង់។ ទ្រង់គ្មានគូប្រៀប ហើយទ្រង់គ្មានខ្នងបង្អែក និងអ្នកជួយគាំទ្រ ទ្រង់ជាព្រះដែលបង្កើតសភាវសត្វលោក ទ្រង់ជាអ្នកចាត់ចែងតែមួយគត់ គ្មានអ្វីកើតឡើងលើកលែងតែទ្រង់សព្វព្រះទ័យ ហើយគ្មានកើតផលអ្វីលើកលែងតែទ្រង់មានព្រះចេតនា ទ្រង់តែមួយគត់សក្តិសមនឹងទទួលការគោរពសក្ការៈ គ្មានអ្នកផ្សេងឡើយ។ អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿قُلْ هُوَ ٱللَّهُ أَحَدٌ ۝١ ٱللَّهُ ٱلصَّمَدُ ۝٢ لَمْ يَلِدْ وَلَمْ يُولَدْ ۝٣ وَلَمْ يَكُن لَّهُۥ كُفُوًا أَحَدٌۢ ۝٤﴾ الإخلاص: ١-٤

មានន័យថា៖ «មូហាំម៉ាត់ចូរប្រសាសន៍ចុះថា៖ អល់ឡោះតែមួយគត់ទ្រង់ជាព្រះជាម្ចាស់ ហើយទ្រង់មានព្រះនាម និងព្រះលក្ខណៈដ៏ប្រសើរថ្លៃថ្លា គ្មាននរណាម្នាក់ចូលហ៊ុនចំណែកជាមួយទ្រង់ឡើយ។ អល់ឡោះតែមួយគត់ទ្រង់គង់ជាអមតៈ ដែលត្រូវគេផ្សងប្រាថ្នាសុំឱ្យបានសំរេចដូចបំណង។ ទ្រង់គ្មានកូន គ្មានឪពុក និងគ្មានប្រពន្ធ។ គ្មានសត្វលោកណាអាចប្រដូច ហើយប្រៀបនឹងទ្រង់ ទាំងព្រះនាម ព្រះលក្ខណៈ ទាំងសកម្មភាព ទ្រង់មហាខ្ពង់ខ្ពស់ មហាពិសិដ្ឋ» ។

## ភស្តុតាងបញ្ជាក់ថាមានអល់ឡោះជាម្ចាស់

ពិតប្រាកដ គ្រប់អ្វីទាំងឡាយដែលមាននៅក្នុងចក្រវាលនៃសភាវសត្វលោកបញ្ជាក់យ៉ាងច្បាស់ដោយគ្មានម្ទិលសង្ស័យថា មានព្រះជាម្ចាស់ដែលជាអ្នកបង្កើត ទ្រង់គឺអល់ឡោះជាម្ចាស់។ ពួកអ្នកដែលមានបញ្ញាញាណ និងមាននិស្ស័យជ្រះថ្លាបានយល់ពីរឿងនេះ

យ៉ាងច្បាស់។ ពិតប្រាកដ ពួកអ្នកដែលបដិសេធចំពោះវត្តមានរបស់អល់ឡោះ ពួកគេចង់បានភស្តុតាងជារូបធាតុពិតដែលដឹងដោយឥន្ទ្រីយារម្មណ៍របស់ពួកគេ។ ពួកគេជំទាស់នឹងខ្លួនឯងក្នុងការទាមទារចង់បានជាតួរូបីនៃជំនឿ ដោយសារពួកគេមានជំនឿថា មានវត្តមានអ្វីគ្រប់យ៉ាងក្នុងចក្រវាលនេះឥន្ទ្រីយារម្មណ៍របស់ពួកគេក៏គិតមិនដល់ដែរ តែពួកគេអាចដឹងតាមរយៈការប្រទះឃើញលទ្ធផល និងឥទ្ធិពលនៃរបស់ដែលមាននៅក្នុងចក្រវាល។ ពួកគេដឹងតាមរយៈឥទ្ធិពលនៃវត្ថុទាំងនោះ តែមិនតាមរយៈធាតុពិតនៃវត្ថុទាំងនោះឡើយ។ ពួកគេជឿថាមានទំនាញផែនដី ហើយក្នុងខ្លួនដឹងច្បាស់មិនអាចមើលឃើញ តែពួកគេឃើញឥទ្ធិពលរបស់វាគឺអ្វីគ្រប់យ៉ាងត្រូវស្រូបទាញដោយទំនាញផែនដី។ ពួកគេជឿថាមានដែនម៉ាញេទិច ហើយក៏ដឹងច្បាស់ថាខ្លួនឯងមើលមិនឃើញដែនម៉ាញេទិចនេះ តែពួកគេឃើញពីឥទ្ធិពលរបស់វាដែលស្រូបចូលគ្នា។ ប៉ុន្តែពួកគេមើលមិនឃើញពីកម្លាំងទំនាញនេះឡើយ។ ពួកគេមានជំនឿថាមានប្រាជ្ញា ពួកគេមើលមិនឃើញប្រាជ្ញា តែពួកគេឃើញពីឥទ្ធិពលរបស់វា។ តើពួកអ្នកដែលគិតថាអ្វីៗវាឋិតនៅត្រឹមតែការដឹងដោយឥន្ទ្រីយារម្មណ៍នោះត្រឹមត្រូវដែរឬទេ? តើសមហេតុផលដែរឬទេនៅពេល ដែលពួកគេបដិសេធនឹងជំនឿចំពោះអល់ឡោះ។ ពីព្រោះពួកគេមិនអាចដឹងពីទ្រង់តាមរយៈឥន្ទ្រីយារម្មណ៍របស់ពួកគេ? គ្រាន់តែផ្អែកទៅលើឥទ្ធិពលតែមួយគត់ ពួកគេជឿលើភាពពិតជាច្រើន ដែលពួកគេមើលមិនឃើញ។ ពិតប្រាកដ ការទាមទារចង់ដឹងដោយឥន្ទ្រីយារម្មណ៍ ដើម្បីជឿថាមានអល់ឡោះជាម្ចាស់ បានធ្វើឱ្យមនុស្សភាគច្រើនឃ្លាតចាកពីផ្លូវត្រូវក្នុងការស្គាល់អល់ឡោះជាម្ចាស់

ដែលផ្លុះបញ្ចាំងក្នុងគំនិតនៃការគិតអំពីនិមិត្តសញ្ញារបស់ទ្រង់ និងសាភាវសត្វលោករបស់ទ្រង់។ ទ្រង់បានមានព្រះបន្ទូលថា៖

﴿وَقَالَ فِرۡعَوۡنُ يَٰهَٰمَٰنُ ٱبۡنِ لِي صَرۡحٗا لَّعَلِّيٓ أَبۡلُغُ ٱلۡأَسۡبَٰبَ ٣٦ أَسۡبَٰبَ ٱلسَّمَٰوَٰتِ فَأَطَّلِعَ إِلَىٰٓ إِلَٰهِ مُوسَىٰ وَإِنِّي لَأَظُنُّهُۥ كَٰذِبٗاۚ وَكَذَٰلِكَ زُيِّنَ لِفِرۡعَوۡنَ سُوٓءُ عَمَلِهِۦ وَصُدَّ عَنِ ٱلسَّبِيلِۚ وَمَا كَيۡدُ فِرۡعَوۡنَ إِلَّا فِي تَبَابٖ ٣٧﴾ غافر: ٣٦-٣٧

មានន័យថា៖ «ផារ៉ាអុងបាននិយាយថា នៃហាម៉ាន ចូរសង់អាគារខ្ពស់មួយឱ្យយើង សង្ឃឹមថាយើងអាចឡើងទៅលើមេឃបាន យើងចង់មើលព្រះជាម្ចាស់របស់មូសាដោយខ្លួនឯង យើងសង្ស័យថាវានិយាយកុហកយើង។ គេបានលួងទង្វើដ៏អាក្រក់របស់ផារ៉ាអុងថាជាទង្វើល្អ ហើយខ្លួនត្រូវរារាំងពីផ្លូវត្រូវ។ ល្បិចកលរបស់ផារ៉ាអុងគ្មានអ្វីក្រៅពីក្ដីអភ័ព្វទាំងនៅលោកិយ៍ និងបរលោក»។

ពុំមែនចំពោះតែយុគសម័យកាលណាមួយនោះឡើយ តែនេះគឺជាវប្បធម៌ទំនៀមទំលាប់របស់ពួកអ្នកប្រឆាំងជំទាស់បដិសេធតាំងពីដើមរៀងមកដោយសារភាពល្ងង់ខ្លៅរបស់ពួកគេ។ អល់ឡោះជាម្ចាស់បានមានព្រះបន្ទូលថា៖

﴿وَقَالَ ٱلَّذِينَ لَا يَعۡلَمُونَ لَوۡلَا يُكَلِّمُنَا ٱللَّهُ أَوۡ تَأۡتِينَآ ءَايَةٞۗ كَذَٰلِكَ قَالَ ٱلَّذِينَ مِن قَبۡلِهِم مِّثۡلَ قَوۡلِهِمۡۘ تَشَٰبَهَتۡ قُلُوبُهُمۡۗ قَدۡ بَيَّنَّا ٱلۡأٓيَٰتِ لِقَوۡمٖ يُوقِنُونَ ١١٨﴾ البقرة: ١١٨

មានន័យថា៖ «ពួកអ្នកដែលល្ងង់ខ្លៅបាននិយាយថា បើសិនជាអល់ឡោះនិយាយផ្ទាល់ជាមួយពួកយើង ឬឯងនាំមកបង្ហាញយើងនូវនិមិត្តសញ្ញាណាមួយ។ ក៏ដូចគ្នាដែរ ពួកអ្នកជំនាន់មុនក៏និយាយអ៊ីចឹងដែរ ដួងចិត្តរបស់ពួកគេស្រដៀងៗគ្នា។ ពិតណាស់យើងបានបកស្រាយបញ្ជាក់អំពីនិមិត្តសញ្ញារបស់យើង យ៉ាងច្បាស់លាស់សម្រាប់ពួកអ្នកដែលមានជំនឿជឿជាក់»។

ឬពួកគេមិនជឿដោយសារមូលហេតុនៃភាពក្រអឺតក្រទមរបស់ពួកគេ អល់ឡោះទ្រង់បានមានព្រះបន្ទូលថា៖

﴿وَقَالَ ٱلَّذِينَ لَا يَرۡجُونَ لِقَآءَنَا لَوۡلَآ أُنزِلَ عَلَيۡنَا ٱلۡمَلَٰٓئِكَةُ أَوۡ نَرَىٰ رَبَّنَاۗ لَقَدِ ٱسۡتَكۡبَرُواْ فِيٓ أَنفُسِهِمۡ وَعَتَوۡ عُتُوّٗا كَبِيرٗا ٢١ يَوۡمَ يَرَوۡنَ ٱلۡمَلَٰٓئِكَةَ لَا بُشۡرَىٰ يَوۡمَئِذٖ لِّلۡمُجۡرِمِينَ وَيَقُولُونَ حِجۡرٗا مَّحۡجُورٗا ٢٢﴾ *الفرقان :* ٢١-٢٢

មានន័យថា៖ «ពួកអ្នកដែលគ្មានសង្ឃឹមនឹងជួបយើងបាននិយាយថា បើសិនជាគេបញ្ជូនពួកទេវតាមកជួបពួកយើង ឬក៏ពួកយើងឃើញព្រះជាម្ចាស់របស់យើង។ ពិតប្រាកដ ពួកគេមានចិត្តអំនួតចំពោះខ្លួន ហ៊ាននិយាយពាក្យក្រអឺតក្រទមបែបនេះ។ ថ្ងៃដែលពួកគេឃើញពួកទេវតា គ្មានអ្វីរីករាយនៅថ្ងៃនោះសម្រាប់ពួកអ្នកអគតិ ហើយពួកទេវតានិយាយថាឋានសួគ៌ជាកន្លែងដែលគេហាមចំពោះពួកអ្នក»។

ឬក៏ជាអំពើអគតិ ដូចជាការប្រព្រឹត្តិរបស់ពួកជិហ្វ។ អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿ وَإِذۡ قُلۡتُمۡ يَٰمُوسَىٰ لَن نُّؤۡمِنَ لَكَ حَتَّىٰ نَرَى ٱللَّهَ جَهۡرَةٗ فَأَخَذَتۡكُمُ ٱلصَّٰعِقَةُ وَأَنتُمۡ تَنظُرُونَ ٥٥ ﴾ البقرة : ٥٥

មានន័យថា៖ "ចូររំឭកចុះខណៈដែលពួកអ្នកនិយាយថា បពិត្រមូសា! ពួកយើងមិនព្រមជឿចំពោះឯងជាដាច់ខាត លុះត្រាណា ពួកយើងឃើញអល់ឡោះផ្ទាល់នឹងភ្នែក។ ស្រាប់តែមានភ្លើងធ្លាក់ពីលើ មេឃមក ហើយពួកអ្នកបានឃើញផ្ទាល់នឹងភ្នែក ភ្លើងនោះបានឆាប ឆេះប្រល័យពួកអ្នក ដោយសារតែអំពើបាប និងការប្រមាថរបស់ពួក អ្នកចំពោះអល់ឡោះជាម្ចាស់» ។

**ភស្តុតាងខ្លះៗបញ្ជាក់ថាមានអល់ឡោះ**

- រកហេតុផលតាមឧបនិស្ស័យដ៏បរិសុទ្ធ : ពិតប្រាកដ មនុស្ស ម្នាក់ៗមានឧបនិស្ស័យត្រឹមត្រូវ និងប្រាជ្ញាយល់ដឹងមានជំនឿ ជាក់យ៉ាងច្បាស់ថា គ្មានអ្វីមួយដែលគ្មានអ្នកបង្កើត ហើយក៏ គ្មានអ្វីមួយកើតឡើងដោយគ្មានមូលហេតុនោះដែរ។
- ព្រះបន្ទូលក្នុងគម្ពីរអាល់គួរអាន : ជំរុញឱ្យសង្កេតមើលពិភព លោកដែលនៅជុំវិញខ្លួនឯង ត្រិះរិះពិចារណាទៅលើសភាវសត្វ លោកទាំងឡាយដែលមាននៅក្នុងចក្រវាល ដែលបង្ហាញថាមាន ព្រះជាម្ចាស់ជាអ្នកបង្កើត ជាអ្នកចាត់ចែង ដោយគ្មានភាពមន្ទិល សង្ស័យជាដាច់ខាត។
- ចក្រវាលដែលពោរពេញដោយភាពសុក្រឹតឥតខ្ចោះ ការប្រឌិត ឡើងដ៏គួរឱ្យស្ញប់ស្ញែង មានតាំងពីភពផ្កាយទាំងឡាយដែល កំពុងមានចលនា។ ភពនីមួយៗដែលនៅលើមេឃ បើសិនជា

ឃ្លាតតែបន្តិចពីគន្លងរបស់ខ្លួននោះ នឹងកើតមានគ្រោះមហន្តរាយដ៏ប្រល័យនៅក្នុងចក្រវាល។ គ្មាននរណាដឹងពីទំហំនៃគ្រោះមហន្តរាយនោះ លើកលែងតែអល់ឡោះជាម្ចាស់តែមួយគត់។ តើនរណាជាអ្នកទទួលខុសត្រូវ និងបង្កើតភពទាំងនោះ តាំងពីការចាប់ផ្តើមកំណើតចក្រវាលរហូតមកដល់សព្វថ្ងៃ។ ភពទាំងឡាយធ្វើចលនាតាមក្រឹត្យក្រមកំណត់មួយយ៉ាងជាក់លាក់។ អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿ قُلِ ٱنظُرُواْ مَاذَا فِي ٱلسَّمَٰوَٰتِ وَٱلۡأَرۡضِۚ وَمَا تُغۡنِي ٱلۡأٓيَٰتُ وَٱلنُّذُرُ عَن قَوۡمٖ لَّا يُؤۡمِنُونَ ١٠١ ﴾ يونس : ١٠١

មានន័យថា៖ «មូហាំម៉ាត់ចូរប្រាប់ពួកគេចុះថា ចូរពួកអ្នកពិនិត្យសង្កេតទៅលើអ្វីៗដែលមាននៅលើមេឃ និងនៅលើផែនដី។ តែនិមិត្តសញ្ញាទាំងឡាយ ព្រមទាំងការដាស់តឿនឱ្យប្រុងប្រយ័ត្ន គ្មានប្រយោជន៍សម្រាប់ពួកអ្នកដែលគ្មានជំនឿ» ។

- ខ្លួនមនុស្សផ្ទាល់ ដែលមានលក្ខណៈពិសេសអស្ចារ្យទាំងរូបសម្បត្តិ និងទ្រព្យទ្រង់ទ្រាយ អល់ឡោះជាម្ចាស់បានប្រទានមកជាមួយនូវលទ្ធភាព និងសក្តានុពល។ ដូចអល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿ وَفِي ٱلۡأَرۡضِ ءَايَٰتٞ لِّلۡمُوقِنِينَ ٢٠ وَفِيٓ أَنفُسِكُمۡۚ أَفَلَا تُبۡصِرُونَ ٢١ ﴾
الذاريات : ٢٠-٢١

មានន័យថា៖ «ហើយនៅលើផែនដីជានិមិត្តសញ្ញាសម្រាប់ពួកអ្នកដែលមានជំនឿជឿជាក់ និងនៅក្នុងខ្លួនរបស់ពួកគេ តើពួកគេអត់បើកភ្នែកមើលទេមែនទេ?» ។

- ពពួកសត្វផ្សេងៗ ដែលមនុស្សទាញយកផលប្រយោជន៍ធ្វើជាចំណីអាហា គ្រឿងឧបភោគបរិភោគ សម្លៀកបំពាក់ និងទុកធ្វើជាយានជំនិះ។ ដូចអល់ឡោះជាម្ចាស់បានមានព្រះបន្ទូលថា៖

﴿وَإِنَّ لَكُمْ فِي ٱلْأَنْعَٰمِ لَعِبْرَةً نُّسْقِيكُم مِّمَّا فِي بُطُونِهِۦ مِنۢ بَيْنِ فَرْثٍ وَدَمٍ لَّبَنًا خَالِصًا سَآئِغًا لِّلشَّٰرِبِينَ ٦٦ وَمِن ثَمَرَٰتِ ٱلنَّخِيلِ وَٱلْأَعْنَٰبِ تَتَّخِذُونَ مِنْهُ سَكَرًا وَرِزْقًا حَسَنًا إِنَّ فِي ذَٰلِكَ لَءَايَةً لِّقَوْمٍ يَعْقِلُونَ ٦٧ وَأَوْحَىٰ رَبُّكَ إِلَى ٱلنَّحْلِ أَنِ ٱتَّخِذِي مِنَ ٱلْجِبَالِ بُيُوتًا وَمِنَ ٱلشَّجَرِ وَمِمَّا يَعْرِشُونَ ٦٨ ثُمَّ كُلِي مِن كُلِّ ٱلثَّمَرَٰتِ فَٱسْلُكِي سُبُلَ رَبِّكِ ذُلُلًا يَخْرُجُ مِنۢ بُطُونِهَا شَرَابٌ مُّخْتَلِفٌ أَلْوَٰنُهُۥ فِيهِ شِفَآءٌ لِّلنَّاسِ إِنَّ فِي ذَٰلِكَ لَءَايَةً لِّقَوْمٍ يَتَفَكَّرُونَ ٦٩﴾ *النحل : ٦٦-٦٩*

មានន័យថា៖ «ពិតប្រាកដ សត្វពាហនៈគឺជាតួយ៉ាងមួយសម្រាប់ពួកអ្នក យើងបានប្រទានទឹកដោះដល់ពួកអ្នក ចេញពីក្នុងពោះរបស់វាកើតចេញពីចន្លោះអាចម៍ និងឈាមរបស់វាជាទឹកដោះដ៏ថ្លាបរិសុទ្ធមានរសជាតិឆ្ងាញ់សម្រាប់ពួកអ្នកទទួលទាន។ អំពីក្តីប្រទានរបស់យើងគឺផ្លែល្មើ និងផ្លែទំពាំងបាយជូរ ពួកអ្នកយកវាទៅបិតធ្វើស្រា ហើយពួកអ្នកយកផ្លែឈើទាំងនោះធ្វើជាចំណីដ៏ឆ្ងាញ់ពិសា។ ពិតប្រាកដ ទាំងនេះជានិមិត្តសញ្ញាសម្រាប់ពួកអ្នកដែលមានប្រាជ្ញាចេះគិត។ ព្រះជាម្ចាស់របស់ឯងបានត្រាស់បង្គាប់ឱ្យសត្វឃ្មុំយកភ្នំ និងដើមឈើ

ធ្វើជាសំបុក ហើយនិងផ្ទះសម្បែង សំណង់អាគារដែលមនុស្សធ្វើ។ បន្ទាប់មកទ្រង់ប្រើឱ្យឃ្មុំខាំស៊ីផ្លែឈើទាំងឡាយ និងធ្វើត្រាប់តាមផ្លូវដែលទ្រង់បានត្រួសត្រាយឱ្យយ៉ាងងាយស្រួល។ ទឹកដមដែលចេញពីក្នុងពោះរបស់វាមានសម្បុរខុសៗគ្នាជាថ្នាំព្យាបាលសម្រាប់មនុស្ស។ ពិតណាស់ នេះជានិមិត្តសញ្ញាសម្រាប់ពួកអ្នកដែលចេះគិតពិចារណា»។

- រុក្ខជាតិ ដើមឈើ និងដំណាំដាំដុះទាំងឡាយមានប្រភេទ និងពណ៌សម្បុរខុសៗគ្នា ដែលមនុស្សទាញយកផលប្រយោជន៍ប្រើសម្រាប់ជាគ្រឿងឧបភោគបរិភោគជាទីជម្រក និងជាឱសថព្យាបាល។ ដូចអល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿وَهُوَ ٱلَّذِى مَدَّ ٱلْأَرْضَ وَجَعَلَ فِيهَا رَوَٰسِىَ وَأَنْهَٰرًا ۖ وَمِن كُلِّ ٱلثَّمَرَٰتِ جَعَلَ فِيهَا زَوْجَيْنِ ٱثْنَيْنِ ۖ يُغْشِى ٱلَّيْلَ ٱلنَّهَارَ ۚ إِنَّ فِى ذَٰلِكَ لَءَايَٰتٍ لِّقَوْمٍ يَتَفَكَّرُونَ ﴿٣﴾ وَفِى ٱلْأَرْضِ قِطَعٌ مُّتَجَٰوِرَٰتٌ وَجَنَّٰتٌ مِّنْ أَعْنَٰبٍ وَزَرْعٌ وَنَخِيلٌ صِنْوَانٌ وَغَيْرُ صِنْوَانٍ يُسْقَىٰ بِمَآءٍ وَٰحِدٍ وَنُفَضِّلُ بَعْضَهَا عَلَىٰ بَعْضٍ فِى ٱلْأُكُلِ ۚ إِنَّ فِى ذَٰلِكَ لَءَايَٰتٍ لِّقَوْمٍ يَعْقِلُونَ ﴿٤﴾﴾ الرعد: ٣-٤

មានន័យថា៖ «ទ្រង់គឺជាអ្នកដែលពន្លាតផែនដីឱ្យធំទូលាយ ទ្រង់បានបង្កើតឱ្យភ្នំ និងទន្លេ និងមានផ្លែឈើគ្រប់ប្រភេទ គ្រប់ផ្លែឈើនីមួយៗមានពីរប្រភេទ ហើយទ្រង់បង្កើតឱ្យមានយប់និងថ្ងៃគ្របដណ្តប់គ្នាទៅវិញទៅមក។ ពិតប្រាកដ នេះជានិមិត្តសញ្ញាសម្រាប់ពួកអ្នកដែលចេះគិតពិចារណា។ នៅលើផែនដីនេះទៀតមានប្រភេទដីផ្សេងគ្នាតែនៅជាប់ៗគ្នា មានចំការគ្រប់ប្រភេទ ចំការទំពាំងបាយជូរ

ចំការដំណាំផ្សេងៗ និងចំការល្មើដែលមានដើមដុះចេញពីគល់តែមួយ និងគល់ផ្សេងគ្នា គេស្រោចស្រពទឹកតែមួយ ហើយយើងបានធ្វើឱ្យផ្លែឈើទាំងនោះមានរសជាតិប្រសើរខុសគ្នាក្នុងការទទួលទាន។ ពិតប្រាកដ ជានិមិត្តសញ្ញាសម្រាប់ពួកអ្នកដែលមានប្រាជ្ញាចេះគិត» ។

- សភាវៈទាំងឡាយនៃសត្វលោកផ្សេងៗ ដែលរស់នៅលើផែនដីគ្រប់ប្រភេទ គ្រប់ជំពូក គ្រប់លក្ខណៈ។ អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿ خَلَقَ ٱلسَّمَٰوَٰتِ بِغَيۡرِ عَمَدٖ تَرَوۡنَهَاۖ وَأَلۡقَىٰ فِي ٱلۡأَرۡضِ رَوَٰسِيَ أَن تَمِيدَ بِكُمۡ وَبَثَّ فِيهَا مِن كُلِّ دَآبَّةٖۚ وَأَنزَلۡنَا مِنَ ٱلسَّمَآءِ مَآءٗ فَأَنۢبَتۡنَا فِيهَا مِن كُلِّ زَوۡجٖ كَرِيمٍ ۝١٠ هَٰذَا خَلۡقُ ٱللَّهِ فَأَرُونِي مَاذَا خَلَقَ ٱلَّذِينَ مِن دُونِهِۦۚ بَلِ ٱلظَّٰلِمُونَ فِي ضَلَٰلٖ مُّبِينٖ ۝١١ ﴾ لقمان: ١٠-١١

មានន័យថា៖ «ទ្រង់បានបង្កើតមេឃដោយគ្មានសសរដូចដែលពួកអ្នកមើលឃើញស្រាប់ ហើយទ្រង់បានដាក់ភ្នំចុះមកដើម្បីទប់លំនឹងផែនដី កុំឱ្យរង្គោះរង្គើដល់ពួកអ្នក។ ទ្រង់ដាក់ពង្រាយសត្វគ្រប់ប្រភេទនៅលើផែនដី យើងបានបញ្ចុះទឹកភ្លៀងពីលើមេឃ បន្ទាប់មក យើងបង្កើតឱ្យរុក្ខជាតិគ្រប់ប្រភេទដុះដាលឡើងស្រស់បំព្រង និងមានប្រយោជន៍។ នេះជាការបង្កើតរបស់អល់ឡោះ ចូរបង្ហាញយើងពីអ្វីដែលអ្នកផ្សេងក្រៅពីយើងបានបង្កើត។ តាមពិត ពួកអ្នកដែលអគតិនោះកំពុងឋិតក្នុងក្តីវង្វេងយ៉ាងជាក់ច្បាស់» ។

- ប្រព័ន្ធបន្តពូជរបស់សត្វមានជីវិតទាំងអស់ដ៏ចម្លែក ដែលទទួលរ៉ាប់រងរក្សានិរន្តរភាពនៃជីវិតរស់នៅ និងតុល្យភាពនៅលើភពផែនដី។ ដូចអល់ឡោះជាម្ចាស់បានមានព្រះបន្ទូលថា៖

﴿وَٱللَّهُ خَلَقَ كُلَّ دَآبَّةٍ مِّن مَّآءٍ فَمِنْهُم مَّن يَمْشِى عَلَىٰ بَطْنِهِۦ وَمِنْهُم مَّن يَمْشِى عَلَىٰ رِجْلَيْنِ وَمِنْهُم مَّن يَمْشِى عَلَىٰٓ أَرْبَعٍ يَخْلُقُ ٱللَّهُ مَا يَشَآءُ إِنَّ ٱللَّهَ عَلَىٰ كُلِّ شَىْءٍ قَدِيرٌ ﴿٤٥﴾﴾ النور : ٤٥

មានន័យថា៖ «ហើយអល់ឡោះទ្រង់បង្កើតគ្រប់សត្វទាំងអស់ដែលរស់នៅលើផែនដីពីសារធាតុទឹក ពពួកសត្វខ្លះលូន ខ្លះទៀតដើរជើងពីរ ហើយខ្លះទៀតដើរជើងបួន អល់ឡោះជាម្ចាស់ទ្រង់បង្កើតអ្វីតាមតែទ្រង់សព្វព្រះទ័យ។ ពិតប្រាកដណាស់ អល់ឡោះទ្រង់មានអានុភាពលើអ្វីគ្រប់យ៉ាង» ។

- ការចែកចាយរបបអាហារចិញ្ចឹមជីវិតដ៏ចម្លែក ការធានាសម្រាប់សត្វលោក និងសភាវៈទាំងមូល។ ដូចទ្រង់បានមានព្រះបន្ទូលថា៖

﴿وَمَا مِن دَآبَّةٍ فِى ٱلْأَرْضِ إِلَّا عَلَى ٱللَّهِ رِزْقُهَا وَيَعْلَمُ مُسْتَقَرَّهَا وَمُسْتَوْدَعَهَا ۚ كُلٌّ فِى كِتَـٰبٍ مُّبِينٍ ﴿٦﴾﴾ هود : ٦

មានន័យថា៖ «ហើយគ្មានសត្វអ្វីដែលដើរនៅលើផែនដីលើកលែងតែអល់ឡោះជាម្ចាស់ ទ្រង់ធានាចំពោះរបបអាហារចិញ្ចឹមជីវិតរបស់វា ទ្រង់ដឹងពីទីជម្រក និងទីអវសានរបស់វា។ អ្វីៗទាំងអស់មានចារក្នុងគម្ពីរព្រះលិខិតយ៉ាងច្បាស់លាស់» ។

សភាវសត្វលោកសព្វបែបយ៉ាងនៅក្នុងចក្រវាល អល់ឡោះជាម្ចាស់បានបញ្ជាក់យ៉ាងច្បាស់ពីប្រភពដើមរបស់វាមួយចំនួន ហើយទ្រង់តែមួយគត់ដឹងពីប្រភពដើមមួយចំនួនផ្សេងទៀត។ ដូចអល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿ سُبۡحَٰنَ ٱلَّذِي خَلَقَ ٱلۡأَزۡوَٰجَ كُلَّهَا مِمَّا تُنۢبِتُ ٱلۡأَرۡضُ وَمِنۡ أَنفُسِهِمۡ وَمِمَّا لَا يَعۡلَمُونَ ٣٦ ﴾ يس: ٣٦

មានន័យថា៖ «អល់ឡោះជាម្ចាស់ទ្រង់មហាពិសិដ្ឋមហាស្អាតស្អំ ទ្រង់បង្កើតឱ្យមានភេទញីឈ្មោលគ្រប់រុក្ខជាតិដែលដុះចេញពីដីនិងកំណើតដែលកើតចេញពីខ្លួនពួកគេ ហើយនិងអ្វីផ្សេងឯទៀតដែលពួកគេមិនដឹង» ។

គ្មានអ្វីមន្ទិលបន្តិចសោះថា មានកម្លាំងចលករមួយដែលបង្កើតឱ្យមានសភាវៈទាំងនេះ ហើយកម្លាំងនោះនៅរក្សា និងដំណើរការ**តាមក្រឹត្យ**ក្រមរបស់វាទាំងមូល។ ដូច្នេះមានការសន្និដ្ឋានបីគ្មានបួនគឺ៖

- ទី១៖ ចក្រវាលទាំងមូលប្រកបដោយក្រឹត្យក្រមជាប្រព័ន្ធកើតឡើងដោយខ្លួនឯង ហើយនេះជាការសន្និដ្ឋានមួយមិនសមហេតុផល ខុសពីការពិតទាំងស្រុង ព្រោះគ្រប់អ្វីទាំងអស់ដែលកើតឡើងតែងតែមានអ្នកបង្កើត។
- ទី២៖ ចក្រវាលនេះបង្កើតឡើងដោយអ្វីមួយ ហើយអ្វីនោះចេញពីចក្រវាលខ្លួនឯង។ ការសន្និដ្ឋានបែបនេះក៏មិនសមហេតុផលដែរ បញ្ញាញាណមិនអាចទទួលយកបាន ពីព្រោះវត្ថុអ្វីមួយមិនអាចបង្កើតអ្វីមួយឱ្យដូចខ្លួនឯងបានឡើយ។

- ទី៣៖ ចក្រវាលនេះ បង្កើតឡើងដោយនរណាម្នាក់ឋិតនៅក្រៅពីពិភពផ្សេងពីចក្រវាល គឺព្រះអល់ឡោះជាម្ចាស់នៃសកលលោក ហើយនេះជាអ្វីដែលពួកអ្នកមូស្លីមជឿ។ ឯចំណែកពួកអ្នកគ្មានជំនឿវិញឋិតក្នុងភាពមន្ទិលសង្ស័យស្ទាក់ស្ទើរ។ ត្រូវនឹងពាក្យបន្ទូលរបស់អល់ឡោះជាម្ចាស់៖

﴿أَمۡ خُلِقُواْ مِنۡ غَيۡرِ شَيۡءٍ أَمۡ هُمُ ٱلۡخَٰلِقُونَ ٣٥ أَمۡ خَلَقُواْ ٱلسَّمَٰوَٰتِ وَٱلۡأَرۡضَۚ بَل لَّا يُوقِنُونَ ٣٦ أَمۡ عِندَهُمۡ خَزَآئِنُ رَبِّكَ أَمۡ هُمُ ٱلۡمُصَيۡطِرُونَ ٣٧﴾ الطور : ٣٥-٣٧

មានន័យថា៖ «តើពួកគេកើតឡើងដោយគ្មានអ្នកបង្កើត ឬក៏ពួកគេជាអ្នកបង្កើតមេឃ និងផែនដី។ តាមពិត ពួកគេគ្មានជំនឿជាក់ ឬក៏ពួកគេមានឃ្លាំងសម្បត្តិព្រះជាម្ចាស់របស់ឯង ឬក៏ពួកគេជាអ្នកត្រួតត្រា» ។

- ភស្តុតាងដែលបញ្ជាក់ថាមានអល់ឡោះ គឺការយល់ឃើញបែបឧបនិស្ស័យ៖

អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿فَأَقِمۡ وَجۡهَكَ لِلدِّينِ حَنِيفٗاۚ فِطۡرَتَ ٱللَّهِ ٱلَّتِي فَطَرَ ٱلنَّاسَ عَلَيۡهَاۚ لَا تَبۡدِيلَ لِخَلۡقِ ٱللَّهِ﴾ الروم : ٣٠

មានន័យថា៖ «ចូរតម្រង់ទិសរបស់ឯងសម្រាប់សាសនាដ៏ត្រឹមត្រូវ ជាឧបនិស្ស័យដែលអល់ឡោះជាម្ចាស់ទ្រង់បានបង្កើតមនុស្សឱ្យមានបែបនេះ គ្មានការផ្លាស់ប្តូរសម្រាប់ការបង្កើតរបស់អល់ឡោះ»។

ខ្លួនមនុស្សគេបង្កើតមកជាមួយនឹងអារម្មណ៍ និងការទទួលស្គាល់ថា មានព្រះជាម្ចាស់ជាអ្នកបង្កើតខ្លួនគេ និងចក្រវាលទាំងមូល ដែលពួកសាសនវិទូបានបញ្ញត្តិថា " សភាវគតិសាសនា " ទោះបីជាឧបនិស្ស័យនេះបានឃ្លាតចាកពីខ្លួនរបស់គេ ក៏មនុស្សនៅតែត្រូវការកម្លាំងចលករនេះដើម្បីបំពេញតម្រូវការ និងកង្វះខាតរបស់គេ ហើយសុំជ្រកកោននៅពេលមានឧបសគ្គលំបាក និងគ្រោះថ្នាក់។ សភាវគតិនេះ មាននៅក្នុងខ្លួនមនុស្សគ្រប់រូបគ្មានករណីលើកលែង ក៏ប៉ុន្តែអ្នកខ្លះបដិសេធដោយភាពចចេសរឹងរូស និងក្រអឺតក្រទម ហើយអ្នកខ្លះទទួលស្គាល់ និងមានជំនឿ។ សភាវគតិនេះលេចឡើងនៅពេលបុគ្គលម្នាក់ធ្លាក់ខ្លួនឈឺអស់សង្ឃឹម ជួបនឹងគ្រោះថ្នាក់ធំ ភ័យរន្ធត់នឹងរឿងដែលខ្លួនមិនពេញចិត្ត ពេលនោះអ្នកនឹងឃើញគេធ្វើទាំងមិនដឹងខ្លួនដោយពោលពាក្យថា ឱព្រះជាម្ចាស់! ឬងើយមើលទៅលើមេឃ ជាការទទួលស្គាល់ចេញពីខ្លួនគេផ្ទាល់ថា មានកម្លាំងអាចកំបាំងដ៏ខ្លាំងក្លាអាចជួយសង្គ្រោះគេពីគ្រោះភ័យទាំងនេះ។ ត្រូវនឹងបន្ទូលរបស់អល់ឡោះជាម្ចាស់៖

﴿ وَإِذَا مَسَّ ٱلۡإِنسَٰنَ ٱلضُّرُّ دَعَانَا لِجَنۢبِهِۦٓ أَوۡ قَاعِدًا أَوۡ قَآئِمٗا فَلَمَّا كَشَفۡنَا عَنۡهُ ضُرَّهُۥ مَرَّ كَأَن لَّمۡ يَدۡعُنَآ إِلَىٰ ضُرّٖ مَّسَّهُۥ ﴾ يونس: ١٢

មានន័យថា៖ «នៅពេលដែលមនុស្សរងនូវគ្រោះថ្នាក់ គេបួងសួងសុំឱ្យយើងសង្គ្រោះទាំងខ្លួននៅដេក ឬអង្គុយ ឬឈរ ដរាបណាយើងបានសង្គ្រោះឱ្យគេរួចផុតភ័យពីគ្រោះថ្នាក់ គេធ្វើហាក់បីដូចខ្លួន

គេពុំបានសុំបួងសួងយើង ឱ្យជួយសង្គ្រោះខ្លួនគេពីគ្រោះថ្នាក់ដែលគេបានទទួលរង»។

- ការដាក់កំហិតរបស់គម្ពីរអាល់គួរអាន៖ គម្ពីរអាល់គួរអានបានដាក់កំហិតឱ្យសត្វលោកទាំងអស់ធ្វើរួមគ្នា ឬផ្សេងគ្នា បង្កើតសភាវៈអ្វីមួយដែលមានជីវិត។ អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿يَٰٓأَيُّهَا ٱلنَّاسُ ضُرِبَ مَثَلٌ فَٱسْتَمِعُوا۟ لَهُۥٓ ۚ إِنَّ ٱلَّذِينَ تَدْعُونَ مِن دُونِ ٱللَّهِ لَن يَخْلُقُوا۟ ذُبَابًا وَلَوِ ٱجْتَمَعُوا۟ لَهُۥ ۖ وَإِن يَسْلُبْهُمُ ٱلذُّبَابُ شَيْـًٔا لَّا يَسْتَنقِذُوهُ مِنْهُ ۚ ضَعُفَ ٱلطَّالِبُ وَٱلْمَطْلُوبُ ﴿٧٣﴾﴾ *الحج: ٧٣*

មានន័យថា៖ "នៃមនុស្សលោកទាំងឡាយ គេលើកឧទាហរណ៍មួយចូរនាំគ្នាស្តាប់ និងពិចារណា ពិតប្រាកដ រូបសំណាកទាំងឡាយដែលពួកអ្នកនាំគ្នាគោរពបូជាក្រៅពីអល់ឡោះជាម្ចាស់នោះ ពួកគេមិនអាចបង្កើតសត្វរុយមួយក្បាល បើទោះជាពួកគេទាំងនោះរួមគ្នាធ្វើក៏ដោយ។ បើសិនជាសត្វរុយលួចពាំចំណីពួកគេ ពួកគេមិនដណ្តើមពីសត្វរុយមកវិញបានឡើយ។ ទាំងរូបសំណាក និងសត្វរុយសុទ្ធតែទន់ខ្សោយដូចគ្នា»។ ជាមួយនោះ ព្រលឹងជាភារកិច្ចរបស់អល់ឡោះជាម្ចាស់គ្មាននរណាដឹងថាព្រលឹងជាអ្វីនោះឡើយ។ លើកលែងតែព្រះអង្គតែមួយគត់។ ទ្រង់បានមានព្រះបន្ទូលថា៖

﴿وَيَسْـَٔلُونَكَ عَنِ ٱلرُّوحِ ۖ قُلِ ٱلرُّوحُ مِنْ أَمْرِ رَبِّى وَمَآ أُوتِيتُم مِّنَ ٱلْعِلْمِ إِلَّا قَلِيلًا ﴿٨٥﴾﴾ *الإسراء: ٨٥*

មានន័យថា៖ «ពួកអ្នកគ្មានជំនឿសួរអ្នកអំពីព្រលឹង ចូរប្រាប់ពួកគេវិញថា ព្រលឹងគឺជារឿងរបស់ព្រះជាម្ចាស់របស់ខ្ញុំ ហើយគេគ្មានបានឱ្យចំណេះដឹងដល់ពួកអ្នកលើកលែងតែបន្តិចបន្តួច»។

តាមពិត ពួកគេអសមត្ថភាពនឹងបង្កើតអ្វីដែលគ្មានព្រលឹង អ្នកនាំសារមូហាំម៉ាត់បានមានប្រសាសន៍ថា៖

يقول صلى الله عليه وسلم: قال الله عز وجل: ( وَمَنْ أَظْلَمُ مِمَّنْ ذَهَبَ يَخْلُقُ كَخَلْقِي فَلْيَخْلُقُوا ذَرَّةً، أَوْ لِيَخْلُقُوا حَبَّةً أَوْ شَعِيرَةً ) *صحيح البخاري*

មានន័យថា៖ «អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា គ្មាននរណាអគតិជាងអ្នកដែលបង្កើតដូចជាការបង្កើតរបស់យើង ចូរឱ្យគេបង្កើតគ្រាប់ពោត ឬឱ្យគេបង្កើតគ្រាប់ធញ្ញជាតិ ឬបង្កើតគ្រាប់ស្រូវសាឡី» ។

ការអសមត្ថភាពរបស់មនុស្សក្នុងការចាត់ចែងចក្រវាល ជាភស្តុតាងបញ្ជាក់ថា មានព្រះជាម្ចាស់ជាអ្នកបង្កើត និងជាអ្នកចាត់ចែង។ ដូចអល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលៈ

﴿ أَلَمْ تَرَ إِلَى ٱلَّذِى حَآجَّ إِبْرَٰهِـۧمَ فِى رَبِّهِۦٓ أَنْ ءَاتَىٰهُ ٱللَّهُ ٱلْمُلْكَ إِذْ قَالَ إِبْرَٰهِـۧمُ رَبِّىَ ٱلَّذِى يُحْىِۦ وَيُمِيتُ قَالَ أَنَا۠ أُحْىِۦ وَأُمِيتُ ۖ قَالَ إِبْرَٰهِـۧمُ فَإِنَّ ٱللَّهَ يَأْتِى بِٱلشَّمْسِ مِنَ ٱلْمَشْرِقِ فَأْتِ بِهَا مِنَ ٱلْمَغْرِبِ فَبُهِتَ ٱلَّذِى كَفَرَ ۗ وَٱللَّهُ لَا يَهْدِى ٱلْقَوْمَ ٱلظَّـٰلِمِينَ ﴿٢٥٨﴾ ﴾ *البقرة : ٢٥٨*

មានន័យថា៖ «តើឯងឃើញទេ សភាពរបស់អ្នកដែលបានប្រកែកជាមួយនឹងអ៊ីព្រហ៊ីមក្នុងរឿងព្រះជាម្ចាស់របស់គេ។ ព្រោះតែអល់ឡោះជាម្ចាស់បានប្រទានអំណាចដល់គេ ខណៈដែលអ៊ីព្រហ៊ីម

បាននិយាយថា ព្រះជាម្ចាស់របស់ខ្ញុំដែលទ្រង់ផ្តល់ជីវិត និងដកយកជីវិត។ ស្តេចទមិឡនោះនិយាយថា អញក៏អាចទុកជីវិត និងសម្លាប់បានដែរ។ អ៊ីព្រហ៊ីមនិយាយថា ពិតប្រាកដ អល់ឡោះជាម្ចាស់ទ្រង់អាចធ្វើឱ្យព្រះអាទិត្យរះពីទិសខាងកើត ចូរឱ្យព្រះអាទិត្យរះពីទិសខាងលិចវិញមើលបានទេ? ដូច្នេះ អ្នកដែលគ្មានជំនឿនោះត្រូវទ័លគំនិត ហើយអល់ឡោះជាម្ចាស់ ទ្រង់មិនចង្អុលបង្ហាញផ្លូវចំពោះពួកអ្នកដែលអគតិនោះឡើយ» ។

- ប្រហែលជាភស្តុតាងមួយទៀតបញ្ជាក់ថាមានអល់ឡោះជាម្ចាស់ គឺការដាក់កំហិតរបស់ទ្រង់ឱ្យមនុស្សទូទៅនិពន្ធគម្ពីរមួយដែលដូចនឹងគម្ពីរអាល់គួរអាន ដែលជាគម្ពីរបញ្ចុះពីលើមេឃមកចុងក្រោយបង្អស់ ជាការដាក់កំហិតដែលមានតំលៃជានិរន្តរ៍រហូតដល់ថ្ងៃបរលោក។ អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿قُل لَّئِنِ ٱجۡتَمَعَتِ ٱلۡإِنسُ وَٱلۡجِنُّ عَلَىٰٓ أَن يَأۡتُواْ بِمِثۡلِ هَٰذَا ٱلۡقُرۡءَانِ لَا يَأۡتُونَ بِمِثۡلِهِۦ وَلَوۡ كَانَ بَعۡضُهُمۡ لِبَعۡضٖ ظَهِيرٗا ٨٨﴾ الإسراء : ٨٨

មានន័យថា៖ «មូហាំម៉ាត់ចូរប្រសាសន៍ចុះថា បើសិនជាមនុស្ស និងជិនប្រមូលផ្តុំគ្នាព្យាយាមនិពន្ធឱ្យដូចគម្ពីរអាល់គួរអាន ពួកគេមិនអាចធ្វើបានជាដាច់ខាត បើទោះជាពួកគេជួយសហការគ្នាក៏ដោយ»។

នរណាកើតមន្ទិលសង្ស័យចំពោះការមានវត្តមានរបស់អល់ឡោះជាម្ចាស់ ឬកើតមន្ទិលចំពោះសាររបស់អ្នកនាំសារមូហាំម៉ាត់ សូមអ្នកនោះទទួលនូវការដាក់កំហិតនេះ ហើយនិពន្ធឱ្យដូចគម្ពីរ

អាល់គួរអាន។ គេដឹងច្បាស់ថា ពួកអ្នកជំនាញខាងភាសា ខាងនិពន្ធ ហើយអ្នកដែលពូកែវោហារទាំងអស់ គេប្រទានគម្ពីរនេះចុះមកជាភាសារបស់ពួកគេ បានខិតខំព្យាយាមណាស់ដែរ តែពួកគេនៅតែអសមត្ថភាពជាមួយនឹងការខិតខំប្រឹងប្រែងដ៏ខ្លាំងក្លារបស់ពួកគេ ដើម្បីឆ្លើយតបនឹងការដាក់កំហិតនេះ។

គម្ពីរអាល់គួរអានជាពាក្យបន្ទូលរបស់អល់ឡោះបញ្ចុះមកពីព្រះអង្គផ្ទាល់។ ដូចទ្រង់បានមានព្រះបន្ទូលថា៖

﴿وَمَا كَانَ هَٰذَا ٱلْقُرْءَانُ أَن يُفْتَرَىٰ مِن دُونِ ٱللَّهِ وَلَٰكِن تَصْدِيقَ ٱلَّذِى بَيْنَ يَدَيْهِ وَتَفْصِيلَ ٱلْكِتَٰبِ لَا رَيْبَ فِيهِ مِن رَّبِّ ٱلْعَٰلَمِينَ ﴿٣٧﴾﴾ يونس : ٣٧

មានន័យថា៖ «គ្មាននរណាម្នាក់មានសមត្ថភាពនិពន្ធគម្ពីរអាល់គួរអាននេះឡើងក្រៅអំពីអល់ឡោះ។ តែអល់ឡោះជាម្ចាស់បានបញ្ចុះគម្ពីរនេះមកជាការបញ្ជាក់ពីភាពត្រឹមនៃគម្ពីរមុនៗ ហើយក៏ជាការបកស្រាយដែលគ្មានភាពមន្ទិលសង្ស័យមកអំពីព្រះជាម្ចាស់នៃសកលលោកទាំងមូល »។

បើសិនជាគម្ពីរនេះជាសំដីរបស់មនុស្សនោះនឹងត្រដាងឡើងនូវភាពចម្រូងចម្រាសក្នុងវាក្យខណ្ឌនីមួយៗ។ ដូចទ្រង់បានមានព្រះបន្ទូលថា៖

﴿أَفَلَا يَتَدَبَّرُونَ ٱلْقُرْءَانَ ۚ وَلَوْ كَانَ مِنْ عِندِ غَيْرِ ٱللَّهِ لَوَجَدُوا۟ فِيهِ ٱخْتِلَٰفًا كَثِيرًا ﴿٨٢﴾﴾ النساء : ٨٢

មានន័យថា៖ «តើពួកគេមិនពិនិត្យមើលនៅក្នុងគម្ពីរអាល់គួរអានទេឬ? បើសិនជាគម្ពីរនេះមកអំពីអ្នកផ្សេងក្រៅពីអល់ឡោះ ពួកគេនឹងប្រទះឃើញក្នុងគម្ពីរនេះ នូវការខ្វែងគ្នាយ៉ាងច្រើន»។

២- ជឿចំពោះពួកទេវតា៖ គឺជាជំនឿមួយដែលជឿថាសម្រាប់អល់ឡោះជាម្ចាស់ទ្រង់មានពួកទេវតាដ៏ច្រើនសន្ធឹកសន្ធាប់គ្មាននរណាដឹងពីចំនួនរបស់ពួកគេឡើយ។ មានតែអល់ឡោះជាម្ចាស់ទេជាអ្នកដែលដឹង។ ទ្រង់បង្កើតពួកគេសម្រាប់ឱ្យគោរពសក្ការៈចំពោះទ្រង់។ អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿ لَّن يَسْتَنكِفَ ٱلْمَسِيحُ أَن يَكُونَ عَبْدًا لِّلَّهِ وَلَا ٱلْمَلَٰٓئِكَةُ ٱلْمُقَرَّبُونَ ﴾ النساء: ١٧٢

មានន័យថា៖ «មេស៊ី (យេស៊ូ)មិនដែលប្រមាថជាដាច់ខាតចំពោះការដាក់ខ្លួនជាខ្ញុំបម្រើរបស់អល់ឡោះ ហើយពួកទេវតាដ៏ជិតស្និទ្ធនឹងទ្រង់ក៏អ៊ីចឹងដែរ»។

ពួកទេវតាទាំងនោះពុំមែនជាព្រះផ្សេងក្រៅពីអល់ឡោះ ពួកគេពុំមែនជាបុត្ររបស់ទ្រង់ តាមពិតទ្រង់បង្កើតពួកគេដើម្បីឱ្យពួកគេបំពេញការងារដែលទ្រង់បានបង្គាប់ប្រើ។ ដូចទ្រង់បានមានព្រះបន្ទូលថា៖

﴿ وَقَالُوا۟ ٱتَّخَذَ ٱلرَّحْمَٰنُ وَلَدًا ۗ سُبْحَٰنَهُۥ ۚ بَلْ عِبَادٌ مُّكْرَمُونَ ﴿٢٦﴾ لَا يَسْبِقُونَهُۥ بِٱلْقَوْلِ وَهُم بِأَمْرِهِۦ يَعْمَلُونَ ﴿٢٧﴾ ﴾ الأنبياء: ٢٦-٢٧

មានន័យថា៖ «ពួកអ្នកគោរពពហុទេពនិយាយថា ព្រះជាម្ចាស់មហាមេត្តាទ្រង់មានបុត្រ។ ព្រះជាម្ចាស់មហាស្អាតស្អំ! តាមពិត ពួកគេ

គ្រាន់តែខ្ញុំបម្រើរបស់ទ្រង់ដ៏មហាប្រពៃតែប៉ុណ្ណោះ។ ពួកគេមិនដែលនិយាយពាក្យអ្វីមុនព្រះអង្គបង្គាប់ ហើយពួកគេធ្វើតាមការបង្គាប់របស់ព្រះអង្គ»។

៣- ជឿចំពោះព្រះគម្ពីរ៖ គឺជាការជឿថាអល់ឡោះជាម្ចាស់ទ្រង់បានប្រទានគម្ពីរជាច្រើនចុះពីលើមេឃមកកាន់ពួកអ្នកនាំសាររបស់ទ្រង់ដើម្បីផ្សព្វផ្សាយគម្ពីរទាំងនេះដល់មនុស្សលោក បកស្រាយប្រាប់ពួកគេពីច្បាប់ស្ហារីអាត់ដែលពួកគេនឹងគោរពសក្ការៈចំពោះទ្រង់ រួមទាំងការរៀបចំជីវិតរស់នៅរបស់ពួកគេ។គម្ពីរទាំងនោះមានដូចជា៖

1. គម្ពីរ ស៊ូហុហ្វរបស់អ្នកនាំសារអ៊ីព្រហ៊ីម។
2. គម្ពីរតាវរ៉ត ជាគម្ពីរដ៏ពិសិដ្ឋដែលព្រះបានប្រទានចុះមកឱ្យអ្នកនាំសារមូសា។
3. គម្ពីរអើសហ្សាពួរ ជាគម្ពីរដែលទ្រង់បានប្រទានចុះមកចំពោះអ្នកនាំសារ ដាវូត។
4. គម្ពីរអិញជីលជាគម្ពីរដែលព្រះបានប្រទានចុះមកចំពោះអ៊ីសា (យេស៊ូ)។
5. គម្ពីរអាល់គួរអាន ជាគម្ពីរដ៏ពិសិដ្ឋដែលព្រះបានប្រទានចុះមកចំពោះអ្នកនាំសារមូហាំម៉ាត់ ដើម្បីផ្សព្វផ្សាយអំពាវនាវដល់មនុស្សទូទៅ ហើយទ្រង់បានចាត់ទុកគម្ពីរមុនៗជាមោឃៈ បន្ទាប់ពីទ្រង់បានប្រទានគម្ពីរអាល់គួរអាននេះរួចមក។

## តើគម្ពីរអាល់គួរអានជាអ្វី?

ជាពាក្យបន្ទូលរបស់អល់ឡោះដែលទ្រង់ប្រទានចុះមកចំពោះអ្នកនាំសារមូហាំម៉ាត់ជាភាសាអារ៉ាប់។ គ្រាន់តែ សូត្រគេចាត់ទុកជាការគោរពសក្ការៈ។ គម្ពីរនេះបានចម្លងយ៉ាងត្រឹមត្រូវតៗគ្នាទាំងសំណេរ និងការទន្ទេញចាំ ចាប់ផ្តើមដោយជំពូកមួយហៅថា (ស៊ូរ៉ោះអាល់ហ្វាទីហះ) ហើយបញ្ចប់ដោយជំពូកមួយហៅថា (ស៊ូរ៉ោះ អាន់ណើស)។ គម្ពីរនេះជាធម្មនុញ្ញសម្រាប់ពួកអ្នកមូស្លីម ដែលពួកគេដកស្រង់នូវពាក្យទូន្មានប្រៀនប្រដៅ ក្បួនច្បាប់សម្រាប់រៀបចំកិច្ចការសាសនា និងសង្គមរស់នៅរបស់ពួកគេឱ្យមានច្បាប់ទម្លាប់ ខុសពីគម្ពីរមុនៗដូចតទៅ៖

- ជាគម្ពីរប្រទានចុះពីលើមេឃមកចុងក្រោយបង្អស់ ដែលទ្រង់សន្យាអភិរក្ស និងរក្សាច្បាប់ដើមគម្ពីរនេះឱ្យនៅគង់វង្សរហូតដល់ថ្ងៃបរលោក។ ដូចអល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿ إِنَّا نَحْنُ نَزَّلْنَا ٱلذِّكْرَ وَإِنَّا لَهُۥ لَحَٰفِظُونَ ٩ ﴾ الحجر : ٩

មានន័យថា៖ "ពិតប្រាកដ យើងបានប្រទានគម្ពីរអាល់គួរអានចុះមក ហើយយើងជាអ្នកថែរក្សាគម្ពីរនេះ"។

- គ្របដណ្តប់នូវរាល់ការបញ្ញត្តិច្បាប់ទាំងឡាយ
- ដែលច្បាប់នេះនឹងបង្កើតនូវសង្គមមួយប្រកបដោយគុណធម៌ និងជានាទទួលខុសត្រូវចំពោះការគោរពសិទ្ធិមនុស្ស។

- គេចាត់ទុកជាឯកសារប្រវត្តិសាស្ត្រមួយដែលបញ្ជាក់ពីសារតារនៃការបញ្ចុះសាសនាមកចំពោះពួកអ្នកនាំសារ ហើយហេតុការណ៍ដែលបានកើតឡើងចំពោះពួកគេ ជាមួយនឹងជាតិសាសន៍របស់ខ្លួនតាំងពីសម័យអាដាំរហូតដល់អ្នកនាំសារទីបញ្ចប់គឺ ព្យាការីមូហាំម៉ាត់។
- គម្ពីរនេះគេបញ្ចុះមកសម្រាប់មនុស្សជាតិទូទៅ ដើម្បីឱ្យពួកគេទទួលបាននូវភាពសុខដុមរមនា សេចក្ដីសុខ សុវត្ថិភាព ស្ថេរភាព ស្ងប់ស្ងាត់ នាំពួកគេចេញឱ្យផុតពីភាពងងឹតអន្ធការទៅរកពន្លឺដ៏ភ្លឺថ្លានៃជីវិត។
- គម្ពីរនេះមានគុណសម្បត្តិធំធេងណាស់ គ្រាន់តែការសូត្រទន្ទេញចាំមាត់ និងបង្រៀនគេឱ្យចេះសូត្រក៏ជាការគោរពសក្ការៈចំពោះអល់ឡោះជាម្ចាស់ផងដែរ។

## សាសន៍ដទៃនិយាយអំពីគម្ពីរអាល់គួរអាន៖

លោក វ. ដូរ៉ង់ត៍ (W.Durant) ក្នុងសៀវភៅអរិយធម៌របស់លោកបានសរសេរថា គម្ពីរអាល់គួរអានបញ្ជូនមកកាន់ចិត្តមនុស្សជាជំនឿដ៏ងាយស្រួល គ្មានភាពស្រពេចស្រពិល គ្មានពិធីសាសនាដ៏ស្មុគស្មាញ ចាកផុតទាំងស្រុងពីជំនឿលើអារក្សអ្នកតា ជំនឿលើភិក្ខុ និងបព្វជិតសាសនា។ គម្ពីរអាល់គួរអានមានគុណសម្បត្តិធំធេងក្នុងការលើកកម្ពស់ពួកអ្នកមូស្លីមផ្នែកខាងសីលធម៌ និងវប្បធម៌។ ជាគម្ពីរដែលបញ្ញត្តិឡើងនូវបទដ្ឋាន របៀបរបបសង្គម ឯកភាពជាតិ ជំរុញឱ្យពួកគេប្រកាន់តាមគោលការណ៍សុខភាព ហើយរំដោះប្រាជ្ញាស្មារតីពួក

គេឱ្យរួចផុតពីជំនឿអរូបី ការស្រមើស្រមៃ ចេញពីភាពអយុត្តិធម៌ ហិង្សាព្រៃផ្សៃ ហើយស្តារពួកវណ្ណៈទាសករឱ្យមានភាពប្រសើរឡើងវិញ។ លើកស្ទួយពួកអ្នកមានវណ្ណៈតូចទាបឱ្យមានតម្លៃ និងឥស្សរភាពឡើងវិញ។ បង្កើតឱ្យមានសមធម៌ក្នុងសង្គមមូស្លីម ប្រាសចាកពីមហិច្ឆតាលោភលន់ គ្មានសង្គមណាអាចប្រៀបស្មើនឹងសង្គមឥស្លាម ទោះនៅទីណាក៏ដោយក្នុងសកលលោកទាំងមូល ដែលមានជនជាតិស្បែកសរស់នៅ។

៤-ជឿចំពោះពួកអ្នកនាំសារ៖ ជឿថាអល់ឡោះជាម្ចាស់ទ្រង់បានជ្រើសរើសពួកអ្នកនាំសារពីក្នុងចំណោមមនុស្សលោកដើម្បីផ្តល់សារ និងនីតិច្បាប់របស់អល់ឡោះដល់មនុស្សលោកទូទៅ ដើម្បីកុំឱ្យពួកគេយកលេសជាមួយទ្រង់បន្ទាប់ពីបញ្ជូនពួកអ្នកនាំសាររួច។ ពួកគេជាមនុស្សដែលមានសីលធម៌សុក្រឹតត្រឹមត្រូវបំផុត។ ពួកគេគ្មានកំហុសចំពោះអ្វីដែលពួកគេផ្សព្វផ្សាយអំពីអល់ឡោះជាម្ចាស់។ ពួកអ្នកនាំសាររបស់ទ្រង់មានចំនួនច្រើនឥតគណនា គ្មាននរណាដឹងពីចំនួនរបស់ពួកគេ លើកលែងអល់ឡោះ ពួកគេជាមនុស្សធម្មតា តែទ្រង់បានផ្តល់លក្ខណៈពិសេសសម្រាប់ពួកគេក្នុងការទទួលសារពីទ្រង់។ ដូចទ្រង់បានមានព្រះបន្ទូលថា៖

﴿وَمَآ أَرۡسَلۡنَا قَبۡلَكَ إِلَّا رِجَالٗا نُّوحِيٓ إِلَيۡهِمۡۖ فَسۡـَٔلُوٓاْ أَهۡلَ ٱلذِّكۡرِ إِن كُنتُمۡ لَا تَعۡلَمُونَ ٧﴾ الأنبياء : ٧

មានន័យថា «យើងពុំបានបញ្ជូនអ្នកនាំសារមុនឯងលើកលែងតែពួកគេជាបុរសដែលយើងបានត្រាស់បន្ទូលចំពោះពួកគេ។ ចូរនាំគ្នាសួរពួក

អ្នកចេះដឹង បើសិនជាពួកអ្នកមិនដឹង»។ អ្នកនាំសារដំបូងបង្អស់គឺណូហ (ណូអេ) ហើយចុងក្រោយបង្អស់គឺអ្នកនាំសារមូហាំម៉ាត់។

៥- ជឿចំពោះថ្ងៃបរលោក៖ ជឿថាជីវិតរស់នៅលោកីយ៍នឹងមានថ្ងៃបញ្ចប់ និងសាបសូន្យ។ ដូចទ្រង់បានមានព្រះបន្ទូលថា៖

﴿كُلُّ مَنْ عَلَيْهَا فَانٍ ﴿٢٦﴾ وَيَبْقَىٰ وَجْهُ رَبِّكَ ذُو الْجَلَالِ وَالْإِكْرَامِ ﴿٢٧﴾﴾
الرحمن : ٢٦-٢٧

មានន័យថា៖ «រាល់អ្នកដែលនៅលើផែនដីទាំងអស់ត្រូវវិនាស ហើយនៅសល់តែព្រះភក្រ្តរបស់ព្រះជាម្ចាស់របស់ឯង ដែលមានព្រះកិត្តិនាមថ្លៃថ្លា ឧត្តុងឧត្តម»។ បន្ទាប់មកទៀត ទ្រង់នឹងបង្កើតឱ្យរស់ឡើងវិញងើបចេញពីផ្នូរ នៅពេលនោះ ទ្រង់នឹងបង្កើតសត្វលោកទាំងអស់ឱ្យរស់ឡើងវិញដើម្បីជំនុំជំរះពួកគេ ហើយតបស្នងតាមអំពើរបស់ពួកគេ។ ទ្រង់ប្រទានជូនពួកអ្នកធ្វើល្អសក្តិសមនឹងអ្វីដែលពួកគេបានសាងដូចជាពើល្អ ក្តីជំនឿ ការប្រតិបត្តិតាមពួកអ្នកនាំសារ។ ផ្ទុយទៅវិញទ្រង់នឹងដាក់ទោសចំពោះពួកអ្នកសាងអំពើអាក្រក់ ជាការតបស្នងតាមអ្វីដែលពួកគេបានសាងនៃអំពើបាប ការក្បត់នឹងជំនឿ ការប្រព្រឹត្តបទល្មើសប្រឆាំងនឹងពួកអ្នកនាំសារ មិនជឿចំពោះជីវិតអមតៈនៅថ្ងៃបរលោកដែលមានឋានសួគ៌ និងឋាននរក។

៦- ជឿចំពោះព្រះលិខិត៖ ជឿថាអល់ឡោះជាម្ចាស់ទ្រង់ដឹងពីបុព្វេនូវរាល់អ្វីគ្រប់យ៉ាងមុននឹងវាកើតឡើង ហើយនិងអ្វីដែលនឹងកើតចំណេះដឹង ការលិខិតកំណត់ និងក្តីប្រាថ្នារបស់ទ្រង់។ ដូចទ្រង់បានមានព្រះបន្ទូលថា៖

﴿ وَخَلَقَ كُلَّ شَىۡءٖ فَقَدَّرَهُۥ تَقۡدِيرٗا ﴿٢﴾ ﴾ الفرقان : ٢

មានន័យថា៖ «ទ្រង់បានបង្កើតអ្វីគ្រប់យ៉ាង ហើយទ្រង់បានកំណត់ទៅតាម**ក្រឹត្យ**ក្រមរបស់វា»។

ផ្លែផ្កានៃជំនឿចំពោះព្រះលិខិតកើតឡើងបន្ទាប់ពីយកហេតុជាបច្ច័យ៖

1. ធ្វើឱ្យអារម្មណ៍ស្រស់ស្រាយ ចិត្តស្ងប់ស្ងប់ស្ងាត់ គ្មានចន្លោះប្រហោងសម្រាប់ការកើតទុក្ខខ្វល់ខ្វាយ ចំពោះអ្វីដែលកើតឡើង ឬបានកើតឡើងកន្លងផុត។
2. អំពាវនាវទៅរកចំណេះដឹង និងរបកកំហើញដែលអល់ឡោះជាម្ចាស់ទ្រង់បានដាក់ចុះមកក្នុងចក្រវាល។ អ្វីដែលទ្រង់បានកំណត់ទៅលើមនុស្សគឺការប្រឈមទាំងឡាយ ដូចជា ជំងឺ វាជាការកំណត់ ដែលគេជំរុញឱ្យស្វែងរកការព្យាបាល ដើម្បីប្រានចោលនូវការកំណត់លិខិតនេះ ស្វែងរកប្រភពថ្នាំព្យាបាលដែលមាននៅក្នុងអ្វីដែលអល់ឡោះជាម្ចាស់ ទ្រង់បានបង្កើតមកនៅក្នុងពិភពលោក។
3. ចិត្តផ្សារភ្ជាប់នឹងអល់ឡោះជាម្ចាស់ មិនត្រូវភ័យខ្លាចចំពោះការបង្កគ្រោះថ្នាក់របស់មនុស្ស។ អ្នកនាំសារលោកបានមានប្រសាសន៍ថា៖

يقول صلى الله عليه وسلم: (.. وَاعْلَمْ أَنَّ الأُمَّةَ لَوِ اجْتَمَعَتْ عَلَى أَنْ يَنْفَعُوْكَ بِشَيْءٍ لَمْ يَنْفَعُوْكَ إِلاَّ بِشَيْءٍ قَدْ كَتَبَهُ اللهُ لَكَ وَلَوِ اجْتَمَعُوْا عَلَى أَنْ يَضُرُّوْكَ بِشَيْءٍ لَمْ يَضُرُّوْكَ إِلاَّ بِشَيْءٍ قَدْ كَتَبَهُ اللهُ عَلَيْكَ رُفِعَتِ الأَقْلاَمُ وَجَفَّتِ الصُّحُفُ) *سنن الترمذي*

មានន័យថា៖ «ចូរជ្រាបចុះថា បើសិនជាប្រជាតិទាំងមូលប្រមូលគ្នាចង់ជួយជាប្រយោជន៍អ្វីដល់អ្នក ពួកគេមិនអាចជួយជាប្រយោជន៍ដល់អ្នកជាដាច់ខាត លុះត្រាតែអ្វីដែលទ្រង់បានចារសម្រាប់អ្នក។ បើសិនជាពួកគេប្រមូលគ្នាចង់ធ្វើបាបអ្នក ពួកគេមិនអាចធ្វើបាបអ្នកបានជាដាច់ខាត លុះត្រាតែអ្វីដែលអល់ឡោះទ្រង់បានចារទៅលើអ្នក។ បញ្ជីព្រះលិខិតគេលែងសរសេរ ទំព័រនៃព្រះលិខិតក៏ស្ងួតអស់ហើយដែរ » ។

## គោលការណ៍គ្រឹះរបស់ឥស្លាម

គោលការណ៍គ្រឹះរបស់ឥស្លាម គឺរក្សាអាយុជីវិត (លើកលែងតែមានទោសដែលច្បាប់ឥស្លាមបានកំណត់) រក្សាកិត្តិយស ទ្រព្យសម្បត្តិ បញ្ញា និងពូជសាសន៍។ អ្នកនាំសារឥស្លាមបានមានប្រសាសន៍ថា៖

يقول رسول الإسلام صلى الله عليه وسلم : (فَإِنَّ اللهَ حَرَّمَ عَلَيْكُمْ دِمَاءَكُمْ وَأَمْوَالَكُمْ وَأَعْرَاضَكُمْ كَحُرْمَةِ يَوْمِكُمْ هَذَا فِيْ شَهْرِكُمْ هَذَا فِيْ بَلَدِكُمْ هَذَا) صحيح البخاري

មានន័យថា៖ «ពិតប្រាកដ អល់ឡោះជាម្ចាស់ទ្រង់បានហាមទៅលើពួកអ្នកទាំងអស់គ្នានូវការបង្ហូរឈាម និងការបៀតបៀនកិត្តិយសត្រូវហាមដូចជាថ្ងៃនេះ ក្នុងខែរនេះ ក្នុងនគរដ៏ពិសិដ្ឋនេះ (នគរម៉ឹក្កះ)» ។

លោកបានមានប្រសាសន៍ទៀតថា៖

ويقول أيضًا: ( أَلاَ أُخْبِرُكُمْ بِالْمُؤْمِنِ مَنْ أَمِنَهُ النَّاسُ عَلَى أَمْوَالِهِمْ وَأَنْفُسِهِمْ وَالْمُسْلِمُ مَنْ سَلِمَ النَّاسُ مِنْ لِسَانِهِ وَيَدِهِ وَالْمُجَاهِدُ مَنْ جَاهَدَ نَفْسَهِ فِيْ طَاعَةِ اللهِ وَالْمُهَاجِرُ مَنْ

هَجَرَ الْخَطَايَا وَالذُّنُوْبَ ) صحيح ابن حبان

មានន័យថា៖ «តើខ្ញុំមិនបានប្រាប់ពួកអ្នកពីបុគ្គលមានជំនឿទេរឺ? គឺអ្នកដែលមនុស្សទាំងអស់ទទួលបានសេចក្ដីសុខសុវត្ថិភាពពីរូបគេទាំងទ្រព្យសម្បត្តិ និងអាយុជីវិត។ អ្នកមូស្លីមគឺជាអ្នកដែលមនុស្សទាំងឡាយទទួលបានសេចក្ដីសុខសន្តិភាពអំពីពាក្យសំដីរបស់គេ ដៃជើងរបស់គេ។ អ្នកដែលតស៊ូពលី គឺអ្នកដែលតស៊ូជំនះនឹងខ្លួនឯងក្នុងការគោរពប្រណិប័តន៍ចំពោះអល់ឡោះ ហើយអ្នកដែលភៀសខ្លួន គឺអ្នកដែលលះបង់ជៀសឆ្ងាយពីកំហុស និងអំពើបាប»។

## គ្រមសីលធម៌ឥស្លាម

ឥស្លាមបានហាមគ្រប់អំពើអបាយមុខទាំងឡាយទាំងកាយវិការ និងពាក្យសំដី។ អល់ឡោះជាម្ចាស់ទ្រង់បានបន្ទូលថា៖

﴿ قُلْ إِنَّمَا حَرَّمَ رَبِّىَ ٱلْفَوَٰحِشَ مَا ظَهَرَ مِنْهَا وَمَا بَطَنَ وَٱلْإِثْمَ وَٱلْبَغْىَ بِغَيْرِ ٱلْحَقِّ وَأَن تُشْرِكُوا۟ بِٱللَّهِ مَا لَمْ يُنَزِّلْ بِهِۦ سُلْطَٰنًا وَأَن تَقُولُوا۟ عَلَى ٱللَّهِ مَا لَا تَعْلَمُونَ ﴿٣٣﴾ ﴾ الأعراف : ٣٣

មានន័យថា៖ «មូហាំម៉ាត់ចូរប្រសាសន៍ចុះថា ពិតប្រាកដ ព្រះជាម្ចាស់របស់ខ្ញុំទ្រង់បានហាមអំពើអបាយមុខទាំងបើកចំហ និងលាក់បាំង ទ្រង់ហាមអំពើបាប និងការបំពានបៀតបៀនដោយខុសច្បាប់ ទ្រង់ហាមការចូលហ៊ុនជាមួយអល់ឡោះ ក្នុងការគោរពសក្ការៈ ដែល

គ្មានភស្តុតាងបញ្ជាក់មក ទ្រង់ហាមការនិយាយប្រឌិតចំពោះអល់ឡោះនូវអ្វីដែលពួកអ្នកមិនដឹង»។

ទ្រង់បង្គាប់ឱ្យប្រកាន់យកនូវសីលធម៌ល្អ ហើយពេញចិត្តចំពោះសីលធម៌ល្អនេះ។ អ្នកនាំសារលោកបានមានប្រសាសន៍ថា៖

يقول رسول الإسلام صلى الله عليه وسلم: ( بُعِثْتُ لِأُتَمِّمَ صَالِحَ الْأَخْلَاقِ )

*المستدرك على الصحيحين*

មានន័យថា៖ «គេបញ្ជូនខ្ញុំមកដើម្បីបំពេញសីលធម៌ល្អ»។

## សិទ្ធិក្នុងឥស្លាម

ឥស្លាមបានដាក់ចេញនូវសិទ្ធិ និងកាតព្វកិច្ចទៅលើសាសនិកឥស្លាមម្នាក់ៗតាមលំដាប់ឋានានុក្រមរបស់ខ្លួន។ ឪពុកម្តាយមានសិទ្ធិ ប្តីប្រពន្ធក៏មានសិទ្ធិរៀងៗខ្លួន កូនៗក៏មានសិទ្ធិ ហើយញាតិជិតខាងក៏មានសិទ្ធិ។ល។ គោលបំណងនៃសិទ្ធិទាំងនេះ គឺជាចំណងផ្សារសាច់ផ្សារឈាមបុគ្គលនិងបុគ្គលក្នុងសង្គមមូស្លីម រក្សាការពារមិនឱ្យរង្គោះរង្គើរ បែកបាក់ និងសាបព្រោះសេចក្តីស្រលាញ់មេត្រីភាពរវាងពួកគេ។ អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿وَٱعۡبُدُواْ ٱللَّهَ وَلَا تُشۡرِكُواْ بِهِۦ شَيۡـٔٗاۖ وَبِٱلۡوَٰلِدَيۡنِ إِحۡسَٰنٗا وَبِذِي ٱلۡقُرۡبَىٰ وَٱلۡيَتَٰمَىٰ وَٱلۡمَسَٰكِينِ وَٱلۡجَارِ ذِي ٱلۡقُرۡبَىٰ وَٱلۡجَارِ ٱلۡجُنُبِ وَٱلصَّاحِبِ بِٱلۡجَنۢبِ وَٱبۡنِ ٱلسَّبِيلِ وَمَا مَلَكَتۡ أَيۡمَٰنُكُمۡۗ إِنَّ ٱللَّهَ لَا يُحِبُّ مَن كَانَ مُخۡتَالٗا فَخُورًا ٣٦﴾ النساء: ٣٦

មានន័យថា៖ «ចូរគោរពសក្ការៈចំពោះអល់ឡោះ កុំយកអ្វីមួយមកចូលហ៊ុនជាមួយទ្រង់ ត្រូវកត្តញ្ញូចំពោះឪពុកម្ដាយ ធ្វើល្អចំពោះសាច់ញាតិ កូនកំព្រា អ្នកទីទ័លក្រ អ្នកជិតខាងដែលជាប់សាច់ជាប់ឈាម និងញាតិនៅក្បែរខាងគ្នា មិត្តភ័ក្ត្រដែលនៅក្បែរខាងគ្នា អ្នកដំណើរដាច់សង្វែង និងអ្នកបម្រើដែលនៅក្រោមអាណាព្យាបាលរបស់ពួកអ្នក។ ពិតប្រាកដណាស់ អល់ឡោះទ្រង់មិនសព្វព្រះទ័យចំពោះអ្នកដែលមានមោទនភាពក្រអឺតក្រទមនោះឡើយ»។

តាមទីសាធារណៈក៏មានសិទ្ធិ អ្នកនាំសារលោកបានមានប្រសាសន៍ថា៖

يقول رسول الإسلام صلى الله عليه وسلم : (إِيَّاكُمْ وَالْجُلُوْسَ بِالطُّرُقَاتِ فَقَالُوْا يَا رَسُوْلَ اللهِ مَا لَنَا مِنْ مَجَالِسِنَا بُدٌّ نَتَحَدَّثُ فِيْهَا فَقَالَ فَإِذَا أَبَيْتُمْ إِلاَّ الْمَجْلِسَ فَأُعْطُوْا الطَّرِيْقَ حَقَّهُ قَالُوْا وَمَا حَقُّ الطَّرِيْقِ يَا رَسُوْلَ اللهِ قَالَ غَضُّ الْبَصَرِ وَكَفُّ الْأَذَى وَرَدُّ السَّلَامِ وَالْأَمْرُ بِالْمَعْرُوْفِ وَالنَّهْيُ عَنِ الْمُنْكَرِ ) صحيح البخاري

មានន័យថា៖ "ចូរប្រុងប្រយ័ត្នចំពោះការអង្គុយនៅតាមចិញ្ចើមផ្លូវ ពួកគេនិយាយថា បពិត្រអ្នកនាំសាររបស់អល់ឡោះ គ្មានអ្វីចាំបាច់នោះទេ ពួកយើងគ្រាន់តែអង្គុយនិយាយគ្នាតែប៉ុណ្ណោះ។ លោកបានតបវិញថា បើសិនជាពួកអ្នកចចេសចង់តែអង្គុយនោះ ចូរគោរពសិទ្ធិផ្លូវ ពួកគេសួរថា បពិត្រអ្នកនាំសាររបស់អល់ឡោះ តើអ្វីជាសិទ្ធិរបស់ផ្លូវនោះ? លោកបានតបវិញថា កុំតាមលំឡឹងមើលគេ កុំបៀតបៀនគេ ទទួលសាឡាម ប្រើគ្នាឱ្យធ្វើល្អ និងហាមឃាត់គ្នាពីប្រការអាក្រក់»។

សត្វឃាតក៏មានសិទ្ធិរបស់វា ត្រូវចេះមេត្តា និងអាណិតអាសូរចំពោះសត្វ ជាមូលហេតុនៃការលុបលាងទោសកំហុស។ អ្នកនាំសារលោកបានមានប្រសាសន៍ថា៖

عَنْ أَبِي هُرَيْرَةَ رَضِيَ اللَّهُ عَنْهُ أَنَّ النَّبِيَّ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ قَالَ : ( بَيْنَا رَجُلٌ بِطَرِيقٍ اشْتَدَّ عَلَيْهِ الْعَطَشُ فَوَجَدَ بِئْرًا فَنَزَلَ فِيهَا فَشَرِبَ ثُمَّ خَرَجَ فَإِذَا كَلْبٌ يَلْهَثُ يَأْكُلُ الثَّرَى مِنْ الْعَطَشِ فَقَالَ الرَّجُلُ لَقَدْ بَلَغَ هَذَا الْكَلْبَ مِنْ الْعَطَشِ مِثْلُ الَّذِي كَانَ بَلَغَ مِنِّي فَنَزَلَ الْبِئْرَ فَمَلَأَ خُفَّهُ مَاءً فَسَقَى الْكَلْبَ فَشَكَرَ اللَّهُ لَهُ فَغَفَرَ لَهُ قَالُوا يَا رَسُولَ اللَّه وَإِنَّ لَنَا فِي الْبَهَائِمِ لَأَجْرًا فَقَالَ فِي كُلِّ ذَاتِ كَبِدٍ رَطْبَةٍ أَجْرٌ ) صحيح البخاري

មានន័យថា៖ «មានបុរសម្នាក់ដើរតាមផ្លូវ គេស្រេកទឹកខ្លាំង ស្រាប់តែបានប្រទះនឹងអណ្តូងទឹកមួយ បានចុះទៅក្នុងអណ្តូងនោះ ផឹកទឹកឆ្អែតរួច ឡើងចេញមកវិញ ស្រាប់តែឃើញសត្វសុនខមួយកំពុងលិតដីព្រោះស្រេកទឹកឃ្លាំងពេក។ បុរសនោះនឹកក្នុងចិត្តថាសត្វសុកខនេះពិតជាស្រេកទឹកខ្លាំងដូចខ្ញុំដែរហើយមើលទៅ។ គេក៏បានចុះទៅក្នុងអណ្តូងទឹកម្តងទៀត យកស្បែកជើងដួសទឹកពេញ ហើយដាក់ឱ្យសត្វសុនខនោះផឹក។ អល់ឡោះជាម្ចាស់ទ្រង់អរគុណចំពោះរូបគេ ហើយអភ័យទោសចំពោះគេ។ ពួកគេនិយាយថា បពិត្រអ្នកនាំសាររបស់អល់ឡោះ តើពាក់ព័ន្ធនឹងសត្វឃាតមានបុណ្យសម្រាប់ពួកយើងខ្ញុំដែរឬ? លោកតបថា ពិតណាស់ រាល់ការធ្វើល្អចំពោះសត្វមានជីវិតតែងមានបុណ្យ»។

រីឯការធ្វើបាប ចាប់ចង ឃុំឃាំងសត្វ ជាមូលហេតុនៃការចុះនរក។ អ្នកនាំសារលោកបានមានប្រសាសន៍ថា៖

يقول رسول الإسلام صلى الله عليه وسلم : ( عُذِّبَتْ امْرَأَةٌ فِي هِرَّةٍ حَبَسَتْهَا حَتَّى مَاتَتْ جُوعًا فَدَخَلَتْ فِيهَا النَّارَ قَالَ فَقَالَ وَاللَّهُ أَعْلَمُ لَا أَنْتِ أَطْعَمْتِهَا وَلَا سَقَيْتِهَا حِينَ حَبَسْتِيهَا وَلَا أَنْتِ أَرْسَلْتِهَا فَأَكَلَتْ مِنْ خَشَاشِ الْأَرْضِ ) صحيح البخاري

មានន័យថា៖ «ស្ត្រីម្នាក់ត្រូវទទួលទារុណកម្មដោយសារបានចាប់សត្វឆ្មាឃុំឃាំងធ្វើបាបរហូតដល់សត្វឆ្មានោះងាប់ ហើយត្រូវចុះនរកព្រោះតែសត្វឆ្មានោះ។ មិនឱ្យចំណីវាស៊ី មិនឱ្យទឹកវាផឹក ចាប់វាចងមិនព្រមលែងឱ្យវាទៅរកស៊ីសត្វល្អិត»។

នេះជាក្តីមេត្តារបស់ឥស្លាមចំពោះសត្វឃាត យ៉ាងណាមិញចំពោះមនុស្សលោកដែលអល់ឡោះជាម្ចាស់ទ្រង់បានលើកតម្កើង និងផ្តល់តំលៃដល់រូបគេខ្ពស់លើសពីសត្វលោកទាំងមូល។

## **សាសន៍ដទៃនិយាយអំពីឥស្លាម**

លោក ដេក រ៉េសស្លើ បាននិយាយក្នុងសៀវភៅអរិយធម៌អារ៉ាប់របស់លោកថា៖ ពិតប្រាកដ ឥស្លាម គេអាចនិយមន័យបានបីន័យទីមួយសាសនា ន័យទីពីរ រដ្ឋាភិបាល និងទីបី គឺវប្បធម៌ សរុបសង្ខេបឥស្លាមគឺជាអរិយម៌តែមួយគត់។

## ឥស្លាម និងទ្រព្យសម្បត្តិ

ទ្រព្យសម្បត្តិក្នុងឥស្លាម ជាទ្រព្យសម្បត្តិរបស់អល់ឡោះ គឺជាបញ្ញើរបស់ទ្រង់មកចំពោះមនុស្សលោក និងជាទំនួលខុសត្រូវ ត្រូវរកស៊ីដោយស្របច្បាប់ឥស្លាម ចំណាយចាយទៅវិញក៏ឱ្យស្របនឹងច្បាប់ឥស្លាម ចំណាយសម្រាប់ខ្លួន សម្រាប់អ្នកនៅក្រោមបន្ទុកដោយគ្មានការខ្ជះខ្ជាយ។ អ្នកនាំសារឥស្លាម បានមានប្រសាសន៍ថា៖

يقول رسول الإسلام صلى الله عليه وسلم : ( لَا تَزُولُ قَدَمَا عَبْدٍ يَوْمَ الْقِيَامَةِ حَتَّى يُسْأَلَ عَنْ عُمُرِهِ فِيمَا أَفْنَاهُ وَعَنْ عِلْمِهِ فِيمَ فَعَلَ وَعَنْ مَالِهِ مِنْ أَيْنَ اكْتَسَبَهُ وَفِيمَ أَنْفَقَهُ وَعَنْ جِسْمِهِ فِيمَ أَبْلَاهُ ) سنن الترمذي

មានន័យថា៖ «នៅថ្ងៃបរលោកបុគ្គលម្នាក់មិនអាចឈានជើងដើរជាដាច់ខាត លុះត្រាតែគេសួរពីអាយុជីវិតរបស់គេតើគេចំណាយអាយុជីវិតរបស់គេទៅលើអ្វី? ចំណេះដឹងរបស់គេយកធ្វើអ្វី? ទ្រព្យសម្បត្តិរកបានមកពីណា? ហើយចំណាយចាយវិញទៅផ្លូវណា? ហើយខ្លួនប្រាណគេចំណាយកម្លាំងធ្វើអ្វីខ្លះ?″។

ត្រូវបរិច្ចាគទ្រព្យសម្បត្តិក្នុងផ្លូវល្អ អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿ لَّيْسَ ٱلْبِرَّ أَن تُوَلُّوا۟ وُجُوهَكُمْ قِبَلَ ٱلْمَشْرِقِ وَٱلْمَغْرِبِ وَلَٰكِنَّ ٱلْبِرَّ مَنْ ءَامَنَ بِٱللَّهِ وَٱلْيَوْمِ ٱلْءَاخِرِ وَٱلْمَلَٰٓئِكَةِ وَٱلْكِتَٰبِ وَٱلنَّبِيِّۦنَ وَءَاتَى ٱلْمَالَ عَلَىٰ

حُبِّهِۦ ذَوِى ٱلۡقُرۡبَىٰ وَٱلۡيَتَٰمَىٰ وَٱلۡمَسَٰكِينَ وَٱبۡنَ ٱلسَّبِيلِ وَٱلسَّآئِلِينَ وَفِي ٱلرِّقَابِ ﴾ البقرة : ١٧٧

មានន័យថា៖ «ពុំមែនជាសេចក្ដីល្អទេ ដែលពួកអ្នកបែរទៅទិសខាងកើត និងទិសខាងលិច។ ក៏ប៉ុន្ដែសេចក្ដីល្អ គឺអ្នកដែលមានជំនឿចំពោះអល់ឡោះ ថ្ងៃបរលោក ពួកទេវតា គម្ពីរៗ និងពួកអ្នកនាំសារ ហើយបរិច្ចាគទ្រព្យសម្បត្តិដោយពេញចិត្ដជូនដល់សាច់ញាតិ កូនកំព្រា អ្នកទីទ័លក្រ អ្នកដើរដាច់សង្វែងតាមផ្លូវ និងការលោះទាសករ»។

## ឥស្លាម និងស្ត្រី

ឥស្លាមយល់ឃើញថា បុរស និងស្ដ្រីជាភេទពីរខុសគ្នា ម្នាក់ៗសុទ្ធតែមានសិទ្ធិ និងមានកាតព្វកិច្ចរៀងៗខ្លួន។ ម្យ៉ាងទៀតឥស្លាមយល់ឃើញថា ការលើកតម្កើង និងគោរពសិទ្ធិស្ដ្រីជាសញ្ញាសម្គាល់សម្រាប់បុគ្គលដែលត្រឹមត្រូវពេញលក្ខណៈ ប្រសើរថ្លៃថ្លា។ អ្នកនាំសារមូហាំម៉ាត់ បានមានប្រសាសន៍ថា៖

يقول صلى الله عليه وسلم: ( خِيَارُكُمْ خِيَارُكُمْ لِنِسَائِهِمْ ) صحيح ابن حبان

មានន័យថា៖ «អ្នកមានជំនឿដែលប្រសើរជាងគេក្នុងចំណោមពួកអ្នក គឺអ្នកដែលធ្វើល្អប្រសើរជាងគេចំពោះស្ដ្រី»។

ស្ដ្រីមានអាទិភាពជាងបុរសក្នុងការទទួលនូវភាពកតញ្ញូតាធម៌ ការរាប់-អាន និងការធ្វើអំពើល្អ អ្នកនាំសារមូហាំម៉ាត់បានប្រសាសន៍ទៅកាន់បុរសម្នាក់ដែលសួរថា៖

يقول رسول الإسلام للرجل الذي سأله مَنْ أَحَقُّ النَّاسِ بِحُسْنِ صَحَابَتِي قَالَ أُمُّكَ قَالَ ثُمَّ مَنْ قَالَ ثُمَّ أُمُّكَ قَالَ ثُمَّ مَنْ قَالَ ثُمَّ أُمُّكَ قَالَ ثُمَّ مَنْ قَالَ ثُمَّ أَبُوكَ صحيح البخاري

មានន័យថា៖ «អ្នកណាគួរគាត់ធ្វើល្អជាងគេ? លោកបានតបវិញថា៖ ម្ដាយរបស់អ្នក។ បន្ទាប់មក នរណាទៀត? លោកឆ្លើយថា ម្ដាយរបស់អ្នក។ បុរសនោះសួរទៀតថា នរណាទៀត? លោកឆ្លើយថាម្ដាយរបស់អ្នក។ បន្ទាប់មក នរណាទៀត? លោកឆ្លើយថា ឪពុករបស់អ្នក។

ឋានៈស្ត្រីក្នុងឥស្លាមដូចអ្នកនាំសារលោកបានប្រាប់ថា៖

كما أخبر عنها رسول الإسلام بقوله : ( إِنَّمَا النِّسَاءُ شَقَائِقُ الرِّجَالِ ) سنن أبي داود

មានន័យថា៖ «ពិតប្រាកដ ស្ត្រីជាបងប្អូនបង្កើតរបស់បុរស»។

ឥស្លាមចាត់ទុកការលើកតម្កើងស្ត្រីជាអត្តសញ្ញាណបុគ្គលដែលត្រឹមត្រូវពេញលក្ខណៈល្អប្រសើរថ្លៃថ្លា ដូចអ្នកនាំសារលោកបានមានប្រសាសន៍ថា៖

يقول صلى الله عليه وسلم: ( أَكْمَلُ الْمُؤْمِنِيْنَ إِيْمَانًا أَحْسَنُهُمْ خُلُقًا وَخِيَارُكُمْ خِيَارُكُمْ لِنِسَائِهِمْ) صحيح ابن حبان

មានន័យថា៖ "អ្នកមានជំនឿដែលពេញលក្ខណៈជាងគេ គឺអ្នកមានជំនឿដែលមានសីលធម៌ល្អជាងគេ ហើយអ្នកមានជំនឿដែលប្រសើរជាងគេក្នុងចំណោមពួកអ្នក គឺអ្នកដែលធ្វើល្អចំពោះស្ត្រីបានប្រសើរជាងគេ »។

* ស្ត្រីដូចជាបុរសក្នុងនាមជាមនុស្សជាតិ ពុំមែនជាប្រភពនៃកំហុស ហើយក៏ពុំមែនជាមូលហេតុដែលធ្វើឱ្យអាដាំចេញពីឋានសួគ៌ដែរ។
* ស្ត្រីដូចជាបុរសក្នុងការដាក់បន្ទុករបស់ច្បាប់សាសនា គេដាក់កាតព្វកិច្ចលើស្ត្រីដូចបុរសដែរ។
* ស្ត្រីដូចជាបុរស ស្ត្រីមានបុគ្គលិកលក្ខណៈឯករាជ្យ ពុំបានបាត់បង់ឈ្មោះខ្លួនឯង និងឈ្មោះត្រកូលដោយគ្រាន់តែរៀបអាពាហ៍ពិពាហ៍ និងរួមរស់ជាខ្លួនប្រាណតែមួយជាមួយនឹងប្តី។
* ស្ត្រីដូចជាបុរសក្នុងការទទួលផលបុណ្យ និងទទួលទោសទាំងលោកីយ៍ និងបរលោក។
* ស្ត្រីដូចជាបុរសក្នុងការរក្សាកិត្តិយស និងតម្លៃរបស់ខ្លួន។
* ស្ត្រីដូចជាបុរស ស្ត្រីមានសិទ្ធិទទួលទ្រព្យមត៌កដូចបុរសដែរ។
* ស្ត្រីដូចជាបុរសក្នុងភាពមានកាយសម្បទាពេញលេញ និងសេរីភាពក្នុងការចាត់ចែងទ្រព្យសម្បត្តិ។
* ស្ត្រីដូចជាបុរសក្នុងការមានភារកិច្ចទទួលខុសត្រូវចំពោះការកែប្រែសង្គមឱ្យល្អប្រសើរ។
* ស្ត្រីដូចជាបុរសក្នុងការមានសិទ្ធិទទួលការសិក្សាអប់រំ។
* ស្ត្រីដូចជាបុរសក្នុងការមានសិទ្ធិទទួលការអប់រំល្អ និងក្លាយជាពលរដ្ឋល្អ។

## ឥស្លាម និងផ្លូវភេទ

ពិតប្រាកដ ឥស្លាមមើលឃើញថា សភាវគតិផ្លូវភេទជាកម្លាំងចលករចាំបាច់មួយដែលត្រូវបំពេញតាមតម្រូវការ ពុំត្រូវរាំងខ្ទប់ ហើយក៏ពុំមែនជារឿងអាក្រក់ដែលត្រូវជៀសវាងនោះដែរ។ យោងតាមក្រមសីលធម៌ឥស្លាមបានជានាការបំពេញចំណង់តណ្ហានេះដោយវិធីសាស្ត្រមួយត្រឹមត្រូវមានសុវត្ថិភាព ជៀសវាងពីភាពព្រៃផ្សៃ និងតណ្ហាពុះកញ្ជ្រោល។ ឥស្លាមបានចាត់ទុកអាពាហ៍ពិពាហ៍ជាច្រកចេញស្របច្បាប់ដើម្បីរំលត់នូវតណ្ហាដែលជាសភាវគតិនេះ។

គោលដៅនៃអាពាហ៍ពិពាហ៍ក្នុងឥស្លាមគឺដើម្បីភាពស្កប់ស្កល់ភាពហ្នឹងហ្នរផ្លូវចិត្ត និងមនោសញ្ចេតនាប្ដីប្រពន្ធ។ អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿ وَمِنْ ءَايَـٰتِهِۦٓ أَنْ خَلَقَ لَكُم مِّنْ أَنفُسِكُمْ أَزْوَٰجًا لِّتَسْكُنُوٓا۟ إِلَيْهَا وَجَعَلَ بَيْنَكُم مَّوَدَّةً وَرَحْمَةً ۚ إِنَّ فِى ذَٰلِكَ لَـَٔايَـٰتٍ لِّقَوْمٍ يَتَفَكَّرُونَ ﴿٢١﴾ ﴾

الروم : ٢١

មានន័យថា៖ «អំពីនិមិត្តសញ្ញារបស់ទ្រង់គឺទ្រង់បង្កើតសម្រាប់ពួកអ្នកនូវគូស្រករចេញពីខ្លួនរបស់ពួកអ្នក ដើម្បីឱ្យពួកអ្នករួមរស់ស្កប់ស្កល់ជាមួយនឹងគេ ទ្រង់ធ្វើឱ្យកើតមានក្ដីស្រលាញ់ អាណិតអាសូររវាងពួកអ្នក។ ពិតប្រាកដក្នុងរឿងនេះជានិមិត្តសញ្ញាសម្រាប់ពួកអ្នកដែលចេះគិតពិចារណា»។

គោលបំណងនៃអាពាហ៍ពិពាហ៍គឺរក្សាការពារប្ដីប្រពន្ធទាំងពីរនាក់ពីការធ្លាក់ ឬរអិលចូលក្នុងអំពើអបាយមុខ ឋោកទាប។ ដូចអល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿هُنَّ لِبَاسٌ لَّكُمْ وَأَنتُمْ لِبَاسٌ لَّهُنَّ﴾ البقرة : ١٨٧

មានន័យថា៖ «ពួកគេជាសម្លៀកបំពាក់គ្របដណ្ដប់ពួកអ្នក ហើយពួកអ្នកជាសម្លៀកបំពាក់គ្របដណ្ដប់ពួកគេ»។

ដើម្បីរក្សាសុវត្ថិភាពបុគ្គល និងសង្គម ឥស្លាមបានហាមរាល់កត្តាទាំងឡាយដែលជាមូលហេតុបង្កឱ្យកើតតណ្ហាផ្លូវភេទ ខ្លាចក្រែងធ្លាក់ចូលក្នុងអំពើពេស្យាចារ្យ ផិតក្បត់ ឬរួមភេទដូចគ្នា ទោះដោយការយល់ព្រម ឬជាការចាប់រំលោភ ហើយជាលទ្ធផលអំពើទាំងនេះបានបន្សល់នូវកូនឥតខណ្ឌស្លា គ្មានឪពុកម្ដាយពិតប្រាកដ គ្មានជំបូលពិតប្រាកដ ដើម្បីចិញ្ចឹមបីបាច់ ថែរក្សា និងអប់រំពួកគេឱ្យបរិសុទ្ធស្អាតស្អំ និងមានសីលធម៌ល្អ។ ដូច្នេះ កូនទាំងនេះ នឹងធំឡើងក្លាយជាវណ្ណៈសង្គមមួយពោរពេញដោយកំហឹងចំពោះសង្គមរបស់ខ្លួន រីករាលដាលជំងឺឆ្លង ជំងឺគ្រោះថ្នាក់ផ្សេងៗដែលផលប៉ះពាល់របស់វា ពុំមែនមានចំពោះតែពួកអ្នកប្រព្រឹត្តប៉ុណ្ណោះទេ តែអាចគ្របដណ្ដប់លើសង្គមទាំងមូល។ អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿وَلَا تَقْرَبُوا۟ ٱلزِّنَىٰٓ ۖ إِنَّهُۥ كَانَ فَٰحِشَةً وَسَآءَ سَبِيلًا ﴿٣٢﴾﴾ الإسراء : ٣٢

មានន័យថា៖ «ចូរកុំទៅក្បែរអំពើផិតក្បត់ ពិតប្រាកដ វាជាអំពើអបាយមុខ ហើយជាផ្លូវដ៏អាក្រក់ជាទីបំផុត»។

## ឥស្លាម និងអ្នកមិនមែនមូស្លីម

ពួកអ្នកមិនមែនមូស្លីមដែលជាប់កុងត្រាក្នុងប្រទេសឥស្លាមត្រូវបានការពារអាយុជីវិត ទ្រព្យសម្បត្តិ កិត្តិយស គ្មានការរំលោភបំពានបង្កហិង្សាចំពោះពួកគេ មិនត្រូវរំលោភសិទ្ធិឬរើសអើងចំពោះពួកគេ។ អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿لَّا يَنْهَىٰكُمُ ٱللَّهُ عَنِ ٱلَّذِينَ لَمْ يُقَٰتِلُوكُمْ فِى ٱلدِّينِ وَلَمْ يُخْرِجُوكُم مِّن دِيَٰرِكُمْ أَن تَبَرُّوهُمْ وَتُقْسِطُوٓا۟ إِلَيْهِمْ ۚ إِنَّ ٱللَّهَ يُحِبُّ ٱلْمُقْسِطِينَ ﴿٨﴾﴾ سورة الممتحنة : ٨

មានន័យថា៖ «អល់ឡោះជាម្ចាស់ទ្រង់មិនហាមឃាត់ពួកអ្នកពីពួកដែលមិនបានច្បាំងប្រយុទ្ធជាមួយនិងពួកអ្នកក្នុងរឿងសាសនា ហើយពួកគេពុំបានដេញជម្លៀសពួកអ្នកចេញពីស្រុកភូមិ។ ចូរធ្វើល្អ និងផ្តល់ភាពយុត្តិធម៌ដល់ពួកគេ ពិតប្រាកដ អល់ឡោះទ្រង់សព្វព្រះទ័យចំពោះពួកអ្នកដែលប្រកាន់នូវភាពយុត្តិធម៌»។

អ្នកនាំសារមូហាំម៉ាត់លោកបានមានប្រសាសន៍ថា៖

يقول رسول الإسلام صلى الله عليه وسلم : ( أَلاَ مَنْ ظَلَمَ مُعَاهِدًا أَوْ انْتَقَصَهُ أَوْ كَلَّفَهُ فَوْقَ طَاقَتِهِ أَوْ أَخَذَ مِنْهُ شَيْئًا بِغَيْرِ طِيبِ نَفْسٍ فَأَنَا حَجِيجُهُ يَوْمَ الْقِيَامَةِ وَأَشَارَ رَسُوْلُ اللهِ صلى الله عليه وسلم بِأُصْبُعِهِ إِلَى صَدْرِهِ أَلاَ وَمَنْ قَتَلَ مُعَاهِدًا لَهُ ذِمَّةُ اللهِ وَذِمَّةُ رَسُوْلِهِ حَرَّمَ اللهُ عَلَيْهِ رِيحَ الْجَنَّةِ وَإِنَّ رِيْحَهَا لَتُوْجَدُ مِنْ مَسِيْرَةِ سَبْعِيْنَ خَرِيْفًا) سنن البيهقي.

មានន័យថា៖ «ពិតណាស់ អ្នកដែលរំលោភបំពានលើអ្នកមិនមែនមូស្លីមដែលជាប់កិច្ចសន្យា ប្រមាថមើលងាយគេ បង្ខំឱ្យធ្វើការហួសកម្លាំង ឬ

ដកហូតយកអ្វីដោយបង្ខំ ដូច្នេះ ខ្ញុំជាអ្នកប្តឹងតវ៉ាឱ្យគេនៅថ្ងៃបរលោក។ អ្នកនាំសារបានយកម្រាមដៃចង្អុលទ្រូង ហើយនិយាយ ពិតណាស់ នរណាសម្លាប់អ្នកដែលជាប់កិច្ចសន្យា គេមានការជានារបស់អល់ឡោះ និងអ្នកនាំសាររបស់ទ្រង់ អល់ឡោះជាម្ចាស់នឹងហាមអ្នកនោះពីក្លិនពិដោរឋានសួគ៌ គេនឹងទទួលបានក្លិនវាក្នុងចម្ងាយរយៈពេល៧០ឆ្នាំ» ។

## ឥស្លាម និងការគោរពសិទ្ធិសាសនាដទៃ

ពិតប្រាកដ ឥស្លាមតម្រូវឱ្យសាសនិករបស់ខ្លួនជឿចំពោះសារផ្សេងៗទៀតដែលចុះពីលើមេឃ និងជឿចំពោះពួកអ្នកនាំសារស្រលាញ់ លើកតម្កើង និងគោរពពួកគាត់។ អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿ وَتِلْكَ حُجَّتُنَآ ءَاتَيْنَٰهَآ إِبْرَٰهِيمَ عَلَىٰ قَوْمِهِۦ ۚ نَرْفَعُ دَرَجَٰتٍ مَّن نَّشَآءُ ۗ إِنَّ رَبَّكَ حَكِيمٌ عَلِيمٌ ﴿٨٣﴾ وَوَهَبْنَا لَهُۥٓ إِسْحَٰقَ وَيَعْقُوبَ ۚ كُلًّا هَدَيْنَا ۚ وَنُوحًا هَدَيْنَا مِن قَبْلُ ۖ وَمِن ذُرِّيَّتِهِۦ دَاوُۥدَ وَسُلَيْمَٰنَ وَأَيُّوبَ وَيُوسُفَ وَمُوسَىٰ وَهَٰرُونَ ۚ وَكَذَٰلِكَ نَجْزِى ٱلْمُحْسِنِينَ ﴿٨٤﴾ وَزَكَرِيَّا وَيَحْيَىٰ وَعِيسَىٰ وَإِلْيَاسَ ۖ كُلٌّ مِّنَ ٱلصَّٰلِحِينَ ﴿٨٥﴾ وَإِسْمَٰعِيلَ وَٱلْيَسَعَ وَيُونُسَ وَلُوطًا ۚ وَكُلًّا فَضَّلْنَا عَلَى ٱلْعَٰلَمِينَ ﴿٨٦﴾ وَمِنْ ءَابَآئِهِمْ وَذُرِّيَّٰتِهِمْ وَإِخْوَٰنِهِمْ ۖ وَٱجْتَبَيْنَٰهُمْ وَهَدَيْنَٰهُمْ إِلَىٰ صِرَٰطٍ مُّسْتَقِيمٍ ﴿٨٧﴾ ﴾ سورة الأنعام : ٨٣-٨٧

មានន័យថា៖ «នោះគឺជាភស្តុតាងរបស់យើង ដែលយើងបានប្រទានជូនអ៊ីព្រហ៊ីមក្នុងចំណោមសាសន៍របស់គេ យើងលើកឋានៈអ្នកណា

ដែលយើងសព្វព្រះទ័យ។ ពិតប្រាកដ ព្រះជាម្ចាស់របស់ឯងទ្រង់មហាមានគតិបណ្ឌិត និងមហាដឹង។ យើងបានប្រទានចំពោះគេនូវកូនឈ្មោះ អ៊ីស្ហាក និងចៅឈ្មោះយ៉ាក់កូប ពួកគេទាំងពីរនាក់យើងបានចង្អុលបង្ហាញផ្លូវ ហើយណួហ យើងបានចង្អុលបង្ហាញគេមុននេះ។ កូនចៅវង្សត្រកូលអ៊ីព្រហ៊ីម មានដាវូត ស៊ូឡៃម៉ាន អាយូប យូសុហ្វ មូសា ហារូន បែបនេះឯង យើងតបស្នងចំពោះពួកអ្នកធ្វើអំពើកុសលធម៌។ ហ្សាការីយ៉ា និងយ៉ះយ៉ា ហើយនិងអ៊ិលយ៉ើស សុទ្ធតែពួកអ្នកមានកុសលធម៌។ អ៊ិស្មាអ៊ីល អិលយ៉ាសាក់ យូណុស និងលូត ពួកគេទាំងអស់យើងបានតម្កើងខ្ពស់អស់សកលលោកទាំងមូល។ ក្នុងចំណោមជីដូនជីតា កូនចៅ បងប្អូនរបស់ពួកគេ យើងបានជ្រើសរើសពួកគេ និងចង្អុលបង្ហាញផ្លូវត្រង់ដល់ពួកគេ» ។

* គម្ពីរអាល់គួរអាននិយាយដូចម្តេចចំពោះមូសា :

អល់ឡោះជាម្ចាស់បានមានព្រះបន្ទូលថា :

﴿وَٱذۡكُرۡ فِي ٱلۡكِتَٰبِ مُوسَىٰٓۚ إِنَّهُۥ كَانَ مُخۡلَصٗا وَكَانَ رَسُولٗا نَّبِيّٗا ٥١﴾
مريم : ٥١

មានន័យថា : «ចូររំឭកចុះក្នុងគម្ពីរអាល់គួរអានពីមូសា ពិតប្រាកដគេជាបុគ្គលដែលមានចិត្តសទ្ធាជ្រះថ្លាជាអ្នកនាំសារនិងជាព្យាការី» ។

* តើគម្ពីរអាល់គួរអាននិយាយដូចម្តេចអំពី អ៊ីសា កូនប្រុសរបស់នាងម៉ារី៖

អល់ឡោះជាម្ចាស់បានមានព្រះបន្ទូលថា៖

﴿وَإِذۡ قَالَتِ ٱلۡمَلَٰٓئِكَةُ يَٰمَرۡيَمُ إِنَّ ٱللَّهَ ٱصۡطَفَىٰكِ وَطَهَّرَكِ وَٱصۡطَفَىٰكِ عَلَىٰ نِسَآءِ ٱلۡعَٰلَمِينَ ﴿٤٢﴾﴾ آل عمران : ٤٢

មានន័យថា៖ «ចូររំឭកចុះខណៈដែលទេវតាបាននិយាយថា នែនាង ម៉ារី ពិតប្រាកដ អល់ឡោះជាម្ចាស់បានជ្រើសរើសនាង ផ្តល់ភាពស្អាតស្អំដល់នាង ហើយបានជ្រើសរើសនាងឱ្យមានឋានៈខ្ពស់លើសស្ត្រីក្នុងលោកទាំងមូល»។

អល់ឡោះជាម្ចាស់បានមានព្រះបន្ទូលថា៖

﴿إِنَّ مَثَلَ عِيسَىٰ عِندَ ٱللَّهِ كَمَثَلِ ءَادَمَۖ خَلَقَهُۥ مِن تُرَابٖ ثُمَّ قَالَ لَهُۥ كُن فَيَكُونُ ﴿٥٩﴾﴾ آل عمران : ٥٩

មានន័យថា៖ «ពិតប្រាកដ ប្រៀបធៀបអ៊ីសាចំពោះអល់ឡោះដូចជាអាដាំទ្រង់បង្កើតគេពីដី បន្ទាប់មកទ្រង់បានមានព្រះបន្ទូលទៅកាន់គេថា ចូរកើតចុះ វាក៏កើតឡើង» ។

អល់ឡោះជាម្ចាស់បានមានព្រះបន្ទូលថា៖

﴿يَٰٓأَهۡلَ ٱلۡكِتَٰبِ لَا تَغۡلُواْ فِي دِينِكُمۡ وَلَا تَقُولُواْ عَلَى ٱللَّهِ إِلَّا ٱلۡحَقَّۚ إِنَّمَا ٱلۡمَسِيحُ عِيسَى ٱبۡنُ مَرۡيَمَ رَسُولُ ٱللَّهِ وَكَلِمَتُهُۥٓ أَلۡقَىٰهَآ إِلَىٰ مَرۡيَمَ وَرُوحٞ مِّنۡهُۖ فَـَٔامِنُواْ بِٱللَّهِ وَرُسُلِهِۦۖ وَلَا تَقُولُواْ ثَلَٰثَةٌۚ ٱنتَهُواْ خَيۡرٗا لَّكُمۡۚ إِنَّمَا ٱللَّهُ إِلَٰهٞ وَٰحِدٞۖ سُبۡحَٰنَهُۥٓ أَن يَكُونَ لَهُۥ وَلَدٞۘ لَّهُۥ مَا فِي ٱلسَّمَٰوَٰتِ وَمَا فِي ٱلۡأَرۡضِۗ وَكَفَىٰ بِٱللَّهِ وَكِيلٗا ﴿١٧١﴾﴾ النساء : ١٧١

មានន័យថា៖ "នែពួកម្ចាស់គម្ពីរ ចូរកុំប្រកាន់ជ្រុលពេកក្នុងសាសនារបស់ពួកអ្នក ហើយកុំនិយាយប្រឌិតទៅលើអល់ឡោះ លើកលែងតែពាក្យពិត។ ពិតប្រាកដ មេស៊ី (អ៊ីសា) កូននាងម៉ារី ជាអ្នកនាំសាររបស់ អល់ឡោះ ហើយពាក្យបន្ទូលរបស់ទ្រង់ដែលបានត្រាស់ទៅកាន់នាងម៉ារី និងវិញ្ញាណបរិសុទ្ធដែលមកអំពីទ្រង់។ ចូរមានជំនឿចុះចំពោះអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់ កុំនិយាយថាព្រះមានបីអង្គ ចូរបញ្ឈប់ វាប្រសើរសម្រាប់ពួកអ្នក តាមពិតអល់ឡោះជាព្រះតែមួយដ៏មហាពិសិដ្ឋទ្រង់ឯណាមានកូន។ សម្រាប់ទ្រង់គឺអ្វីៗដែលនៅលើមេឃ និងនៅលើដី ហើយមានអល់ឡោះជាអ្នកទទួលខុសត្រូវគឺគ្រប់គ្រាន់ »។

## ឥស្លាម និងសង្គ្រាម

សង្គ្រាមនៅក្នុងឥស្លាម ហៅថា (ជីហាត) ការតស៊ូ។ ការតស៊ូក្នុងឥស្លាមតាមអត្ថន័យទូទៅគឺការជំនះចិត្តខ្លួនឯង បង្ខំឱ្យខ្លួនឯងបោះបង់អំពើគេហាមឃាត់ និងអនុវត្តនូវប្រការដែលគេបង្គាប់ប្រើតាមលទ្ធភាពដែលអាចធ្វើបានដើម្បីស្វែងរកការសព្វព្រះទ័យរបស់អល់ឡោះ។ អ្នកនាំសារមូហាំម៉ាត់លោកបានមានប្រសាសន៍ថា៖

عن فضالة بن عبيدرضي الله عنه كان يحدث عن رسول الله صلى الله عليه وسلم قال : ( اَلْمُجَاهِدُ مَنْ جَاهَدَ نَفْسَهُ لِلَّهِ عَزَّ وَجَلَّ ) صحيح ابن حبان

មានន័យថា៖ «អ្នកដែលតស៊ូគឺអ្នកដែលស៊ូជំនះនឹងខ្លួនឯង ដើម្បីអល់ឡោះជាម្ចាស់»។

- ការផ្សព្វផ្សាយឥស្លាមដល់អ្នកមិនមែនឥស្លាមដោយការអំពាវនាវស្រាយបំភ្លឺ និងផ្ដល់អំណះអំណាងក្នុងគម្ពីរអាល់គួរអាន ហើយការអត់ធ្មត់ចំពោះការជំទាស់បដិសេធរបស់ពួកគេក៏ជាការតស៊ូ។ អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿وَلَوْ شِئْنَا لَبَعَثْنَا فِى كُلِّ قَرْيَةٍ نَّذِيرًا ﴿٥١﴾ فَلَا تُطِعِ ٱلْكَـٰفِرِينَ وَجَـٰهِدْهُم بِهِۦ جِهَادًا كَبِيرًا ﴿٥٢﴾﴾ الفرقان : ٥١-٥٢

មានន័យថា៖ «បើសិនជាយើងសព្វព្រះទ័យ យើងនឹងបញ្ជូនទៅកាន់គ្រប់ភូមិនីមួយៗនូវអ្នកដាស់តឿនម្នាក់ ចូរកុំស្ដាប់ពួកអ្នកគ្មានជំនឿ ហើយចូរតស៊ូឱ្យបានស្វិតស្វាញជាមួយនឹងពួកគេ» ។

- ការបង្គាប់ប្រើឱ្យធ្វើល្អ និងហាមឃាត់គ្នាពីអំពើអាក្រក់ ក៏ជាការតស៊ូ ជាផ្លូវរបស់ពួកអ្នកនាំសារ ពួកអ្នកដើរតាមពួកអ្នកនាំសារជំនាន់ក្រោយ។ អ្នកនាំសារមូហាំម៉ាត់បានមានប្រសាសន៍ថា៖

عن عبدالله بن مسعود أن رَسُولَ اللَّهِ صلى الله عليه وسلم يقول : (ما من نَبِيٍّ بَعَثَهُ الله فِي أُمَّةٍ قَبْلِي إلا كان له من أُمَّتِهِ حَوَارِيُّونَ وَأَصْحَابٌ يَأْخُذُونَ بِسُنَّتِهِ وَيَقْتَدُونَ بِأَمْرِهِ ثُمَّ إِنَّهَا تَخْلُفُ من بَعْدِهِمْ خُلُوفٌ يَقُولُونَ مالا يَفْعَلُونَ وَيَفْعَلُونَ مالا يُؤْمَرُونَ فَمَنْ جَاهَدَهُمْ بيده فَهُوَ مُؤْمِنٌ وَمَنْ جَاهَدَهُمْ بِلِسَانِهِ فَهُوَ مُؤْمِنٌ وَمَنْ جَاهَدَهُمْ بِقَلْبِهِ فَهُوَ مُؤْمِنٌ وَلَيْسَ وَرَاءَ ذلك من الْإِيمَانِ حَبَّةُ خَرْدَلٍ) *صحيح مسلم*

មានន័យថា៖ "គ្មានអ្នកនាំសារណាម្នាក់ ដែលអល់ឡោះជាម្ចាស់បានបញ្ជូនគាត់មកនៅសម័យមុនខ្ញុំ លើកលែងតែក្នុងចំណោមសាសន៍របស់ពួកគាត់មានពួកសហការី និងពួកអ្នកដែលប្រកាន់តាមផ្លូវរបស់គាត់ អនុវត្តតាមការបង្គាប់របស់គាត់ បន្ទាប់មកពួកអ្នកបន្តវេនជំនាន់

ក្រោយ នាំគ្នានិយាយពីអ្វីដែលខ្លួនមិនធ្វើ ហើយនាំគ្នាធ្វើអ្វីដែលគេមិនប្រើ នរណាតស៊ូជាមួយពួកគេនឹងដៃគេជាអ្នកមានជំនឿ នរណាតស៊ូជាមួយពួកគេនឹងពាក្យសំដីគេជាអ្នកមានជំនឿ នរណាតស៊ូជាមួយពួកគេនឹងចិត្តគេជាអ្នកមានជំនឿ ហើយក្រៅពីនេះគ្មានអ្វីហៅថាជំនឿសូម្បីប៉ុនគ្រាប់ស្ពៃ» ។

- ការធ្វើល្អចំពោះមនុស្សលោក ពុំត្រូវបៀតបៀនគេ ផ្តល់ភាពសប្បាយរីករាយដល់ពួកគេ អត់ធ្មត់ចំពោះរាល់ការបៀតបៀនរបស់ពួកគេ ក៏ជាការតស៊ូ។ អ្នកនាំសារមូហាំម៉ាត់បានមានប្រសាសន៍ថា៖

عن أبي هريرة رضي الله عنه قال قال رسول الله صلى الله عليه وسلم :
(السَّاعِي على الْأَرْمَلَةِ وَالْمِسْكِينِ كَالْمُجَاهِدِ في سَبِيلِ اللَّهِ أو الْقَائِمِ اللَّيْلَ الصَّائِمِ النَّهَارَ) صحيح البخاري

មានន័យថា៖ «អ្នកស្វះស្វែងជួយដល់ស្ត្រីមេម៉ាយនិងអ្នកក្រតោក**យ៉ាក**ប្រៀបដូចជាអ្នកតស៊ូច្បាំងក្នុងផ្លូវអល់ឡោះ ឬដូចអ្នកដែលងើបថ្វាយបង្គំពេលយប់ ហើយបួសពេលថ្ងៃ» ។

- ចេញដំណើរស្វែងរកចំណេះវិជ្ជាក៏ជាការតស៊ូ។ អ្នកនាំសារលោកបានមានប្រសាសន៍ថា៖

عن أنس بن مالك رضي الله عنه قال قال رسول الله صلى الله عليه وسلم
:(مَنْ خَرَجَ فِيْ طَلَبِ الْعِلْمِ كَانَ فِيْ سَبِيْلِ اللهِ حَتَّى يَرْجِعَ ) سنن الترمذي

មានន័យថា៖ «នរណាចេញស្វែងរកចំណេះវិជ្ជាគឺគេកំពុងឋិតក្នុងផ្លូវអល់ឡោះរហូតដល់គេត្រលប់មកវិញ» ។

- ការបង្រៀនចំណេះដឹងក៏ជាការតស៊ូ។ អ្នកនាំសារលោកបានមានប្រសាសន៍ថា៖

عن أبي هريرة رضي الله عنه قال قال رسول الله صلى الله عليه وسلم : (من جاء مَسْجِدِي هذا لم يَأْتِهِ إلا لِخَيْرٍ يَتَعَلَّمُهُ أو يُعَلِّمُهُ فَهُوَ بِمَنْزِلَةِ الْمُجَاهِدِ فِي سَبِيلِ اللَّهِ وَمَنْ جاء لِغَيْرِ ذلك فَهُوَ بِمَنْزِلَةِ الرَّجُلِ يَنْظُرُ إلى مَتَاعِ غَيْرِهِ) ابن ماجه

មានន័យថា៖ «នរណាមកវិហាររបស់ខ្ញុំ មកគ្មានបំណងអ្វីក្រៅពីបំណងល្អ មករៀន ឬមកបង្រៀន គឺគេមានឋានៈស្មើនឹងអ្នកតស៊ូច្បាំងក្នុងផ្លូវអល់ឡោះ ហើយនរណាមកក្នុងបំណងផ្សេងគេប្រៀបដូចនឹងបុរសម្នាក់ដែលឈរមើលទ្រព្យសម្បត្តិអ្នកដទៃ» ។

និយាយពាក្យពិតក៏ជាការតស៊ូ។ អ្នកនាំសារលោក បានមានប្រសាសន៍ថា៖

عن أبي سعيد الخدري رضي الله عنه قال قال رسول الله صلى الله عليه وسلم : (أَفْضَلُ الْجِهَادِ كَلِمَةُ عَدْلٍ عِنْدَ سُلْطَانٍ جَائِرٍ أَوْ أَمِيرٍ جَائِرٍ ) سنن أبي داود

មានន័យថា៖ «ការតស៊ូដ៏ប្រសើរបំផុត គឺការនិយាយពាក្យយុត្តិធម៌នៅចំពោះស្តេចពាល ឬមេដឹកនាំផ្តាច់ការ» ។

- ការកតញ្ញូចំពោះឪពុកម្តាយក៏ជាការតស៊ូ មានបុរសម្នាក់បានមកជួបនឹងអ្នកនាំសារមកសុំអនុញ្ញាតពីលោកចង់ចេញទៅច្បាំង។ លោកបានសួរថា៖

عن عبد الله بن عمرو رضي الله عنهما قال جَاءَ رَجُلٌ إِلَىَ النَّبِيِّ صلى الله عليه وسلم فَاسْتَأْذَنَهُ فِي الْجِهَادِ فَقَالَ:(أَحَيٌّ وَالِدَاكَ) . قال نَعَمْ قال (فَفِيْهِمَا فَجَاهِدْ ) صحيح البخاري

មានន័យថា៖ «តើឪពុកម្ដាយរបស់អ្នកនៅរស់ទេ? គាត់ថា បាទ។ លោកប្រាប់ថា ចូរតស៊ូជាមួយឪពុកម្ដាយទាំងពីររបស់អ្នកចុះ» ។

- ការយោគយល់ក្នុងការលក់ដូរ សម្រួលដល់សេចក្ដីត្រូវការរបស់មនុស្ស មិនតម្លើងថ្លៃចំពោះទំនិញណាដែលមនុស្សត្រូវការច្រើន ឬមិនទិញផ្ដាច់មុខ ក៏ជាការតស៊ូ។ ពិតប្រាកដណាស់ អ្នកនាំសារលោកបានជួបបុរសម្នាក់នៅផ្សារកំពុងលក់ចំណីអាហារដែលមានតម្លៃទាបជាងតម្លៃទីផ្សារ។ លោកបានមានប្រសាសន៍ថា៖

عن أليسع بن المغيرة قال مَرَّ رَسُوْلُ اللهِ صلى الله عليه و سلم بِرَجُلٍ بِالسُّوْقِ يَبِيْعُ طَعَامًا بِسِعْرٍ هُوَ أَرْخَصُ مِنْ سِعْرِ السُّوْقِ فَقَالَ : (تَبِيْعُ فِيْ سُوْقِنَا بِسِعْرٍ هُوَ أَرْخَصُ مِنْ سِعْرِنَا قَالَ :نَعَمْ قَالَ : صَبْرًا وَاحْتِسَابًا قَالَ : نَعَمْ قَالَ : أَبْشِرْ فَإِنَّ الْجَالِبَ إِلَى سُوْقِنَا كَالْمُجَاهِدِ فِيْ سَبِيْلِ اللهِ وَ الْمُحْتَكِرُ فِيْ سُوْقِنَا كَالْمُلْحِدِ فِيْ كِتَابِ اللهِ) المستدرك على الصحيحين

មានន័យថា៖ «តើឯងលក់ក្នុងផ្សារយើងក្នុងតម្លៃទាបជាងតម្លៃទីផ្សាររបស់យើងមែនទេ ។ បុរសនោះឆ្លើយថា បាទ។ លោកថា តើឯងអត់ធ្មត់ និងប្រាថ្នាផលបុណ្យពីអល់ឡោះជាម្ចាស់ឬ? បុរសនោះឆ្លើយថា បាទ។ លោកប្រសាសន៍ថា៖ ចូរទទួលដំណឹងល្អចុះ អ្នកដែលនាំផលប្រយោជន៍មកកាន់ផ្សាររបស់យើង ដូចជាពួកអ្នកតស៊ូចម្បាំងក្នុងផ្លូវអល់ឡោះ ហើយអ្នករកស៊ីផ្ដាច់មុខក្នុងផ្សាររបស់យើងដូចជាពួកអ្នកគ្មានជំនឿក្នុងគម្ពីរអល់ឡោះ» ។

- មានទំនុកចិត្ត មិនត្រូវក្បត់ ហើយរក្សាអ្វីដែលគេបានផ្តល់ទំនុកចិត្តនៃការងារអ្វីមួយសម្រាប់បុគ្គល ឬសង្គមក៏ជាការតស៊ូ។ អ្នកនាំសារលោកបានមានប្រសាសន៍ថា៖

عن عبد الرحمن بن حميد عن أبيه عن جده قال قال رسول الله صلى الله عليه وسلم : (اَلْعَامِلُ إِذَا اسْتُعْمِلَ فَأَخَذَ الحَقَّ وَأَعْطَى الحَقَّ كَالْمُجَاهِدِ فِيْ سَبِيْلِ اللهِ حَتَّى يَرْجِعَ إِلَى بَيْتِهِ ) المعجم الكبير

មានន័យថា៖ «អ្នកធ្វើការ បើគេប្រើឱ្យធ្វើការ គេយកអ្វីដែលត្រឹមត្រូវ ហើយផ្តល់ឱ្យអ្វីដែលត្រឹមត្រូវ គឺគេដូចជាអ្នកតស៊ូច្បាំងក្នុងផ្លូវអល់ឡោះ រហូតដល់គេត្រលប់មកផ្ទះវិញ» ។

- ការធ្វើបុណ្យហ័ជ្ជ និងអ៊ុំរ៉ោះក៏ជាការតស៊ូ។ អ្នកនាំសារលោកបានមានប្រសាសន៍ថា៖

عن عبيد الله أنه سمع رسول الله صلى الله عليه وسلم يقول : ( اَلْحَجُّ جِهَادٌ وَالْعُمْرَةُ تَطَوُّعٌ ) سنن ابن ماجه حديث ضعيف

មានន័យថា៖ «ការធ្វើបុណ្យហ័ជ្ជគឺជាការតស៊ូ ហើយការធ្វើអ៊ុំរ៉ោះជាការស្ម័គ្រចិត្ត» ។

- ការដើរទៅថ្វាយបង្គំនៅវិហារជាការតស៊ូ។ អ្នកនាំសារលោកបានមានប្រសាសន៍ថា៖

عن أبي أمامة أن رسول الله صلى الله عليه وسلم يقول: (اَلْغُدُوُّ وَالرَّوَاحُ إِلَى الْمَسْجِدِ مِنَ الْجِهَادِ فِيْ سَبِيْلِ اللهِ) الطبراني

មានន័យថា៖ «ការចេញទៅវិហារទាំងព្រឹកទាំងល្ងាចជាការតស៊ូក្នុងផ្លូវអល់ឡោះ» ។

អ្នកនាំសាររបស់អល់ឡោះបានមានប្រសាសន៍ថា៖

عن أبي هريرة رضي الله عنه أن رسول الله صلى الله عليه وسلم قال: (ألا أَدُلُّكُمْ على ما يَمْحُو الله بِهِ الْخَطَايَا وَيَرْفَعُ بِهِ الدَّرَجَاتِ قالوا بَلَى يا رَسُولَ اللَّهِ قال إِسْبَاغُ الْوُضُوءِ على الْمَكَارِهِ وَكَثْرَةُ الْخُطَا إلى الْمَسَاجِدِ وَانْتِظَارُ الصَّلَاةِ بَعْدَ الصَّلَاةِ فَذَلِكُمْ الرِّبَاطُ) صحيح مسلم

មានន័យថា៖ «តើចង់ឱ្យខ្ញុំបង្ហាញពួកអ្នកពីអ្វីដែលធ្វើឱ្យអល់ឡោះជាម្ចាស់លុបលាងទោសកំហុស ហើយទ្រង់លើកឋានៈទេ? ពួកគេឆ្លើយពិតហើយ អ្នកនាំសាររបស់ព្រះ។ លោកបានប្រសាសន៍ថា៖ ការយកទឹកជម្រះកាយឱ្យសព្វគ្រង់កន្លែងគន្លាក់ ដើរឱ្យបានច្រើនជំហានទៅកាន់វិហារ រង់ចាំថ្វាយបង្គំពីពេលមួយទៅពេលមួយនោះ គឺជាការឈរជើងនៅសមរភូមិ» ។

អំពើល្អទាំងឡាយក៏ដូច្នេះដែរ ការតស៊ូពិតប្រាកដ គឺការតស៊ូជំនះខ្លួនដែលអ្នកមូស្លីមត្រូវប្រកាន់ខ្ជាប់ក្នុងមួយជីវិតរបស់គេ។

រីឯអត្ថន័យពិសេសនៃពាក្យតស៊ូ (ជីហាត) គឺប្រយុទ្ធតស៊ូជាមួយនឹងពួកអ្នកដែលឈ្លានពពានទឹកដីរបស់ពួកអ្នកមូស្លីម កិត្តិយសទ្រព្យសម្បត្តិ និងសាសនារបស់ខ្លួន នេះគឺជាសិទ្ធិស្របច្បាប់សម្រាប់មនុស្សទូទៅ។ រីឯការធ្វើសង្គ្រាមដើម្បីផលប្រយោជន៍នយោបាយ ដូចជា ការពង្រីកអំណាចគ្រប់គ្រង បង្ហាញកម្លាំងទ័ព ធ្វើសង្គ្រាមសងសឹក គឺជាអំពើដែលឥស្លាមបានហាមឃាត់។

សម្រាប់ការតស៊ូក្នុងឥស្លាមមានច្បាប់ ក្រមសីលធម៌ និងវិជ្ជាជីវៈដែលបញ្ជាក់ថា ឥស្លាមជាសាសនានៃសេចក្តីមេត្តា។ ពួកចំណាប់ខ្មាំងឈ្លើយសឹក ពួកអ្នកចាញ់សង្គ្រាម ប្រជាពលរដ្ឋដែលចាញ់សង្គ្រាមនៅ

មានសិទ្ធិ និងកាតព្វកិច្ចសម្រាប់ពួកគេ។ ចំពោះប្រិយមិត្តអ្នកអានដែលចង់ស្វែងយល់បន្ថែមសូមត្រលប់ទៅអានសៀវភៅឯកទេសដែលពាក់ពាន់នឹងវិស័យនេះ។

## ឥស្លាម និងបរិស្ថាន

ឥស្លាមប្រើឱ្យថែរក្សាបរិស្ថាន ពុំត្រូវបំពុលបរិស្ថានក្នុងរូបភាពណាមួយតាមរយៈជំរុញលើការដាំរុក្ខជាតិដែលមានប្រយោជន៍។ អ្នកនាំសារលោកបានមានប្រសាសន៍ថា៖

عن أنس بن مالك رضي الله عنه قال قال رسول الله صلى الله عليه وسلم: ( مَا مِنْ مُسْلِمٍ يَغْرُسُ غَرْسًا أَوْ يَزْرَعُ زَرْعًا فَيَأْكُلُ مِنْهُ طَيْرٌ أَوْ إِنْسَانٌ أَوْ بَهِيمَةٌ إِلاَّ كَانَ لَهُ بِهِ صَدَقَةٌ ) صحيح البخاري

មានន័យថា៖ «គ្មានអ្នកមូស្លីមណាម្នាក់បានដាំដើមឈើ ហើយមានសត្វស្លាប ឬមនុស្ស ឬសត្វពាហនៈអាស្រ័យផល ឬផ្លែរបស់វា លើកលែងតែគេប្រទានសម្រាប់អ្នកនោះហាក់បានធ្វើទាន» ។

ជំរុញលើកាលុបបំបាត់ឱ្យអស់នូវរាល់ប្រការទាំងឡាយដែលនាំឱ្យប៉ះពាល់ដល់សេចក្ដីសុខសុវត្ថិភាព។ អ្នកនាំសារលោកបានមានប្រសាសន៍ថា៖

عن أبي هريرة رضي الله عنه قال قال رسول الله صلى الله عليه وسلم:

(... وَيُمِيطُ الأَذَى عَنِ الطَّرِيقِ صَدَقَةٌ )  صحيح البخاري

មានន័យថា៖ «ហើយការដែលគេបោះសម្អាតក្រួសបន្លាចេញពីផ្លូវក៏ជាការធ្វើបុណ្យទានដែរ» ។

ជំរុញលើការបង្កើតឱ្យមានបន្ទប់អនាម័យផ្ទាល់ខ្លួនជៀសវាងការឆ្លងជំងឺអាសន្នរោគ និងបរិស្ថានក្នុងសង្គមដទៃ ជាការថែរក្សាអាយុជីវិតអ្នកដទៃ។ អ្នកនាំសារលោកបានមានប្រសាសន៍ថា៖

عن إبراهيم بن سعد قال سمعت أسامة بن زيد يحدث سعدا عن النبي صلى الله عليه وسلم قال : ( إِذَا سَمِعْتُمْ بِالطَّاعُوْنِ بِأَرْضٍ فَلاَ تَدْخُلُوْهَا وَإِذَا وَقَعَ بِأَرْضٍ وَأَنْتُمْ بِهَا فَلاَ تَخْرُجُوْا مِنْهَا ) صحيح البخاري

មានន័យថា៖ «បើសិនជាពួកអ្នកបានឮជំងឺឆ្លងរាតត្បាតនៅតំបន់មួយចូរកុំចូលទៅកាន់តំបន់នោះ តែបើសិនជាមានជំងឺនេះកើតឡើងហើយពួកអ្នកឋិតក្នុងតំបន់នោះ ចូរកុំរត់ចេញទៅតំបន់ដទៃ » ។

ហាមសម្លាប់ បំផ្លាញសត្វពាហនៈ បក្សាបក្សីដោយឥតប្រយោជន៍។ អ្នកនាំសារលោកបានមានប្រសាសន៍ថា៖

عن عمرو بن الشريد قال سمعت الشريد يقول سمعت رسول الإسلام صلى الله عليه وسلم يقول: (مَنْ قَتَلَ عُصْفُوْرًا عَبَثًا عَجَّ إِلَى اللهِ يَوْمَ الْقِيَامَةِ يَقُوْلُ يَا رَبّ إِنَّ فُلاَنًا قَتَلَنِيْ عَبَثًا وَلَمْ يَقْتُلْنِيْ مَنْفَعَةً ) سنن النسائي

មានន័យថា៖ «នរណាសម្លាប់សត្វចាបមួយដោយឥតប្រយោជន៍។ នៅថ្ងៃបរលោកសត្វចាបនឹងទៅប្ដឹងអល់ឡោះដោយស្រែកតវ៉ាថា៖ បពិត្រព្រះជាម្ចាស់ បុរសម្នាក់នេះបានសម្លាប់ខ្ញុំចោលដោយឥតប្រយោជន៍ គេពុំបានសម្លាប់ខ្ញុំដើម្បីជាប្រយោជន៍នោះឡើយ» ។

ហាមបំពុលបរិស្ថានដោយគ្រប់មធ្យោបាយទាំងអស់។ អ្នកនាំសារលោកបានមានប្រសាសន៍ថា៖

عَنْ أَبِي هُرَيْرَةَ أَنَّ رَسُولَ اللَّهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ قَالَ : ( اتَّقُوا اللَّعَّانَيْنِ قَالُوا وَمَا اللَّعَّانَانِ يَا رَسُولَ اللَّهِ قَالَ الَّذِي يَتَخَلَّى فِي طَرِيقِ النَّاسِ أَوْ فِي ظِلِّهِمْ )

صحيح مسلم

មានន័យថា៖ «ចូរប្រយ័ត្នចំពោះប្រការពីរដែលត្រូវគេដាក់ផ្តាសារពួកគេសួរថា បពិត្រអ្នកនាំសាររបស់ព្រះ តើប្រការពីរនោះជាអ្វី? លោកបានមានប្រសាសន៍ថា គឺការជុះនៅតាមផ្លូវមនុស្សដើរ ឬក្រោមម្លប់ដែលពួកគេជ្រក» ។

## ឥស្លាម និងអនាម័យ

ឥស្លាមជាសាសនាអនាម័យ អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿يَٰبَنِيٓ ءَادَمَ خُذُواْ زِينَتَكُمۡ عِندَ كُلِّ مَسۡجِدٖ وَكُلُواْ وَٱشۡرَبُواْ وَلَا تُسۡرِفُوٓاْۚ إِنَّهُۥ لَا يُحِبُّ ٱلۡمُسۡرِفِينَ ٣١﴾ الأعراف : ٣١

មានន័យថា៖ «នៃកូនចៅអាដាំទាំងឡាយចូរតុបតែងខ្លួននៅរៀងរាល់ពេលទៅថ្វាយបង្គំនៅវិហារ ចូរទទួលទានចំណីអាហារនិងបរិភោគចុះ តែកុំខ្ជះខ្ជាយ។ ពិតប្រាកដ ទ្រង់មិនសព្វព្រះទ័យចំពោះពួកអ្នកដែលខ្ជះខ្ជាយនោះឡើយ» ។

ឥស្លាមជាសាសនាស្អាតស្អំ ដូចអល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿إِنَّ ٱللَّهَ يُحِبُّ ٱلتَّوَّٰبِينَ وَيُحِبُّ ٱلۡمُتَطَهِّرِينَ ٢٢٢﴾ البقرة: ٢٢٢

មានន័យថា៖ «ពិតប្រាកដ អល់ឡោះជាម្ចាស់ទ្រង់សព្វព្រះទ័យចំពោះពួកអ្នកដែលសារភាពកំហុស និងសព្វព្រះទ័យចំពោះពួកអ្នកដែលស្អាតស្អំ» ។

ភាពស្អាតស្អំជាលក្ខខណ្ឌនៃភាពត្រឹមត្រូវសម្រាប់ការថ្វាយបង្គំដែលអ្នកមូស្លីមប្រតិបត្តិប្រាំដងក្នុងមួយថ្ងៃមួយយប់។ ក៏ដូចជាតម្រូវឱ្យមុជទឹកសម្អាតខ្លួនក្រោយពេលរួមមេត្រីជាមួយប្រពន្ធ ហើយក៏ជាភារកិច្ចត្រូវធ្វើសម្រាប់ពិធីដែលជាអត្តសញ្ញាណសាសនាដូចជា ការថ្វាយបង្គំថ្ងៃសុក្រ ថ្ងៃបុណ្យទាំងពីរ ចូលឆ្នាំ និងចេញបួស ការធ្វើបុណ្យហាជ្ជ និងអ៊ុំរ៉ោះ។ លើសពីនេះ ឥស្លាមជំរុញឱ្យលាងដៃទាំងពីរមុននិងក្រោយហូបបាយនិងទទួលទាន ដូចអ្នកនាំសារលោកបានមានប្រសាសន៍ថា៖

يقول رسول الإسلام صلى الله عليه وسلم : ( بَرَكَةُ الطَّعَامِ الْوُضُوءُ قَبْلَهُ وَالْوُضُوءُ بَعْدَهُ ) سنن الترمذي حديث ضعيف

មានន័យថា៖ «ចំណីដែលមានពរជ័យគឺការយកទឹកជម្រះកាយ (ទឹកវូហ្មុ)មុន និងក្រោយពេលទទួលទានរួច» ។

ត្រូវរក្សាការអនាម័យ និងសម្អាតមាត់ធ្មេញជាប្រចាំ ដូចអ្នកនាំសារលោកបានមានប្រសាសន៍ថា៖

يقول رسول الإسلام صلى الله عليه وسلم : ( لَوْ لَا أَنْ أَشُقَّ عَلَى أُمَّتِي لَأَمَرْتُهُمْ بِالسِّوَاكِ عِنْدَ كُلِّ صَلَاةٍ ) صحيح مسلم.

មានន័យថា៖ «ប្រសិនបើមិនពិបាកចំពោះប្រជាជាតិខ្ញុំទេនោះ ខ្ញុំនឹងប្រើឱ្យពួកគេដុសសម្អាតធ្មេញរៀងរាល់ពេលថ្វាយបង្គំ" ។

ជម្រះសម្អាត និងលាងជម្រះអ្វីដែលមានផ្ទុកបាក់តេរី កាកសំណល់ និងភាពកខ្វក់។ ដូចអ្នកនាំសារលោកបានប្រសាសន៍ថា៖

يقول رسول الإسلام صلى الله عليه وسلم : ( اَلْفِطْرَةُ خَمْسٌ اَلْخِتَانُ وَ الْإِسْتِحْدَادُ وَنَتْفُ الْإِبْطُ وَقَصُّ الشَّارِبِ وَتَقْلِيمُ الْأَظْفَارِ ) صحيح البخاري

មានន័យថា៖ «សភាវគតិមានប្រាំ ការកាត់ចុងស្បែកអង្គជាតិ កោររោមជុំវិញប្រដាប់ភេទ ដករោមក្លៀក កាត់តម្រឹមពុកមាត់ឱ្យខ្លី និង កាត់ក្រចក» ។

## ឥស្លាម និងចំណេះវិជ្ជា

សាសនាឥស្លាមជំរុញលើកទឹកចិត្តចំពោះចំណេះវិជ្ជា ឱ្យចេះស្វែងរក និងបង្កើនចំណេះដឹង ស្តីបន្ទោសចំពោះភាពល្ងង់ខ្លៅ និង ដាស់តឿនឱ្យប្រុងប្រយ័ត្នពីភាពល្ងង់ខ្លៅ។ អ្នកនាំសារលោកបានមានប្រសាសន៍ថា៖

يقول رسول الله صلى الله عليه وسلم : ( طَلَبُ الْعِلْمِ فَرِيْضَةٌ عَلَى كُلِّ مُسْلِمٍ ) سنن ابن ماجه

មានន័យថា៖ «ការស្វែងរកចំណេះវិជ្ជាជាកាតព្វកិច្ចលើបុគ្គលមូស្លីមគ្រប់រូប» ។

គេចាត់ទុកការស្វះស្វែងក្នុងរឿងចំណេះវិជ្ជាទាំងការរៀនសូត្រ និងការបង្រៀនជាមូលហេតុនាំទៅកាន់ឋានសួគ៌ ដូចអ្នកនាំសារលោកបានមានប្រសាសន៍ថា៖

يقول رسول الله صلى الله عليه وسلم: ( مَنْ سَلَكَ طَرِيْقًا يَطْلُبُ فِيْهِ عِلْمًا سَلَكَ اللهُ بِهِ طَرِيْقًا مِنْ طُرُقِ الْجَنَّةِ ...) صحيح ابن حبان

មានន័យថា៖ «នរណាដើរស្វែងរកចំណេះវិជ្ជា អល់ឡោះធ្វើឱ្យគេដើរតាមផ្លូវទៅកាន់ឋានសួគ៌» ។

ឥស្លាមបានហាមឃាត់ចំពោះការលាក់ចំណេះវិជ្ជា ព្រោះចំណេះវិជ្ជាជាកម្មសិទ្ធិសមោហភាពសម្រាប់មនុស្សទូទៅ។ អ្នកនាំសារលោកបានមានប្រសាសន៍ថា៖

يقول رسول الله صلى الله عليه وسلم: ( مَنْ كَتَمَ عِلْمًا أَلْجَمَهُ اللهُ يَوْمَ الْقِيَامَةِ بِلِجَامٍ مِنْ نَارٍ ) صحيح ابن حبان

មានន័យថា៖ «នរណាលាក់លៀមចំណេះវិជ្ជា អល់ឡោះនឹងដាក់បង្ហៀរគេពីភ្លើងនរកនៅថ្ងៃបរលោក» ។

ឥស្លាមលើកតម្កើងអ្នកចេះដឹង បង្គាប់ឱ្យគេលើកតម្កើង ឱ្យតម្លៃ និងគោរពពួកអ្នកចេះដឹង។ អ្នកនាំសារលោកបានមានប្រសាសន៍ថា៖

يقول رسول الإسلام صلى الله عليه وسلم : ( لَيْسَ مِنْ أُمَّتِيْ مَنْ لَمْ يُجِلَّ كَبِيْرَنَا وَيَرْحَمْ صَغِيْرَنَا وَيَعْرِفْ لِعَالِمِنَا حَقَّهُ ) مسند الإمام أحمد

មានន័យថា៖ «ពុំមែនជាប្រជាជាតិរបស់ខ្ញុំទេ អ្នកដែលមិនគោរពមនុស្សចាស់ មិនអាណិតកូនក្មេង និងមិនស្គាល់សិទ្ធិរបស់អ្នកចេះដឹង» ។

អ្នកនាំសារលោកបានមានប្រសាសន៍បញ្ជាក់ពីឋានៈរបស់អ្នកចេះដឹងថា៖

يقول رسول الإسلام صلى الله عليه وسلم:" فَضْلُ الْعَالِمِ عَلَى الْعَابِدِ كَفَضْلِيْ عَلَى أَدْنَاكُمْ " سنن الترمذي

មានន័យថា៖ «អ្នកមានចំណេះដឹងខ្ពង់ខ្ពស់ជាងអ្នកប្រតិបត្តិសាសនាដូចជារូបខ្ញុំខ្ពង់ខ្ពស់ជាងអ្នកដែលមានឋានៈទាបជាងគេបំផុតក្នុងចំណោមពួកអ្នក» ។

## ឥទ្ធិពលអរិយធម៌ឥស្លាមចំពោះការអភិវឌ្ឍផ្នែកវិទ្យាស្រ្ត ទំនើប

ពិតប្រាកដ អ្នកដែលបានអានសាឡើងវិញពីឫសគល់ដែលនាំឱ្យវិទ្យាសាស្រ្តទំនើបឈានដល់សព្វថ្ងៃនេះឃើញថា អរិយធម៌ឥស្លាមដែលពួកអ្នកប្រាជ្ញឥស្លាមសម័យដើមបានផ្តល់ជាវិភាគទាន មានគុណសម្បត្តិ បន្ទាប់ពីអស់ឡោះជាម្ចាស់ ក្នុងការធ្វើឱ្យវិទ្យាសាស្រ្តទំនើប មានការវិវឌ្ឍរីកចំរើន។ អ្នកប្រាជ្ញអឺរ៉ុបម្នាក់ឈ្មោះ សេដេអូ បាននិយាយថាបើទោះជាពួកអឺរ៉ុបខិតខំប្រឹងប្រែងយ៉ាងណា ក៏មិនអាចបដិសេធចំពោះគុណសម្បត្តិនៃអរិយធម៌អារ៉ាប់ឥស្លាមចំពោះពិភពលោកទាំងមូល គេមិនអាចលុបបំបាត់កេរដំណែល និងស្នាដៃរបស់ពួកគេចេញពីទំព័រប្រវត្តិសាស្រ្តពិភពលោកយើងនេះបានជាដាច់ខាត។

ពួកគេជាអ្នកចាក់គ្រឹះ និងកសាងមូលដ្ឋានគ្រឹះ ដែលអរិយធម៌ពិភពលោកបានកសាងឡើងលើខឿននេះ ហើយចំពោះអ្នកដែលបានត្រលប់ទៅអានសៀវភៅបច្ចេកសព្ទនៃការហោះហើរ និងលំហអាកាសដែលគេប្រើជាពិសេសសម្រាប់គ្រប់គ្រងការហោះហើរ និងលំហអាវកាសជាតិរបស់អាមេរិក -ណាហ្សា- ទំព័រ ១៨៥ ឃើញថា ៦០% នៃឈ្មោះផ្កាយ ល្បីៗដែលគេប្រើក្នុងយានអាវកាសមានប្រភពចេញពីបច្ចេកសព្ទអារ៉ាប់។

សៀវភៅទាំងឡាយ និងស្នាដៃនិពន្ធរបស់ពួកអ្នកប្រាជ្ញមូស្លីមជំនាន់ដើមជាឯកសារយោងមូលដ្ឋានដែលពួកអ្នកប្រាជ្ញជំនាន់ក្រោយជាពិសេសពួកអឺរ៉ុបបានប្រើជាប្រយោជន៍ក្នុងការស្រាវជ្រាវ ហើយបានធ្វើការអភិវឌ្ឍន៍លើអ្វីដែលពួកគេបានបកប្រែជាភាសារបស់ពួកគេឱ្យ

មានការរីកចំរើនជឿនលឿនក្នុងសម័យទំនើប។ ចំណេះដឹងទាំងនោះបានក្លាយជាមុខវិជ្ជាសិក្សានៅតាមសកលវិទ្យាល័យនានារបស់ពួកគេ។ លោក ចូស្ត័ហ្វ លូបូន ក្នុងសៀវភៅ អរិយធម៌អារ៉ាប់របស់លោកបានសរសេរថា រាល់ពេលដែលយើងស្វែងយល់ស៊ីជម្រៅក្នុងការសិក្សាអំពីអរិយធម៌អារ៉ាប់ ស្នាដៃនិពន្ធបែបវិទ្យាសាស្ត្រ របកកំហើញ និងសិល្បៈរបស់ពួកគេបានលាតត្រដាងពីចំណេះដឹងថ្មីៗមានវិសាលភាពធំធេង ហើយធ្វើឱ្យមើលឃើញភ្លាមៗថា អារ៉ាប់មានគុណសម្បត្តិក្នុងការគាស់កកាយចំណេះវិជ្ជាសម័យកណ្តាល។ សកលវិទ្យាល័យនានានៅអឺរ៉ុបក្នុងរយៈពេលប្រាំសតវត្សដំបូងគេមិនដឹងថា មានប្រភពចំណេះដឹងណាក្រៅពីស្នាដៃនិពន្ធរបស់ពួកគេ ហើយពួកគេជាអ្នកធ្វើនគរូបនីយកម្មលើអឺរ៉ុបផ្នែកមុខវិជ្ជាបង្រៀន មនោគមន៍ និងសីលធម៌សង្គម។ ពិតណាស់ ប្រវត្តិសាស្ត្រមិនដែលស្គាល់ជាតិសាសន៍ណាបានបន្សល់ជាស្នាដៃដូចពួកគេក្នុងរយៈពេលដ៏ខ្លី ហើយគ្មាន សាសន៍ណានាំមុខពួកគេក្នុងការធ្វើទំនើបកម្មលើវិស័យសិល្បៈផងដែរ។

ផ្នែកគណិតវិទ្យា ដូចជាវេខាគណិត រូបមន្តត្រីកោណ ធរណីមាត្រក្នុងលំហ អ្នកប្រាជ្ញដែលលេចធ្លោជាងគេគឺអាល់ខូវ៉ារេហ្ស្មីយ៍។ ផ្នែកលំហអាកាស និងតារាសាស្ត្រ អ្នកប្រាជ្ញដែលលេចធ្លោជាងគេគឺអាល់កើហ្សាវីនីយ៍ និងអាល់បេរូនីយ៍។ អ្នកដើររុករកទំនៀមទម្លាប់បូព៌ាជនជាតិអាឮម៉ង់និយាយពីលោកអាល់បេរូនីយ៍ថា លោកគឺជាទស្សនវិទូដ៏ឧត្តុង្គឧត្តមជាងគេដែលប្រវត្តិសាស្ត្រមនុស្សជាតិបានស្គាល់។ ប៉ុន្តែយើងជាអ្នកមូស្លីមនិយាយថា ក្បាលម៉ាស៊ីននៃបញ្ញាញាណគឺអ្នកនាំសារមូហាំម៉ាត់នៃយើង។ ជំនាញវេជ្ជសាស្ត្រ និងឱសថសាស្ត្រអ្នក

ប្រាជ្ញឥស្លាមបានបង្កើតរូបមន្ត និងទ្រឹស្តីដែលអ្នកប្រាជ្ញសម័យទំនើប បានចាប់ផ្តើមចេញពីទ្រឹស្តីទាំងនោះក្នុងការធ្វើបដិវត្តន៍ផ្នែកវេជ្ជសាស្ត្រ ដូចជាសៀវភៅរបស់ អិពនូ រុស្សូដ៍ និងអិពនូអាន់ណាហ្វីស ដែលបាន រកឃើញវដ្តតូចនៃឈាមមុនជនជាតិអង់គ្លេសឈ្មោះហារីហ្វីយ៍ និងជន ជាតិអេស្ប៉ាញឈ្មោះ សារហ្វីតូស ប៉ុន្មានសតវត្ស។ លោក អាំម៉ើរ ពិន អាលី មកពីខេត្តមូសិលនៃប្រទេសអ៊ីរ៉ាក់ និង អាលី ពិន អ៊ីសា អាល់កា ហាល មានជំនាញខាងចក្ខុរោគសាស្ត្រ។ អាល់ហាសាន់ ពិន អាល់ហៃ សាំ បានបង្កើតទ្រឹស្តី និងច្បាប់ជាច្រើនពាក់ពាន់នឹងចក្ខុប្រសាទ។ អា ល់ម៉ាន់សួរ និងអាពូ បាកើរ អាល់រ៉ាហ្សីយ៍មានជំនាញខាងវះកាត់។ អាល់ម៉ាវហ្វិក មកពីទីក្រុងបាដាត និង អាពូអាល់កោសិម អើសហ្សះរ៉ា វីយ៍មានជំនាញខាងវេជ្ជសាស្ត្រ និងការវះកាត់មាត់ធ្មេញ លោកជាអ្នក និពន្ធសព្វវចនាធិប្បាយវេជ្ជសាស្ត្រមាន៣០ភាគមានរៀបរាប់ពី ឧបករណ៍ប្រើសម្រាប់ការវះកាត់ និងរបៀបប្រើប្រាស់។

ខាងវិស័យភូមិសាស្ត្រ និងភូគព្ភសាស្ត្រអ្នកប្រាជ្ញដែលលេច ធ្លោជាងគេគឺ អើសស្សារីហ្វ អាល់អិទទ្រីសីយ៍ លោកជាអ្នកប្រាជ្ញខាង ភូមិវិទ្យា លោកជាអ្នកផ្តើមគំនិតរចនារូបគំនូរផែនទីដំបូងបង្អស់ ហើយ ក៏ជាអ្នករចនាឧបករណ៍នាវាចរណ៍ដែរ។ ពួកអ្នកប្រាជ្ញឥស្លាមជាច្រើន បានចូលរួមក្នុងការអភិវឌ្ឍន៍អរិយធម៌។ ចំពោះបងប្អូនដែលចង់ដឹង ច្បាស់បន្ថែមទៀត សូមមេត្តាអានសៀវភៅៗដែលនិយាយអំពីរឿងនេះ នោះនឹងឃើញថា មានទ្រឹស្តីនិងការស្រាវជ្រាវជាច្រើនដែលគេដក ស្រង់យកមកពីស្នាដៃរបស់ពួកគេ តែបែរជាដាក់ឈ្មោះអ្នកផ្សេងទៅវិ ញ។ លោក ចច សារតូន និយាយថា បើសិនជាគ្មានអ្នកប្រាជ្ញឥស្លាម និង

ស្នាដៃរបស់ពួកគេទេនោះ ពួកអ្នកប្រាជ្ញនៅបុនសម័យច្បាស់ជាត្រូវចាប់ផ្ដើមពីចំណុចសូន្យ ហើយអរិយធម៌នឹងមានការយឺតយ៉ាវប៉ុន្មានសតវត្សទៅមុខទៀត។

## លក្ខណៈពិសេសនៃអរិយធម៌ឥស្លាម

* ពិតប្រាកដ ការស្វែងរកចំណេះវិជ្ជាក្នុងឥស្លាមជាកាតព្វកិច្ចសាសនា ដែលច្បាប់សារីអាត់ឥស្លាមបានជំរុញ ដូចបានលើកឡើងខាងលើ។
* ពួកអ្នកប្រាជ្ញឥស្លាមជំនាន់ដើមបានប្រើប្រាស់ចំណេះដឹងពួកគាត់ដើម្បីពង្រឹងក្ដីជំនឿក្នុងចិត្តមនុស្ស ផ្ទុយស្រឡះពីពួកអ្នកប្រាជ្ញសម័យទំនើបភាគច្រើនប្រើចំណេះដឹងរបស់ពួកគេជាមធ្យោបាយដើម្បីធ្វើឱ្យរង្គោះរង្គើជំនឿក្នុងចិត្តរបស់មនុស្ស។
* ពិតប្រាកដ ពួកអ្នកប្រាជ្ញឥស្លាមជំនាន់ដើមប្រើប្រាស់ចំណេះដឹងរបស់ពួកគាត់ដើម្បីបម្រើមនុស្សជាតិ ផ្ទុយស្រឡះពីពួកអ្នកប្រាជ្ញសម័យទំនើបភាគច្រើនប្រើប្រាស់ចំណេះដឹងរបស់ពួកគេដើម្បីប្រើមនុស្ស ត្រួតត្រាលើពួកគេ បង្ខំឱ្យពួកគេបម្រើផលប្រយោជន៍របស់ខ្លួនតាមរយៈការផលិត និងបង្កើត គម្រោងផែនការណ៍សាហាវឃោរឃៅដូចជា ផលិតគ្រាប់បែកបរមណូ ណុយក្លេអ៊ែរ សាធាតុអ៊ីុទ្រូសែន និងអាវុធប្រល័យលោក។ ពួកគេប្រើកលឧកាយជាសិល្បៈក្នុងរឿងនេះ ហើយប្រយុទ្ធប្រឆាំងនឹងពួកអ្នកដែលមានបំណងចង់បង្កើតដូចពួកគេ ដើម្បីឱ្យពួកគេក្លាយជាអ្នកគ្រប់គ្រង និងត្រួតត្រាពិភពលោកទាំងមូល។

* ពួកអ្នកប្រាជ្ញឥស្លាមជំនាន់ដើម បានទុកចំណេះដឹងរបស់ពួកគេជាសម្បត្តិសាធារណៈសម្រាប់មនុស្សទូទៅ ដើម្បីបម្រើផលប្រយោជន៍រួមផ្ទុយស្រឡះពីពួកអ្នកប្រាជ្ញសម័យទំនើបភាគច្រើនដែលមានចំណេះដឹងមកធ្វើជាកម្មសិទ្ធិផ្ដាច់មុខសម្រាប់បម្រើតែផលប្រយោជន៍ខ្លួនឯង និងប្រទេសរបស់ខ្លួន អ្នកដទៃគ្មានសិទ្ធិស្វែងយល់អំពីរឿងនេះឡើយ។
* ពួកអ្នកប្រាជ្ញឥស្លាមជំនាន់ដើមទិសដៅដែលចង់បានពីចំណេះដឹងគឺផលបុណ្យពីអល់ឡោះជាម្ចាស់ ផ្ទុយស្រឡះពីពួកអ្នកប្រាជ្ញសម័យទំនើបភាគច្រើនដែលប្រើប្រាស់ចំណេះដឹងជាមធ្យោបាយដើម្បីរកចំណេញខាងរូបធាតុនិយម និងសម្ភារនិយម។

## ព្រះបន្ទូលខ្លះទាក់ទងនឹងវិទ្យាសាស្ត្រពិតក្នុងគម្ពីរអាល់គួរអាន

អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿إِنَّ فِي خَلْقِ ٱلسَّمَٰوَٰتِ وَٱلْأَرْضِ وَٱخْتِلَٰفِ ٱلَّيْلِ وَٱلنَّهَارِ وَٱلْفُلْكِ ٱلَّتِي تَجْرِى فِي ٱلْبَحْرِ بِمَا يَنفَعُ ٱلنَّاسَ وَمَآ أَنزَلَ ٱللَّهُ مِنَ ٱلسَّمَآءِ مِن مَّآءٍ فَأَحْيَا بِهِ ٱلْأَرْضَ بَعْدَ مَوْتِهَا وَبَثَّ فِيهَا مِن كُلِّ دَآبَّةٍ وَتَصْرِيفِ ٱلرِّيَٰحِ وَٱلسَّحَابِ ٱلْمُسَخَّرِ بَيْنَ ٱلسَّمَآءِ وَٱلْأَرْضِ لَأَيَٰتٍ لِّقَوْمٍ يَعْقِلُونَ ١٦٤﴾

البقرة : ١٦٤

មានន័យថា៖«ពិតប្រាកដក្នុងការបង្កើតមេឃនិងផែនដីបែងចែកយប់និងថ្ងៃ កប៉ាល់ដែលកំពុងធ្វើចរាចរណ៍លើផ្ទៃសមុទ្រដែលផ្ដល់ផលប្រយោជន៍ដល់មនុស្ស ទឹកភ្លៀងដែលអល់ឡោះទ្រង់បានបញ្ចុះពីលើ

មេឃ ធ្វើឱ្យផែនដីមានជីវិតរស់ឡើងវិញដោយរុក្ខជាតិក្រោយពេលក្រៀមស្វិត ទ្រង់បានបង្កើតឱ្យមានសព្វសត្វទាំងឡាយលើផែនដីនេះ។ ល្បាយខ្យល់បក់ និងពពកដែលរសាត់នៅលើមេឃ ហើយនិងផែនដីជានិមិត្តសញ្ញាសម្រាប់ពួកអ្នកមានបញ្ញាចេះគិត» ។

គេបញ្ចុះគម្ពីរអាល់គួរអានមកចំពោះមូហាំម៉ាត់ គាត់ជាបុរសម្នាក់មិនចេះអក្សរ មិនចេះអាន មិនចេះសរសេរ រស់នៅជាមួយពូជសាសន៍មួយដែលមិនចេះអក្សរភាគច្រើនគឺដើម្បីកុំឱ្យនរណាម្នាក់មានមន្ទិលសង្ស័យចំពោះសាររបស់មូហាំម៉ាត់។ តើបុរសមិនចេះអក្សរអាចនាំមកនូវគម្ពីរ ដែលធ្វើឱ្យពួកកំពូលកវីអស់សមត្ថភាពនឹងតែងនិពន្ធឱ្យដូចទាំងបំណិន និងវោហារសាស្ត្រ ថែមទាំងបានប្រកាសដាក់កំហិតឱ្យពួកគេនិពន្ធឱ្យដូចគម្ពីរនេះ។ ដូចអល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូល៖

﴿ قُل لَّئِنِ ٱجۡتَمَعَتِ ٱلۡإِنسُ وَٱلۡجِنُّ عَلَىٰٓ أَن يَأۡتُواْ بِمِثۡلِ هَٰذَا ٱلۡقُرۡءَانِ لَا يَأۡتُونَ بِمِثۡلِهِۦ وَلَوۡ كَانَ بَعۡضُهُمۡ لِبَعۡضٖ ظَهِيرٗا ٨٨ ﴾ الإسراء : ٨٨

មានន័យថា៖ «មូហាំម៉ាត់ចូរប្រាប់ពួកគេចុះថា បើសិនជាទាំងមនុស្ស ទាំងពួកបង់បត់ប្រមូលផ្តុំគ្នាចង់បង្កើតឱ្យដូចគម្ពីរអាល់គួរអាននេះ ពួកគេធ្វើមិនដូចជាដាច់ខាត បើទោះជាពួកសហការគាំទ្រគ្នាយ៉ាងណាក៏ដោយចុះ» ។

ថ្វីបើ ទាំងអ្នកនាំសារមូហាំម៉ាត់ និងសហការីរបស់លោកនៅទន់ខ្សោយ ខ្វះខាត និងក្សត់ខ្សោយយ៉ាងណាក៏ដោយ ក៏ពួកគាត់បានអានគម្ពីរអាល់គួរអាននេះ ឱ្យពួកគេស្តាប់ស្តីអំពីនិមិត្តសញ្ញាអច្ឆរិយៈ

ផ្នែកវិទ្យាសាស្ត្រពិតមួយចំនួនតាំងពីជាង១៤សតវត្សរ៍ប្លាយ ដែលពួកអ្នកប្រាជ្ញមិនអាចស្រាវជ្រាវរកឃើញ លើកលែងតែនៅសម័យទំនើបនេះប៉ុណ្ណោះ។ ពួកគេបានប្រើឧបករណ៍បច្ចេកទេសទំនើបដើម្បីជំនួយ។ ក្នុងប្រធានបទនេះ សូមលើកឡើងពីព្រះបន្ទូលខ្លះនៃគម្ពីរអាល់គួរអាន និងរបកកំហើញដែលវិទ្យាសាស្ត្រទំនើបបានសិក្សាស្រាវជ្រាវ ដោយមិនភ្ជាប់ព្រះបន្ទូលទៅនឹងរបកគំហើញវិទ្យាសាស្ត្រទំនើប ព្រោះវិទ្យាសាស្ត្រអាចមានការវិវឌ្ឍន៍ និងផ្លាស់ប្តូរ ផ្ទុយពីគម្ពីរអាល់គួរអាន។ អ្វីដែលវិទ្យាសាស្ត្រទំនើបបានលើកឡើងក្នុងពេលបច្ចុប្បន្នអាចនឹងផ្លាស់ប្តូរនៅថ្ងៃអនាគត។

## គម្ពីរអាល់គួរអាន និងកំណកំណើតភព

អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿ ٱللَّهُ يَبۡدَؤُاْ ٱلۡخَلۡقَ ثُمَّ يُعِيدُهُۥ ثُمَّ إِلَيۡهِ تُرۡجَعُونَ ﴿١١﴾ ﴾ الروم : ١١

មានន័យថា៖ «អល់ឡោះជាម្ចាស់ចាប់ផ្តើមបង្កើត បន្ទាប់មកទ្រង់បង្កើតវាសាឡើងវិញ បន្ទាប់មកពួកអ្នកនឹងវិលត្រលប់ទៅរកទ្រង់»។

គម្ពីរអាល់គួរអានប្រកាសក្នុងព្រះបន្ទូលនេះថា អល់ឡោះជាម្ចាស់តែមួយគត់ទ្រង់ជាអ្នកបង្កើតសភាវសត្វលោកដែលមានក្នុងចក្រវាលពីគ្មានឱ្យមាន។ រឿងទាំងនេះមិនអាចស្វែងយល់បានជាដាច់ខាត លើកលែងតែតាមរយៈការបកស្រាយរបស់គម្ពីរអាល់គួរអានដែលជាព្រះបន្ទូលមកពីអល់ឡោះ។ ទ្រង់បានមានព្រះបន្ទូលរៀបរាប់ពីកំណកំណើតភពថា៖

﴿بَدِيعُ ٱلسَّمَٰوَٰتِ وَٱلۡأَرۡضِۖ وَإِذَا قَضَىٰٓ أَمۡرٗا فَإِنَّمَا يَقُولُ لَهُۥ كُن فَيَكُونُ ١١٧﴾ البقرة : ١١٧

មានន័យថា៖ «អល់ឡោះជាម្ចាស់ទ្រង់ជាអ្នកបង្កើតមេឃនិងផែនដីដោយគ្មានគំរូពីមុនមក ហើយនៅពេលណាទ្រង់លិខិតកំណត់អ្វីមួយទ្រង់គ្រាន់តែបន្ទូលថា ចូរកើតចុះ នោះវាក៏កើតឡើងភ្លាម»។

អល់ឡោះជាម្ចាស់ទ្រង់បន្ទូលប្រាប់យើងក្នុងបន្ទូលនេះថា ពកទាំងមូលកើតចេញពីគ្មាន និងអ្វីដែលមានមុនភព ជាចំណេះដឹងដ៏អាថ៌កំបាំងដែលគ្មាននរណាដឹងលើកលែងអល់ឡោះតែមួយគត់។ ប្រាជ្ញារបស់មនុស្សអសមត្ថភាពនឹងស្វែងយល់ពីរូបធាតុដើម និងរបៀបរបបនៃការកកើតដំបូងបង្អស់ ពីព្រោះមានតែអល់ឡោះជាម្ចាស់តែមួយគត់ដឹងពីអាថ៌កំបាំងនេះ ហើយប្រាជ្ញារបស់មនុស្សនៅតែបន្តអសមត្ថភាពរហូត មិនអាចស្វែងយល់ពីរូបធាតុដើម និងរបៀបរបបនៃការកកើតភព។ អ្វីដែលប្រាជ្ញារបស់មនុស្សអាចធ្វើបានគឺគ្រាន់តែដឹងពីទិដ្ឋភាពខាងក្រៅនៃការកកើតភព គ្រាន់តែជាទ្រឹស្តី ជាសម្មតិកម្ម ដូចអល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿مَّآ أَشۡهَدتُّهُمۡ خَلۡقَ ٱلسَّمَٰوَٰتِ وَٱلۡأَرۡضِ وَلَا خَلۡقَ أَنفُسِهِمۡ وَمَا كُنتُ مُتَّخِذَ ٱلۡمُضِلِّينَ عَضُدٗا ٥١﴾ الكهف : ٥١

មានន័យថា៖ «យើងពុំបានឱ្យពួកគេមកមើលក្នុងការបង្កើតមេឃ និងផែនដី ហើយពុំបានឱ្យពួកគេមកមើលផងដែរក្នុងការបង្កើត

ពួកគេខ្លួនឯង យើងពុំបានយកពួកអ្នកដែលធ្វើឱ្យគេវង្វេងនោះមកធ្វើជាអ្នកគាំទ្រយើងឡើយ» ។

អល់ឡោះជាម្ចាស់បានមានព្រះបន្ទូលទៀតថា៖

﴿أَوَلَمْ يَرَ الَّذِينَ كَفَرُوا أَنَّ السَّمَاوَاتِ وَالْأَرْضَ كَانَتَا رَتْقًا فَفَتَقْنَاهُمَا ۖ وَجَعَلْنَا مِنَ الْمَاءِ كُلَّ شَيْءٍ حَيٍّ ۖ أَفَلَا يُؤْمِنُونَ ﴿٣٠﴾﴾ الأنبياء : ٣٠

មានន័យថា៖ «តើពួកអ្នកដែលបដិសេធនឹងជំនឿមិនឃើញទេឬថា មេឃនិងផែនដីពីមុនជាភពតែមួយ បន្ទាប់មកយើងបានបំបែកវាទាំងពីរ ហើយយើងបានបង្កើតអ្វីគ្រប់បែបយ៉ាងឱ្យមានជីវិតដោយសារទឹក តើពួកគេមិនព្រមមានជំនឿទេឬ?» ។

ព្រះបន្ទូលដ៏ប្រពៃនេះជាភស្តុតាងបញ្ជាក់យ៉ាងច្បាស់ថា ភពដែលយើងកំពុងរស់នៅជាភពមួយដែលមានការចាប់ផ្តើមកកើត ដោយអល់ឡោះបានបង្កើតពីភពផ្កាយបឋមមួយ (ដំណាក់កាលរួមតូច) ហើយទ្រង់មានអានុភាពលើអ្វីគ្រប់យ៉ាង។ បន្ទាប់មក អល់ឡោះទ្រង់បញ្ជាឱ្យផ្ទុះភពផ្កាយបឋមនោះឡើង ហៅថា (ដំណាក់កាលផ្ទុះដ៏មហិមា)។ ភពផ្កាយបឋមដែលផ្ទុះនេះបានក្លាយជាដុំផ្សែង (ដំណាក់កាលជាផ្សែង) ហើយអល់ឡោះបង្កើតចេញពីផ្សែងនោះនូវ ពភផែនដីនិងមេឃ (បានសេចក្តីថា ពភផ្កាយទាំងឡាយនៅពាសពេញលើមេឃកើតចេញពីសារធាតុ និងថាមពលផ្សេងៗគ្នា ខ្លះយើងស្គាល់ ហើយខ្លះទៀតយើងមិនស្គាល់)។ អ្នកដឹងទេដំណាក់កាលនេះមានឈ្មោះថា (ដំណាក់កាលបង្កើតដី និងមេឃ) មានរៀបរាប់ពីបាតុភូតដំណាក់កាលទាំងពីរចុងក្រោយក្នុងបន្ទូលរបស់ទ្រង់ថា៖

﴿قُلۡ أَئِنَّكُمۡ لَتَكۡفُرُونَ بِٱلَّذِي خَلَقَ ٱلۡأَرۡضَ فِي يَوۡمَيۡنِ وَتَجۡعَلُونَ لَهُۥٓ أَندَادٗاۚ ذَٰلِكَ رَبُّ ٱلۡعَٰلَمِينَ ٩ وَجَعَلَ فِيهَا رَوَٰسِيَ مِن فَوۡقِهَا وَبَٰرَكَ فِيهَا وَقَدَّرَ فِيهَآ أَقۡوَٰتَهَا فِيٓ أَرۡبَعَةِ أَيَّامٖ سَوَآءٗ لِّلسَّآئِلِينَ ١٠ ثُمَّ ٱسۡتَوَىٰٓ إِلَى ٱلسَّمَآءِ وَهِيَ دُخَانٞ فَقَالَ لَهَا وَلِلۡأَرۡضِ ٱئۡتِيَا طَوۡعًا أَوۡ كَرۡهٗا قَالَتَآ أَتَيۡنَا طَآئِعِينَ ١١﴾

فصلت : ٩-١١

មានន័យថាៈ «មូហាំម៉ាត់ចូរនិយាយទៅកាន់ពួកគោរពពហុទេពនិយមថា ខ្ញុំពិតជាឆ្ងល់ចំពោះពួកអ្នកដែលបានបដិសេធមិនព្រមជឿចំពោះព្រះជាម្ចាស់ដែលទ្រង់បានបង្កើតផែនដីក្នុងរយៈពេលពីរថ្ងៃ។ ពួកអ្នកបង្កើតជាដៃគូសម្រាប់ទ្រង់ និងអ្នកចូលហ៊ុនជាមួយទ្រង់ក្នុងការគោរពសក្ការៈ។ ទ្រង់ដែលបានបង្កើតនោះគឺជាព្រះជាម្ចាស់នៃសកលលោកទាំងមូល។ ទ្រង់បានបង្កើតឱ្យមានភ្នំចុះពីលើមេឃមកផែនដី ទ្រង់បានប្រទានពរជ័យដល់ផែនដី ទ្រង់បានកំណត់ស្បៀងអាហារសម្រាប់ផែនដីរួចរាល់ក្នុងរយៈពេលបួនថ្ងៃ ប្រាប់ជាដំណឹងដល់នរណាដែលសួរចង់ដឹងពីរឿងនេះ។ បន្ទាប់មក ទ្រង់បានប្រាថ្នាបង្កើតមេឃ ហើយមេឃនៅជាផ្សែងនៅឡើយ ទ្រង់បានត្រាស់បន្ទូលទៅមេឃ និងផែនដីថា សូមឱ្យកើតជាមេឃនិងដីដោយគោរពតាម ឬដោយបង្ខំ។ មេឃនិងដីបានតបទៅព្រះជាម្ចាស់វិញថាយើងកើតជាមេឃកើតជាដីដោយស្តាប់បង្គាប់ព្រះអង្គ» ។

អ្នកប្រាជ្ញខាងរូបវិទ្យាសម័យទំនើបបានទទួលស្គាល់ថា ដើមកំណើតដំបូងនៃការកកើតភព ព្រមទាំងអ្វីទាំងឡាយទាំងពួងដែលមានក្នុងភពទាំងសារធាតុដើម កម្លាំងថាមពល និងថេរវេលា កើត

ចេញពីអ្វីដែលគេហៅឈ្មោះ ថា (ការផ្ទុះដ៏មហិមា ជាភាសាអង់គ្លេសហៅថា The Big Bang) ដែលជាភស្តុតាងបញ្ជាក់ថាវាកើតចេញពីគ្នាន។ សូមក្រឡេកមើលបន្ទូលរបស់អល់ឡោះ

﴿ ثُمَّ ٱسْتَوَىٰٓ إِلَى ٱلسَّمَآءِ وَهِيَ دُخَانٌ فَقَالَ لَهَا وَلِلْأَرْضِ ٱئْتِيَا طَوْعًا أَوْ كَرْهًا قَالَتَآ أَتَيْنَا طَآئِعِينَ ﴿١١﴾ ﴾ فصلت : ١١

មានន័យថា៖ «បន្ទាប់មក ទ្រង់បានប្រាថ្នាបង្កើតមេឃ ហើយមេឃនៅជាផ្សែងនៅឡើយ ទ្រង់បានត្រាស់បន្ទូលទៅមេឃ និងផែនដីថា សូមឱ្យកើតជាមេឃនិងដីដោយគោរពតាម ឬដោយបង្ខំ។ មេឃនិងដីបានតបទៅព្រះជាម្ចាស់វិញថា យើងកើតជាមេឃកើតជាដីដោយស្តាប់បង្គាប់ព្រះអង្គ» ។

គម្ពីរអាល់គួរអានប្រកាសប្រាប់ក្នុងបន្ទូលនេះថា ពិតប្រាកដមេឃនៅពេលចាប់ផ្តើមកកើតដំបូងបានឆ្លងកាត់កាលភាគមួយដែលហៅថាកាលភាគដុំផ្សែង។ វិទ្យាសាស្ត្រទំនើបបានទទួលស្គាល់ពីរឿងនេះ។ លោកបណ្ឌិត ចច គ្គាមូវ និយាយថា ដំបូងឡើយភពពោរពេញដោយល្បាយហ្គាសជាប្រព័ន្ធ កើតចេញពីល្បាយហ្គាសនេះនូវបម្រែបម្រួលបរមេណូមួយដែលមានធាតុផ្សំច្រើនផ្សេងគ្នា។

លោក ដេម ហេនហ្សៀ ជាតារាវិទូម្នាក់និយាយថា៖ ជាក់ច្បាស់ណាស់ថា ធាតុបង្កើតភពផ្តើមដោយបណ្តុំហ្គាសដែលអណ្តែតពាសពេញលំហជាប្រព័ន្ធ ហើយផ្សេងនេបូឡាកើតចេញពីកំហាប់ហ្គាសដ៏ក្រាស់នេះ។

## គម្ពីរអាល់គួរអាន និងការលោតសន្ទឹងនៃភព

អល់ឡោះជាម្ចាស់បានមានព្រះបន្ទូលថា៖

﴿وَٱلسَّمَآءَ بَنَيۡنَٰهَا بِأَيۡيْدٖ وَإِنَّا لَمُوسِعُونَ ٤٧﴾ الذاريات: ٤٧

មានន័យថា៖ «មេឃយើងបានបង្កើតជាដំបូលសម្រាប់ផែនដីដោយអានុភាពដ៏ខ្លាំងក្លាជាទីបំផុត ហើយយើងជាអ្នកពង្រីកវិសាលភាពរបស់វា» ។

អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលទៀតថា៖

﴿أَوَلَمۡ يَرَ ٱلَّذِينَ كَفَرُوٓاْ أَنَّ ٱلسَّمَٰوَٰتِ وَٱلۡأَرۡضَ كَانَتَا رَتۡقٗا فَفَتَقۡنَٰهُمَاۖ وَجَعَلۡنَا مِنَ ٱلۡمَآءِ كُلَّ شَيۡءٍ حَيٍّۚ أَفَلَا يُؤۡمِنُونَ ٣٠﴾ الأنبياء : ٣٠

មានន័យថា៖ "តើពួកអ្នកដែលបដិសេធនឹងជំនឿមិនឃើញទេឬថាមេឃនិងផែនដីពីមុនជាភពតែមួយ បន្ទាប់មកយើងបានបំបែកវាទាំងពីរ ហើយយើងបានបង្កើតអ្វីគ្រប់បែបយ៉ាងឱ្យមានជីវិតដោយសារទឹក តើពួកគេមិនព្រមមានជំនឿទេឬ?"។

អល់ឡោះជាម្ចាស់បានមានព្រះបន្ទូលទៀតថា៖

﴿ثُمَّ ٱسۡتَوَىٰٓ إِلَى ٱلسَّمَآءِ وَهِيَ دُخَانٞ فَقَالَ لَهَا وَلِلۡأَرۡضِ ٱئۡتِيَا طَوۡعًا أَوۡ كَرۡهٗا قَالَتَآ أَتَيۡنَا طَآئِعِينَ ١١﴾ فصلت : ١١

មានន័យថា៖ «បន្ទាប់មក ទ្រង់បានប្រាថ្នាបង្កើតមេឃ ហើយមេឃជាផ្សែងនៅឡើយ ទ្រង់បានត្រាស់បន្ទូលទៅមេឃ និងផែនដីថា សូមឱ្យកើតជាមេឃនិងដីដោយគោរពតាម ឬដោយបង្ខំ។ មេឃនិងដីបានតប

ទៅព្រះជាម្ចាស់វិញថា យើងកើតជាមេឃកើតជាដីដោយស្តាប់បង្គាប់ព្រះអង្គ» ។

អល់ឡោះជាម្ចាស់បានមានព្រះបន្ទូលទៀតថា៖

﴿ يَوْمَ نَطْوِي السَّمَاءَ كَطَيِّ السِّجِلِّ لِلْكُتُبِ كَمَا بَدَأْنَا أَوَّلَ خَلْقٍ نُّعِيدُهُ وَعْدًا عَلَيْنَا إِنَّا كُنَّا فَاعِلِينَ ﴿١٠٤﴾ ﴾ الأنبياء : ١٠٤

មានន័យថា៖ «ថ្ងៃដែលយើងនឹងបត់មេឃដូចជាបត់ទំព័រសៀវភៅ ដូចដែលបានចាប់ផ្តើមបង្កើតដំបូង យើងនឹងបង្កើតវាឡើងវិញម្តងទៀតជាការសន្យាដ៏ពិតប្រាកដរបស់យើង។ យើងតែងតែអនុវត្តតាមពាក្យសន្យារបស់យើងជានិច្ច» ។

អល់ឡោះជាម្ចាស់បានមានព្រះបន្ទូលទៀតថា៖

﴿ يَوْمَ تُبَدَّلُ الْأَرْضُ غَيْرَ الْأَرْضِ وَالسَّمَاوَاتُ وَبَرَزُوا لِلَّهِ الْوَاحِدِ الْقَهَّارِ ﴿٤٨﴾ ﴾ إبراهيم : ٤٨

មានន័យថា៖ «ថ្ងៃដែលគេនឹងប្តូរដីមិនមែនដីនេះ ប្តូរមេឃ មិនមែនមេឃនេះ ហើយសព្វសត្វទាំងឡាយក្រោកចេញពីផ្នូរដើម្បីមកជួបអល់ឡោះជាម្ចាស់ដ៏មហាខ្លាំងពូកែ» ។

ព្រះបន្ទូលទាំងប៉ុន្មានខាងលើជាភស្តុតាងបញ្ជាក់ថា ភពដែលយើងរស់នៅកំពុងតែលាតសន្ធឹងជាប្រចាំ ប្រសិនបើយើងក្រឡេកមកក្រោយឡើងវិញជាមួយនិងការលាតសន្ធឹងនេះ នៅពេលណាមួយចាំបាច់ត្រូវតែរួមគ្នាជាភពផ្កាយតែមួយឡើវិញ (ដំណាក់កាលរួមតូច) ដែលបានលើកឡើងខាងលើ ហើយភពផ្កាយបឋមនេះបានផ្ទុះដោយការបង្គាប់ពីអល់ឡោះជាម្ចាស់ (ដំណាក់កាលផ្ទុះដ៏មហិមា) បាន

ក្លាយជាបណ្តុំផ្សែងនេបូឡា (ដំណាក់កាលក្លាយជាផ្សែង) ដែលគេបង្កើតបានជាភពផែនដី និងមេឃ (ដំណាក់កាលកកើត)។ តាំងពីចាប់ផ្តើមផ្ទុះមកភពនៅតែបន្តលាតសន្ធឹងទំហំរបស់វា ហើយការលាតសន្ធឹងនេះនឹងត្រូវបញ្ឈប់នៅពេលអនាគតដែលគ្មាននរណាដឹងលើកលែងតែអល់ឡោះ។ ដោយការបង្គាប់ពីអល់ឡោះភពនឹងចាប់ផ្តើមរួមឡើងវិញក្លាយទៅជាភពផ្កាយតែមួយរាងដូចភពផ្កាយបឋមដំបូងដែលបានចាប់ផ្តើមកកើតមេឃ និងផែនដី។ ដំណើរការនៃការផ្ទុះនឹងកើតឡើងម្តងទៀត ហើយការផ្ទុះនោះនឹងប្រែក្លាយជាបណ្តុំផ្សែង ហើយកកើតចេញពីផ្សែងនោះផែនដី ដែលមិនដូចផែនដីយើងសព្វថ្ងៃ មេឃដែលមិនដូចជាមេឃសព្វថ្ងៃ ត្រឹមដំណាក់កាលនេះ ជីវិតលោកីយ៍ត្រូវបានបញ្ចប់ ហើយចាប់ផ្តើមដំណាក់កាលជីវិតបរលោក។ ដំណាក់កាលរួមតូច ដំណាក់កាលផ្ទុះ ដំណាក់កាលក្លាយជាផ្សែង និងដំណាក់កាលកកើតមេឃនិងដី ហើយនិងការលាតសន្ធឹងនៃភព បន្ទាប់មកត្រូវរួមតូចវិញ ឆ្លុះឱ្យឃើញជាសកលនូវដំណាក់កាលកកើត ដំណាក់កាលវិនាស និងការកកើតឡើងវិញ។ វិទ្យាសាស្ត្រពិតក្នុងគម្ពីអាល់គួរអានទាំងនេះ មនុស្សលោកមិនអាចស្វែងយល់បានទេ លើកលែងតែនៅចុងសតវត្សទី២០នេះប៉ុណ្ណោះទើបអាចស្រាវជ្រាវរកឃើញពីអ្វីដែលគម្ពីរអាល់គួរអានបញ្ជាក់ប្រាប់មុនតាំងពីជាង១៤សតវត្សកន្លងមក។ គ្រាន់តែរឿងនេះតែមួយគត់ ជាសាក្សីបញ្ជាក់ប្រាប់ថា គម្ពីរអាល់គួរអាន ពិតជាពាក្យបន្ទូលរបស់អល់ឡោះ ជាម្ចាស់យ៉ាងពិតប្រាកដ។ ក៏ដូចជាបញ្ជាក់ថា អ្នកនាំសារចុងក្រោយបង្អស់។ គាត់ពិតជាមានទំនាក់ទំនងជាមួយនឹងការត្រាស់បង្គាប់របស់ព្រះ ហើយក៏ជាបរមគ្រូមកពី

ព្រះជាម្ចាស់ដែលបានបង្កើតមេឃ និងផែនដី។ ពីព្រោះគ្មានមនុស្សណាម្នាក់អាចដឹងពីវិទ្យាសាស្ត្រពិតទាំងនេះនៅសម័យគេបញ្ចុះព្រះគម្ពីរ ហើយក៏គ្មានផងដែរនៅរាប់សិបសតវត្សក្រោយការបញ្ចុះព្រះគម្ពីរ។ (លោកសាស្ត្រាចារ្យបណ្ឌិត ហ្សគ្គលូល អាន់ណ័ចជើរ)

ពួកតារាវិទូសម័យបច្ចុប្បន្នរកឃើញថា ភពកំពុងមានចលនាជាប្រចាំ លាតសន្ធឹង និងពង្រីកខ្លួន ដោយការឆ្លុះមើលកាឡាក់ស៊ី និងភពផ្កាយទាំងឡាយនៅលើមេឃក្នុងរយៈចំងាយឆ្ងាយបំផុត។ វិទ្យាសាស្ត្រពិតនេះ តារាវិទូអាមេរិកឈ្មោះ ហ្វ.ម. ស្លៃហ្វើរ បានធ្វើការឆ្លុះមើលកាឡាក់ស៊ីមួយចំនួនដែលនៅក្រៅពីកាឡាក់ស៊ីរបស់យើង (មិលគីវ៉េ) ឃើញថា កាឡាក់ស៊ីភាគច្រើនកំពុងតែឃ្លាតឆ្ងាយពីយើង និងឃ្លាតឆ្ងាយពីគ្នាក្នុងល្បឿនលឿនជាទីបំផុត។ ក៏ដូចគ្នាដែរ រូបវិទូជំនាញខាងលំហអាកាសនៅដើមសតវត្សទី២០ ឈ្មោះ ចច ឡូមីនហ្វ និងតារាវិទូអាមេរិក ឈ្មោះ អេវីន ហាបេល ដែលបានបញ្ជាក់ពីបាតុភូទដំណើរលាតសន្ធឹងនៃភព។ ពិតណាស់ ផ្កាយ និងកាឡាក់ស៊ីទាំងឡាយកំពុងធ្វើចលនាឃ្លាតឆ្ងាយពីគ្នាជាប្រចាំ ការលាតសន្ធឹងនេះនឹងពង្រីកខ្លួនក្នុងទំហំដែលគ្មានការកំណត់។ ដូច្នេះ ទើបពួកអ្នកវិទ្យាសាស្ត្របានកំណត់ថា ភពទាំងមូលកំពុងលាតសន្ធឹង និងពង្រីកខ្លួនដោយការឃ្លាតចេញពីគ្នារវាងកាឡាក់ស៊ីនីមួយៗ ហើយការលាតសន្ធឹងនេះនឹងប្រព្រឹត្តទៅមុខជានិច្ចរហូតដល់អស់កម្លាំងទំនាញ ដែលត្រួតត្រាលើកាឡាក់ស៊ីទាំងនោះ។ នៅពេលនោះកាឡាក់ស៊ីទាំងឡាយនឹងត្រូវរប៉ាត់រប៉ាយពាសពេញក្នុងលំហ ដែលនឹងបង្កឱ្យវិនាសពិភពលោក។

ត្រូវនឹងបន្ទូលរបស់អល់ឡោះដែលនិយាយអំពីទីបញ្ចប់នៃពិភពលោក និងការកើតថ្ងៃបរលោកថា៖

﴿إِذَا ٱلسَّمَآءُ ٱنفَطَرَتۡ ١ وَإِذَا ٱلۡكَوَاكِبُ ٱنتَثَرَتۡ ٢﴾
سورة الانفطار/ الآية: ١-٢

មានន័យថា៖ «នៅពេលដែលមេឃផ្ទុះ ហើយខូចខាតប្រព័ន្ធរបស់វា។ នៅពេលដែលភពផ្កាយទាំងឡាយធ្លាក់ប៉ះទង្គិចគ្នា» ។

**គម្ពីរអាល់គួរអាន និងតារាសាស្ត្រ**

អល់ឡោះជាម្ចាស់បានមានព្រះបន្ទូលថា៖

﴿ٱللَّهُ ٱلَّذِي رَفَعَ ٱلسَّمَٰوَٰتِ بِغَيۡرِ عَمَدٖ تَرَوۡنَهَا﴾ الرعد : ٢

មានន័យថា៖ «អល់ឡោះជាម្ចាស់ដែលបានលើកមេឃ៧ជាន់ឱ្យខ្ពស់ដោយគ្មាន សសរទល់ ដូចជាពួកអ្នកទាំងអស់គ្នាមើលឃើញស្រាប់» ។

ការសិក្សាស្រាវជ្រាវផ្នែកតារាសាស្ត្របានចង្អុលបង្ហាញថាមានកម្លាំងថាមពលបង្កប់ក្នុងផ្ទៃស្និតនៃសារធាតុទាំងឡាយ មាននៅក្នុងអាតូម ក្នុងសាជាតុផ្សំ និងភពផ្កាយទាំងឡាយ។ កម្លាំងថាមពលនេះជាអ្នកត្រួតត្រាប្រព័ន្ធភពទាំងមូល និងរក្សាដែនកំណត់របស់វារហូតដល់ពេលដែលអល់ឡោះជាម្ចាស់ទ្រង់សព្វព្រះទ័យ ទ្រង់នឹងធ្វើឱ្យវាវិនាសហើយទ្រង់បង្កើតឡើងវិញម្តងទៀតនូវប្រព័ន្ធថ្មីមួយ។ កម្លាំងថាមពលដែលពួកអ្នកប្រាជ្ញបានរកឃើញទាំងនៅលើផែនដីនិងនៅលើមេឃមានបួនរូបភាព ពួកគេជឿជាក់ថា កម្លាំងថាមពលទាំងបួននេះមានទិសផ្សេងៗគ្នាឋិតក្រោមកម្លាំងថាមពលធំមហិមាមួយគ្របដណ្តប់លើគ្រប់ផ្នែកទាំងអស់នៃភព ដើម្បីចងជាប្រព័ន្ធមួយរឹងមាំ បើពុំដូច្នោះ

ទេ នឹងបាត់បង់ប្រព័ន្ធគ្រប់គ្រង ហើយកម្លាំងថាមពលទាំងនោះមានដូចជា៖

* **<u>កម្លាំងថាមពលបរមណូខ្លាំង:</u>** ជាកម្លាំងថាមពលមានតួនាទីចងភ្ជាប់សារធាតុផ្សំដំបូងនៃរូបធាតុនៅក្នុងគ្រាប់អាតូម ដោយការចងភ្ជាប់ដ៏រឹងមាំជាទីបំផុត មានដូចជា ប្រូតូណាត នីត្រូណាត និងសារធាតុស្អិតដំបូងដែលគេឱ្យឈ្មោះថា កូវ៉ាកាតដោយមានប្រភេទខុសៗគ្នា និងធាតុផ្ទុយរបស់វា។ ថាមពលនេះក៏មានតួនាទីរំលាយចូលគ្នារវាងគ្រាប់អាតូមនីមួយៗក្នុងដំណើររំលាយចូលគ្នាដោយកម្លាំងបរមណូ...។
* **<u>កម្លាំងថាមពលអាតូមិកខ្សោយ:</u>** ជាថាមពលខ្សោយមានកម្រិតខ្សោយបំផុតមិនលើសពីកម្លាំងអាតូម មានតួនាទីរៀបចំដំណើរការជាលិកាវិភាគអាណូតូចៗរបស់រូបធាតុក្នុងអាតូម ដូចជាកើតឡើងក្នុងដំណើរជាលិកាវិភាគនៃរូបធាតុកាំរស្មីស្វ័យអ៊ុលត្រា។ ថាមពលនេះត្រួតត្រាលើដំណើរកាជាលិកាវិភាគរបស់រូបធាតុកាំរស្មីស្វ័យអ៊ុលត្រាដោយការបំភាយកាំរស្មីស្វ័យអ៊ុលត្រា។ គ្រប់រូបធាតុនីមួយៗមានអាយុកាលកំណត់របស់វា។ ថាមពលនេះ ផ្ទុកក្នុងជាលិកាទាំងអស់ដោយសញ្ញាជក ឬគ្មានបន្ទុកអគ្គិសនីដែលគេឱ្យឈ្មោះថា បូហ្សូណាត។
* **<u>កម្លាំងថាមពលអគ្គិសនីម៉ាញ៉េទិក:</u>** ជាកម្លាំងចងភ្ជាប់រវាងអាតូមទាំងឡាយនៅក្នុងសារធាតុផ្សំនានា ដែលផ្តល់សម្រាប់រូបធាតុផ្សេងៗមានលក្ខណៈបែបធម្មជាតិ និងតាមបែបគីមី។

* **កម្លាំងទំនាញ**:កម្លាំងនេះនៅរយៈចម្ងាយខ្លី គេចាត់ទុកជាកម្លាំងដ៏ខ្សោយជាទីបំផុតដែលយើងបានស្គាល់ក៏ប៉ុន្តែក្នុងរយៈចម្ងាយឆ្ងាយមានកម្លាំងទំនាញខ្លាំងមហិមានៅក្នុងភពដោយសង្កេតទៅលើការកើនឡើងតាមបែបធម្មជាតិរបស់វា ដែលអាចរក្សា កាឡាក់ស៊ីទាំងឡាយឱ្យមានលំនឹងតាមក្រុមកាឡាក់ស៊ីនីមួយៗ។

អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿وَهُوَ ٱلَّذِى خَلَقَ ٱلَّيْلَ وَٱلنَّهَارَ وَٱلشَّمْسَ وَٱلْقَمَرَ ۖ كُلٌّ فِى فَلَكٍ يَسْبَحُونَ ﴿٣٣﴾﴾ الأنبياء : ٣٣

មានន័យថា៖ «ទ្រង់គឺជាព្រះដែលបានបង្កើតពេលយប់និងថ្ងៃ ព្រះអាទិត្យនិងព្រះច័ន្ទ។ ទាំងអស់នេះឋិតក្នុងគន្លងកំពុងធ្វើចលនា»។

អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលទៀតថា៖

﴿وَٱلشَّمْسُ تَجْرِى لِمُسْتَقَرٍّ لَّهَا ۚ ذَٰلِكَ تَقْدِيرُ ٱلْعَزِيزِ ٱلْعَلِيمِ ﴿٣٨﴾ وَٱلْقَمَرَ قَدَّرْنَٰهُ مَنَازِلَ حَتَّىٰ عَادَ كَٱلْعُرْجُونِ ٱلْقَدِيمِ ﴿٣٩﴾ لَا ٱلشَّمْسُ يَنۢبَغِى لَهَآ أَن تُدْرِكَ ٱلْقَمَرَ وَلَا ٱلَّيْلُ سَابِقُ ٱلنَّهَارِ ۚ وَكُلٌّ فِى فَلَكٍ يَسْبَحُونَ ﴿٤٠﴾﴾ يس : ٣٨-٤٠

មានន័យថា៖ «ព្រះអាទិត្យដើរតាមគន្លងដែលអល់ឡោះជាម្ចាស់បានកំណត់។ នេះជាការកំណត់របស់ព្រះដ៏មានតេជានុភាពខ្លាំងក្លា មហាដឹង។ ព្រះចន្ទ ទ្រង់បានកំណត់ឱ្យមានលំដាប់ខ្នើត និងរនោចរៀងរាល់យប់ ចាប់ផ្តើមពីមួយខ្នើតរហូតដល់ពេញវង្ស បន្ទាប់មកក៏ចាប់ផ្តើមរោចទៅវិញរហូតដល់មានរាងដូចជាធ្លាយល្មើចាស់ស្ងួតកោងស្តើង

ពណ៌រាងលឿង។ ព្រះអាទិត្យមិនអាចតាមទាន់ព្រះចន្ទដែលនឹងធ្វើឱ្យព្រះចន្ទបាត់បង់ពន្លឺ ឬប្តូរគន្លងដើរ យប់ និងថ្ងៃមិនអាចដើរជាន់គ្នាមុនពេលកំណត់។ ទាំងព្រះអាទិត្យ ព្រះចន្ទ និងភពផ្សេងៗទៀតកំពុងតែធ្វើចលនាក្នុងគន្លងរៀងៗខ្លួន» ។

ក្នុងព្រះបន្ទូលខាងលើគម្ពីរអាល់គួរអានបានប្រាប់ថា ព្រះអាទិត្យកំពុងធ្វើចលនាក្នុងទិសមួយកំណត់ច្បាស់លាស់ ដែលពីមុនគេគិតថាព្រះអាទិត្យនៅនឹងថ្កល់។ តែពួកតារាវិទូបានទទួលស្គាល់ថា ព្រះអាទិត្យមានចលនាពិតប្រាកដនៅក្នុងលំហមួយមានកម្រិត និងទិសដែលបានកំណត់។ ភពដទៃទៀត និងផ្កាយទាំងឡាយធ្វើចលនាជាមួយនិងព្រះអាទិត្យដែលឋិតនៅក្នុងប្រព័ន្ធព្រះអាទិត្យ។ គ្រប់ផ្កាយនីមួយៗធ្វើចលនាតាមរបៀបមួយស្រដៀងៗគ្នា។ ព្រះអាទិត្យមិនអាចដើរទាន់ព្រះចន្ទ ភពទាំងអស់មិនអាចជួបគ្នា ផ្កាយនីមួយៗធ្វើចលនាក្នុងអ័ក្សស្របគ្នា។ វិទ្យាសាស្ត្រទំនើបមិនទាន់រកឃើញរឿងនេះ លើកលែងតែនៅសតវត្សទី២០នេះប៉ុណ្ណោះ។

អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿وَٱلسَّمَآءِ ذَاتِ ٱلۡحُبُكِ ۝٧﴾ الذاريات : ٧

មានន័យថា៖ «ទ្រង់ស្បថនឹងមេឃដែលមានសុក្រឹតភាពល្អឥតខ្ចោះ» ។

អាល់ហូពុក (الحبك) មានន័យថា ការបង្កើតដ៏សុក្រឹតឥតខ្ចោះដែលពួកតារាវិទូបានកំណត់ផ្នែកដែលអាចដឹងបាននៃភពមានពីររយពាន់លានកាឡាក់ស៊ី យ៉ាងហោចណាស់មាន៧០ពាន់លានកោដិផ្កាយ។

កាឡាក់ស៊ីទាំងនោះមានរូបរាង សណ្ឋាណ ទំហំ ល្បឿន ម៉ាស ខុសៗគ្នា។ ជាមួយនោះ ក៏ខុសគ្នាផងដែរល្បឿនដើរជុំវិញខ្លួនឯង ល្បឿនធ្វើចលនាជុំវិញគន្លង ល្បឿននៃដំណើរឃ្លាតឆ្ងាយពីយើង និង ឃ្លាតឆ្ងាយពីផ្កាយដូចគ្នា។ លើសពីនេះ ដំណាក់កាលនៃការវិវឌ្ឍ ចំនួនផ្កាយ និងដំណាក់កាលនៃជីវិតទាំងនោះក៏ខុសគ្នាផងដែរ។

អាល់ហូពុក (الحبك) មានន័យថា មានចងសម្ព័ន្ធភាពនឹងគ្នា យ៉ាងរឹងមាំជាទីបំផុត ចំនួនដ៏ច្រើនលើសលុបនៃកាឡាក់ស៊ីដែលយើង ស្គាល់នៃមេឃលោកីយ៍ (ប្រហែលជាមិនលើសពី១០% នៃចំនួនសរុប របស់បណ្តុំកាឡាក់ស៊ីដែលគេស្គាល់នៃភព) ចាំបាច់ត្រូវតែមានកម្លាំង ថាមពលគ្រប់គ្រងលើកម្លាំងស្អិតជាប់នៃកាឡាក់ស៊ីខ្លួនឯងផង ជាមួយ និងកាឡាក់ស៊ីផ្សេងផង និងគ្រប់គ្រងកម្លាំងស្អិតជាប់នៃរូបធាតុផ្សេងៗ និងកម្លាំងថាមពលផ្សេងៗដែលមាននៅក្នុងរូបធាតុទាំងនោះ។ បើពុំ ដូច្នោះទេ ភពទាំងមូលនឹងត្រូវវិនាសអន្តរាយជាមិនខាន។ ដូច អល់ឡោះជាម្ចាស់ទ្រង់បានបន្ទូលថា៖

﴿إِنَّ ٱللَّهَ يُمۡسِكُ ٱلسَّمَٰوَٰتِ وَٱلۡأَرۡضَ أَن تَزُولَاۚ وَلَئِن زَالَتَآ إِنۡ أَمۡسَكَهُمَا مِنۡ أَحَدٖ مِّنۢ بَعۡدِهِۦٓ﴾ فاطر : ٤١

មានន័យថា៖ «ពិតប្រាកដ អល់ឡោះជាម្ចាស់ទ្រង់រក្សាការពារមេឃ និងផែនដីមិនឱ្យដើរខុសគន្លងរបស់វា។ បើសិនជាមេឃ និងដីដើរខុស គន្លងទៅហើយនោះ។ តើមាននរណាផ្សេងក្រៅពីទ្រង់អាចរក្សាការពារ បាន» ។

អាល់ហូពុក (الحبك) មានន័យថា មានគន្លងដែលមានដែនកំណត់សម្រាប់គ្រប់ភពផ្កាយនីមួយៗ។ ជារឿងមួយគួរឱ្យភ្ញាក់ផ្អើលសម្រាប់ពួកអ្នកប្រាជ្ញព្រោះភពផ្កាយច្រើនពេកដែលមាននៅក្នុងកឡាក់ស៊ីដែលគេស្គាល់។ ប្រាជ្ញារបស់មនុស្សមិនដែលគិតដល់ភពផ្កាយទាំងនោះថា មានគន្លងនិងកម្រិតខុសគ្នាមិនអាចប៉ះទង្គិតគ្នាសូម្បីបន្តិចមានប្រព័ន្ធគ្រប់គ្រងល្អិតល្អន់ទាំងពេលជិតស្លាប់ ពេលបាត់បង់ពន្លឺនិងពេលរលត់សូន្យឈឹង និងពេលផ្ទុះក្លាយជាផេះ កម្ទេចកម្ទីដែលខ្ទាតរប៉ាត់រប៉ាយ និងចំហាយរបស់វា។ ហេតុការណ៍នេះកើតឡើងនៅពេលភពផ្កាយណាមួយត្រូវផ្ទុះ ថ្វីបើមានគន្លងនិងចលនាយ៉ាងមមាញឹកនៃភពផ្កាយជាច្រើនផ្សេងទៀតនៅក្នុងកាឡាក់ស៊ីតែមួយ។

អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿ هُوَ ٱلَّذِى جَعَلَ ٱلشَّمْسَ ضِيَآءً وَٱلْقَمَرَ نُورًا وَقَدَّرَهُۥ مَنَازِلَ لِتَعْلَمُوا۟ عَدَدَ ٱلسِّنِينَ وَٱلْحِسَابَ ۚ مَا خَلَقَ ٱللَّهُ ذَٰلِكَ إِلَّا بِٱلْحَقِّ ۚ يُفَصِّلُ ٱلْـَٔايَـٰتِ لِقَوْمٍ يَعْلَمُونَ ۝٥ ﴾ يونس : ٥

មានន័យថា៖ «ទ្រង់គឺជាព្រះដែលបានបង្កើតព្រះអាទិត្យឱ្យមានរស្មីហើយព្រះចន្ទមានពន្លឺ ទ្រង់បានកំណត់ឱ្យព្រះចន្ទមានលំដាប់ខ្នើតនិងរនោច ដើម្បីឱ្យពួកអ្នកដឹងពីចំនួនឆ្នាំ និងថ្ងៃខែ។ អល់ឡោះទ្រង់ពុំបានបង្កើតអ្វីទាំងនោះមក លើកលែងតែជារឿងសច្ចៈ ទ្រង់បកស្រាយអំពីនិមិត្តសញ្ញាទាំងឡាយសម្រាប់ពួកអ្នកដែលចេះដឹង» ។

ការបែងចែកលម្អិតបំផុតរវាងរស្មីដែលកើតចេញពីផ្ទៃ ដែលកំពុងឆាបឆេះបំភ្លឺដោយខ្លួនឯងនោះគឺព្រះអាទិត្យ និងពន្លឺដែលទៅប៉ះ

នឹងផ្ទៃងងឹតគ្មានចំហេះគឺ ព្រះចន្ទចាំងផ្លាតបានជាពន្លឺចេញពីផ្ទៃរបស់វា។ គម្ពីរអាល់គួរអានទាំងមូលគ្មានយកមកពីប្រភពណាផ្សេងតាំងពី ១៤០០ឆ្នាំមុន ក្រៅពីអល់ឡោះជាម្ចាស់ជាអ្នកបង្កើត។ ភាពខុសគ្នាដ៏ល្អិតល្អន់នេះ ពួកអ្នកប្រាជ្ញពុំទាន់រកឃើញនៅឡើយទេ លើកលែងតែនៅពីរសតវត្សចុងក្រោយនេះប៉ុណ្ណោះ។ រហូតមកដល់បច្ចុប្បន្នមនុស្សភាគច្រើននៅពុំទាន់ដឹងពីរឿងនេះនៅឡើយទេ។

## គម្ពីរអាល់គួរអាន និងសម្ពាធបរិយាកាស

អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿فَمَن يُرِدِ ٱللَّهُ أَن يَهۡدِيَهُۥ يَشۡرَحۡ صَدۡرَهُۥ لِلۡإِسۡلَٰمِۖ وَمَن يُرِدۡ أَن يُضِلَّهُۥ يَجۡعَلۡ صَدۡرَهُۥ ضَيِّقًا حَرَجٗا كَأَنَّمَا يَصَّعَّدُ فِي ٱلسَّمَآءِ﴾

الأنعام : ١٢٥

មានន័យថា៖ «នរណាអល់ឡោះទ្រង់សព្វព្រះទ័យចង់ឱ្យគេទទួលយកសេចក្ដីចង្អុលបង្ហាញ ទ្រង់បើកទ្រូងរបស់គេ ហើយនរណាទ្រង់សព្វព្រះទ័យចង់ឱ្យគេវង្វេង ទ្រង់ធ្វើឱ្យទ្រូងរបស់គេថប់ចង្អៀត បីដូចជាអ្នកដែលខំប្រឹងឡើងទៅលើស្រទាប់បរិយាកាសដ៏ខ្ពស់បំផុត» ។

ព្រះបន្ទូលនេះបានកំណត់ថា ការឡើងទៅលើមេឃកាន់តែខ្ពស់កាន់តែថប់ក្នុងការដកដង្ហើម មានអារម្មណ៍ដូចចង់ស្ទះខ្យល់ដោយមូលហេតុសម្ពាធបរិយាកាសខ្សោយ ហើយបរិមាណអ៊ុកស៊ីសែនក៏ថយចុះ។ វិទ្យាសាស្ត្រពិតនេះ មិនអាចកំណត់បានលុះត្រាតែមនុស្ស

ណាម្នាក់ឡើងទៅលើលំហអាកាស។ វិទ្យាសាស្រ្តពិតនេះគេបានស្គាល់នៅពេលដែលមនុស្សបានហោះហើរទៅក្នុងលំហអាកាស ដែលមានរយៈកម្ពស់ខ្ពស់បំផុត។

នៅពេលដែលមនុស្សឡើងហួសពី៨គីឡូម៉ែតនៃនីវ៉ូសមុទ្រ មនុស្សនឹងប្រឈមនឹងបញ្ហាជាច្រើនដូចជា ពិបាកដកដង្ហើដោយសារ ខ្វះអ៊ុកស៊ីសែន សម្ពាធខ្យល់ចុះខ្សោយ អាចកើតជំងឺខ្វះអ៊ុកស៊ីសែន បញ្ហាសម្ពាធបរិយាសចុះទាប ឬហៅម្យ៉ាងទៀតបានថា សម្ពាធបរិយា**កាស**បាត់បង់តុល្យភាព។ ធ្វើឱ្យប្រព័ន្ធរាងកាយរបស់មនុស្សប្រឈមនឹងបញ្ហាអង្គំណើរការ ធ្វើឱ្យមុខងារប្រព័ន្ធជីវសាស្រ្តរាងកាយឈប់ដំណើរការម្តងមួយៗ នេះអាចបកស្រាយពីខ្លឹមសារនៃពាក្យថប់ចង្អៀតទ្រូងដែលតែងកើតឡើងនៅពេលដែលមនុស្សឡើងកាន់តែខ្ពស់ដោយគ្មានឧបករណ៍ការពារគ្រប់គ្រាន់....។

## គម្ពីរអាល់គួរអាន និងភាពខ្វះខាតក្នុងលំហបរិយាកាសខ្ពស់បំផុត

អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿ وَلَوۡ فَتَحۡنَا عَلَيۡهِم بَابٗا مِّنَ ٱلسَّمَآءِ فَظَلُّواْ فِيهِ يَعۡرُجُونَ ١٤ لَقَالُوٓاْ إِنَّمَا سُكِّرَتۡ أَبۡصَٰرُنَا بَلۡ نَحۡنُ قَوۡمٞ مَّسۡحُورُونَ ١٥ ﴾ الحجر : ١٤-١٥

មានន័យថា៖ «បើសិនជាយើងបើកទ្វារមេឃទាំងឡាយឱ្យពួកគេហើយពួកគេនៅតែឡើងកាន់តែខ្ពស់នោះពួកគេនឹងនិយាយថា ក្រសែភ្នែករបស់យើងត្រូវស្រវាំងមើលមិនឃើញ តាមពិតពួកយើងត្រូវគេធ្មិនភ្នែក» ។

មនុស្សមានការជឿងឆ្ងល់ចំពោះការប្រៀបធៀបរបស់គម្ពីរអាល់គួរអានដ៏អស្ចារ្យដែលជាវិទ្យាសាស្ត្រពិតទាក់ទងនឹងភព។ មនុស្សពុំទាន់ដឹង លើកលែងតែក្រោយពេលដែលពួកអ្នកវិទ្យាសាស្ត្របានឡើងទៅក្នុងលំហអាកាសនៅដើមទសវត្សទី៦០នៃសតវត្សទី២០ នៅពេលនោះមានរឿងភ្ញាក់ផ្អើលកើតឡើងដោយសាររកឃើញថា ភពទាំងមូលគ្របដណ្តប់ដោយភាពងងឹតស្ទើរតែទាំងស្រុង ហើយវណ្ណៃថ្ងៃបំភ្លឺពាក់កណ្តាលផែនដីប្រឈមនឹងព្រះអាទិត្យ មានកម្រាស់មិនលើសពី២០០គ.ម៉ផុតពីនីវ៉ូសមុទ្រ។ នៅពេលដែលមនុស្សឡើងផុតពីកម្ពស់នេះ គេនឹងឃើញព្រះអាទិត្យជាផ្កាយដុំមូលមួយពណ៌ខៀវ ក្នុងផ្ទៃពណ៌ខ្មៅងងឹតឈឹង លើកលែងតែតំបន់ខ្លះដែលមានកញ្ចុំផ្កាយបញ្ចេញពន្លឺផ្លេកៗ ដោយសារកំហាប់ខ្យល់នៅក្នុងរយៈកម្ពស់នោះលែងមានតុល្យភាព ចុះខ្សោយ ខ្យល់មានការប្រមូលផ្តុំស្តួចស្តើង ស្ទើរតែបាត់បង់ខ្យល់ទាំងស្រុង មានចំហាយទឹកតិចតួច មានលម្អងធុលីច្រើន។ ដូច្នេះ ព្រះអាទិត្យ និងភពផ្កាយផ្សេងទៀតក្លាយទៅជាកន្លែងពណ៌ខៀវកណ្តាលផ្ទៃងងឹត។ ព្រោះពន្លឺរបស់វាគ្មានអ្វីនឹងចាំងក្នុងលំហដ៏ធំទូលាយ។ អល់ឡោះទ្រង់មហាពិសិដ្ឋ បានមានព្រះបន្ទូលប្រាប់ពីវិទ្យាសាស្ត្រពិតនៃចក្រវាលមុននឹងការរកឃើញរបស់មនុស្សតាំងពី១៤០០ឆ្នាំមុន។

## គម្ពីរអាល់គួរអាន និងអាតូម

អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿وَمَا يَعۡزُبُ عَن رَّبِّكَ مِن مِّثۡقَالِ ذَرَّةٖ فِي ٱلۡأَرۡضِ وَلَا فِي ٱلسَّمَآءِ وَلَآ
أَصۡغَرَ مِن ذَٰلِكَ وَلَآ أَكۡبَرَ إِلَّا فِي كِتَٰبٖ مُّبِينٍ ٦١﴾ يونس : ٦١

មានន័យថា៖ «គ្មានអ្វីលាក់បាំងពីការដឹងរបស់ព្រះជាម្ចាស់របស់អ្នកសូម្បីទំហំប៉ុនអាតូមនៅលើ**ផែន**ដី ហើយអ្វីៗនៅលើមេឃមិនអាចលាក់បាំងផងដែរ។ មិនថាតូចជាងនោះ ឬធំជាងនោះ លើកលែងតែមានសរសេរកត់ត្រាទុកក្នុងព្រះលិខិតរួចជាស្រេច» ។

ក្នុងព្រះបន្ទូលខាងលើ អល់ឡោះជាម្ចាស់ទ្រង់បញ្ជាក់ប្រាប់ថាគ្មានអ្វីអវត្តមានពីការដឹងរបស់ទ្រង់នៃសភាវៈសត្វលោកទាំងឡាយទោះបីជាសភាវៈនោះមានទំហំតូចល្អិតយ៉ាងណាក៏ដោយ។ ពីដើមគេជឿថាអាតូមជាធាតុដ៏តូចបំផុត ទាំងទម្ងន់ និងទំហំ តែវិទ្យាសាស្ត្រទំនើបបានរកឃើញថា អាតូមគេអាចបំបែកវាជាធាតុតូចៗបន្តទៀតខណៈ ដែលពួកអ្នកវិទ្យាសាស្ត្របានរកឃើញថា អាតូមខ្លះអាចបំបែកបានដូចជា សារធាតុអុយរ៉ានីញ៉ូមអាចបំបែកដោយស្វ័យប្រវត្តិជាជាលិកាអគ្គិសនីបូកគេហៅថា (អាល់ហ្វា) និងជាលិកាអគ្គិសនីដកគេហៅថា (បេតា) និងកាំរស្មីដែលគេហៅថា (កោម៉ា)។

នៅពេលដែលវិទ្យាសាស្ត្រទំនើបអាចបំផ្លាញអាតូមដោយរោងចក្រឧស្សាហកម្មនៅឆ្នាំ ១៩៣៩ គ.ស អ្នកប្រាជ្ញអាឮម៉ង់ លោក (ហាហាន់) និង (អិស្សត្រាម៉ែន) នៅវិទ្យាស្ថានក្រុងប៉ែកឡាំងបាន**រ**កឃើញវិធីបំបែកអាតូមអុយរ៉ានីញ៉ូមជាពីរចំណែកធំៗ និងជាបំណែកតូចៗ ហើយតាមការវិវឌ្ឍរីកចំរើននៃការវិភាគផ្នែកនេះបានរកឃើញថានៅមានជាតុដែលតូចល្អិតជាងនោះទៅទៀត។

ជាមួយនិងការវិវឌ្ឍន៍រីកចំរើនខាងវិទ្យាសាស្រ្តបានរកឃើញវិទ្យាសាស្រ្តទំនើបៗទាក់ទងនឹងវិស័យផ្សេងៗនៅថ្ងៃអនាគតរហូតដល់ពិភពលោករលាយសាបសូន្យពុំមានទម្ងន់ស្មើនឹងអ្វីសោះបើប្រៀបនឹងពុទ្ធិរបស់អល់ឡោះ និងអានុភាពរបស់ទ្រង់។ ដូចទ្រង់បានមានព្រះបន្ទូលថា៖

﴿ وَيَسْـَٔلُونَكَ عَنِ ٱلرُّوحِۖ قُلِ ٱلرُّوحُ مِنْ أَمْـرِ رَبِّي وَمَآ أُوتِيتُـم مِّنَ ٱلْعِلْمِ إِلَّا قَلِيـلًا ﴿٨٥﴾ ﴾ الإسراء : ٨٥

មានន័យថា៖ «ពួកគេសួរអ្នកអំពីព្រលឹង ចូរប្រាប់ពួកគេចុះថា ព្រលឹងជាកិច្ចការរបស់ព្រះជាម្ចាស់របស់ខ្ញុំ ហើយគេគ្មានផ្តល់ចំណេះដឹងដល់ពួកអ្នក លើកលែងតែបន្តិចបន្តួចប៉ុណ្ណោះ» ។

ពុទ្ធិរបស់អល់ឡោះ និងអានុភាពរបស់ទ្រង់គ្មានទីបញ្ចប់ គ្មានដែនកំណត់ ទ្រង់បានលើកជាឧទាហរណ៍គ្រាន់តែចង់ឱ្យប្រាជ្ញាដ៏ទន់ខ្សោយរបស់យើងអាចរិះគិតពិចារណាយល់ពីអត្ថន័យនៃភាពកម្របស់ចំណេះដឹងមនុស្ស។

## គម្ពីរអាល់គួរអាន និងជាតិកំណើតរបស់មនុស្ស

អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលបញ្ជាក់ពីដំណាក់កាលនៃការវិវឌ្ឍន៍គភ៌របស់មនុស្សថា៖

﴿ وَلَقَدْ خَلَقْنَا ٱلْإِنسَٰنَ مِن سُلَٰلَةٍ مِّن طِينٍ ﴿١٢﴾ ثُمَّ جَعَلْنَٰهُ نُطْفَةً فِى قَرَارٍ مَّكِينٍ ﴿١٣﴾ ثُمَّ خَلَقْنَا ٱلنُّطْفَةَ عَلَقَةً فَخَلَقْنَا ٱلْعَلَقَةَ مُضْغَةً فَخَلَقْنَا ٱلْمُضْغَةَ عِظَٰمًا فَكَسَوْنَا ٱلْعِظَٰمَ لَحْمًا ثُمَّ أَنشَأْنَٰهُ خَلْقًا ءَاخَرَ ۚ فَتَبَارَكَ ٱللَّهُ أَحْسَنُ ٱلْخَٰلِقِينَ ﴿١٤﴾ ﴾ المؤمنون : ١٢-١٤

មានន័យថា៖ «ពិតប្រាកដ យើងបានបង្កើតអាដាំពីដីឥដ្ឋយកមកពីផែនដី។ បន្ទាប់មកយើងបង្កើតជាល្បាយទឹកកាមបិតក្នុងស្បូនដ៏មានសុវត្ថិភាព។ បន្ទាប់មកទៀត យើងបង្កើតល្បាយទឹកកាមនោះជាដុំឈាម ហើយយើងបង្កើតដុំឈាមជាដុំសាច់ បង្កើតដុំសាច់ជាឆ្អឹង ហើយយើងបានបង្កើតសាច់ដុះស្រោបឆ្អឹងនោះ។ បន្ទាប់មកទៀត យើងបង្កើតគេជាសភាវៈផ្សេងទៀតដោយការផ្លុំព្រលឹងចូល អល់ឡោះមហាបវរ ទ្រង់ជាអ្នកបង្កើតដ៏ជាញជ័យ» ។

ដំណាក់កាលវិវឌ្ឍន៍នៃការបង្កើតមនុស្សដូចមានចែងក្នុងគម្ពីរអាល់គួរអានគឺ៖

<u>**ដំណាក់កាលទី១៖**</u> ដំណាក់កាលដីឥដ្ឋ គឺជាដើមកំណើតដែលគេបង្កើតអាដាំបិតារបស់មនុស្សលោក។ ក្នុងព្រះបន្ទូលនេះបដិសេធនឹងទ្រឹស្តីមនុស្សវិវឌ្ឍចេញពីសភាវៈផ្សេង ដោយអល់ឡោះទ្រង់បានបញ្ជាក់ថា មនុស្សជាសភាវៈមួយកើតឡើងដោយឯករាជ្យ ពុំមែនវិវឌ្ឍន៍កើតមកពីសភាវៈដទៃទៀតនោះឡើយ។

<u>**ដំណាក់កាលទី២៖**</u> ល្បាយទឹកកាមជាលទ្ធផលនៃជំនួបរវាងទឹកកាមបុរស(អូវ៉ែ) និងទឹកកាមស្ត្រី (អូវ៉ុល) ហើយច្របល់ចូលគ្នា។ ក្នុងដំណាក់កាលនេះ អល់ឡោះជាម្ចាស់អាចកំណត់ឱ្យអូវ៉ែ និងអូវ៉ុល

រលាយចូលគ្នា ជាដំណើរការនៃការបង្កាត់គ្នារវាងមេជីវិតទាំងពីរ ហើយជួនកាលអាចមិនច្របល់ចូលគ្នា ដោយការកំណត់ពីអល់ឡោះ មិនឱ្យមានដំណើរការបង្កាត់គ្នា ហើយនៅពេលនោះមេជីវិតទាំងពីរត្រូវស្លាប់។ តែបើសិនជា មេជីវិតទាំងពីរបានច្របល់ចូលគ្នា នឹងបង្កើតបានជាល្បាយទឹកកាម ហើយក្លាយជាការចាប់ផ្តើមនៃការបង្កើតមនុស្ស។ អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿إِنَّا خَلَقْنَا ٱلْإِنسَٰنَ مِن نُّطْفَةٍ أَمْشَاجٍ نَّبْتَلِيهِ فَجَعَلْنَٰهُ سَمِيعًۢا بَصِيرًا ٢﴾

الإنسان : ٢

មានន័យថា៖ «ពិតប្រាកដ យើងបានបង្កើតមនុស្សពីល្បាយទឹកកាម យើងសាកល្បងគេដោយដាក់កាតព្វកិច្ចសាសនាចំពោះគេ ហើយយើងបង្កើតឱ្យគេចេះស្តាប់ និងមើលឃើញ» ។

ល្បាយទឹកកាមក្នុងដំណាក់កាលនេះអាចជ្រុះចេញពីស្បូនមកក្រៅ ដោយការកំណត់ពីអល់ឡោះជាម្ចាស់មិនឱ្យនៅជាប់ក្នុងស្បូនតាមរយៈការតោងជាប់នឹងជញ្ជាំងស្បូន។ អល់ឡោះជាម្ចាស់អាចកំណត់ឱ្យល្បាយទឹកកាមនោះតោងជាប់នឹងស្បូន រីវឌ្ឍទៅជាដំណាក់កាលដុំឈាមតោងជាប់នឹងជញ្ជាំងស្បូន ហើយស្រូបយកសារជាតុចិញ្ចឹមចេញពីស្បូននោះ។ អល់ឡោះជាម្ចាស់បានមានព្រះបន្ទូលថា៖

﴿وَنُقِرُّ فِي ٱلْأَرْحَامِ مَا نَشَآءُ إِلَىٰٓ أَجَلٍ مُّسَمًّى ثُمَّ نُخْرِجُكُمْ طِفْلًا﴾

الحج : ٥

មានន័យថា៖ «យើងបានរក្សាទុកអ្វីនៅក្នុងស្បូនតាមតែយើងសព្វព្រះទ័យ ចាប់ដំណើរការកកើតរហូតដល់កើត។ បន្ទាប់មក យើងបង្កើតពួកអ្នកចេញមកក្រៅជាទារក» ។

**ដំណាក់កាលទី៣៖** ដុំឈាម ឬឈ្លើង ព្រោះវាតោងជាប់នឹងជញ្ជាំងស្បូនស្រូបយកសារជាតុចិញ្ចឹមពីឈាមស្រដៀងនឹងសត្វឈ្លើងដែលទាមបឺតជញ្ជក់ឈាមមនុស្ស ឬសត្វដទៃឯទៀតជាចំណី។

**ដំណាក់កាលទី៤៖** ដុំសាច់ ព្រោះវាមានលក្ខណៈដូចជាដុំសាច់មួយម៉ាត់ដែលគេខាំទំពា។

**ដំណាក់កាលទី៥៖** ការបង្កជាឆ្អឹង។

**ដំណាក់កាលទី៦៖** ការដុះសាច់គ្របដណ្តប់ឆ្អឹង។

**ដំណាក់កាលទី៧៖** ជាដំណាក់កាលចុងក្រោយ ជាសភាវៈផ្សេងមួយទៀត គឺកើតជារូងរាងមនុស្សពេញលេញ និងការផ្លុំព្រលឹងចូលក្នុងខ្លួនទារកនោះ។

គភ៌របស់មនុស្សឆ្លងកាត់ដំណាក់កាលជាច្រើនចាប់ផ្តើមពីការបង្កកំណើតក្នុងផ្ទៃងងឹតទាំងបី។ ដូចព្រះជាម្ចាស់ទ្រង់បានបន្ទូលថា៖

﴿يَخْلُقُكُمْ فِي بُطُونِ أُمَّهَاتِكُمْ خَلْقًا مِّن بَعْدِ خَلْقٍ فِي ظُلُمَاتٍ ثَلَاثٍ﴾

الزمر : 6

មានន័យថា៖ «ទ្រង់បង្កើតពួកអ្នកក្នុងផ្ទៃពោះម្តាយរបស់ពួកអ្នកវិវឌ្ឍន៍ពីកំណើតមួយទៅកំណើតមួយក្នុងផ្ទៃងងឹតបី» ។

អច្ឆរិយភាពនៃគម្ពីរអាល់គួរអានក្នុងព្រះបន្ទូលនេះប្រាប់ឱ្យដឹងថាគភ៌គ្របដណ្តប់ដោយស្រោមចំនួនបីដែលគេហៅថាផ្ទៃងងឹត ពីព្រោះជាផ្ទៃដែលជិតឈឹងមិនជ្រាបទឹក មិនចូលខ្យល់ មិនចូលពន្លឺនិងកំដៅ

ស្រោមទាំងនោះមើលមិនឃើញទេ លុះត្រាតែធ្វើការវះកាត់យ៉ាងលម្អិត។ មើលខាងក្រៅហាក់ដូចជាស្រោមតែមួយ លោកសាស្ត្រាចារ្យ មូរីស បូកាយ និយាយថា៖ ផ្ទៃងងឹតទាំងបីគឺជាដែនខណ្ឌចែករវាងគភ៌និងពិភពខាងក្រៅ គភ៌រស់នៅក្នុងស្រោម (សុក) ដែលនៅក្នុងស្បូនក្នុងផ្ទៃពោះរបស់ស្ត្រី... អាស្រ័យហេតុនេះ ផ្ទៃងងឹតទាំងបីគឺអាចបកស្រាយបានថា ជាភាពងងឹតក្នុងស្រោមសុក ភាពងងឹតក្នុងស្បូន និងភាពងងឹតក្នុងផ្ទៃពោះ។ ក៏ដូចជាកន្លែងដ៏មានសុវត្ថិភាពដាច់ដោយឡែកពីគេ នៅឆ្ងាយពីការប៉ះទង្គិចពីខាងក្រៅ អល់ឡោះជាម្ចាស់បានមានព្រះបន្ទូលថា៖

﴿أَلَمْ نَخْلُقكُّم مِّن مَّآءٍ مَّهِينٍ ۝٢٠ فَجَعَلْنَٰهُ فِى قَرَارٍ مَّكِينٍ ۝٢١ إِلَىٰ قَدَرٍ مَّعْلُومٍ ۝٢٢ فَقَدَرْنَا فَنِعْمَ ٱلْقَٰدِرُونَ ۝٢٣﴾ المرسلات : ٢٠-٢٣

មានន័យថា៖ «តើមិនមែនទេឬយើងបង្កើតពួកអ្នកពីសារធាតុទឹកដ៏ក្បត់ខ្សោយ។ យើងបង្កើតទឹកនោះឱ្យនៅក្នុងស្បូនស្ត្រីដ៏មានសុវត្ថិភាពដល់ដំណាល់កំណត់មួយ។ យើងបានកំណត់ការបង្កើត ការសូនរូប និងការបង្កើតចេញមកក្រៅ ទ្រង់គឺជាអ្នកកំណត់ដ៏សុក្រឹតឥតខ្ចោះ» ។

លោកសាស្ត្រាចារ្យ កេត មួរ ជាអ្នកប្រាជ្ញខាងក្រូណាសាស្ត្រ ប្រធានផ្នែកវះកាត់ និងគភ៌នៃសាកលវិទ្យាល័យ តូរិនតូ ប្រទេសកាណាដាក្នុងសៀវភៅការវិវឌ្ឍន៍បានសរសេរថា «នៅពេលដែលខ្ញុំធ្វើការសិក្សាស្រាវជ្រាវដំណាក់កាលផ្សេងៗរបស់គភ៌ក្នុងផ្ទៃរបស់ម្ដាយ ដែលប្រើឧបករណ៍ថតឆ្លុះបែបវិទ្យាសាស្ត្រទំនើបបំផុត គឺរកឃើញថា

វាត្រូវមួយរយភាគរយទៅនឹងអ្វីដែលគម្ពីរអាល់គួរអានបានចែងពីដំណាក់កាលបង្កផ្ទឹង សាច់។ល។ នៅពេលដែលគេសួរលោកថា តើអាចទេដែលអ្នកនាំសាររបស់ឥស្លាមអាចដឹងពីបំណកស្រាយពិស្តារអំពីគភ៌នេះ? លោកតបវិញថា មិនអាចជាដាច់ខាត... ពិភពលោកនៅសម័យនោះពុំទាន់ដឹងថាភគ៌បង្កឡើងជាដំណាក់កាល មិនតែប៉ុណ្ណោះ ហេូតដល់បច្ចុប្បន្នវិទ្យាសាស្ត្រ ពុំទាន់អាចឱ្យឈ្មោះដំណាកកាលរបស់គភ៌ គ្រាន់តែផ្តល់ជាតួលេខស្មុគស្មាញ ខណៈដែលគម្ពីរអាល់គួរអានបានចែងពីឈ្មោះដំណាក់កាលទាំងនោះដោយកំណត់យ៉ាងច្បាស់លាស់ងាយស្រួល និងពិស្តារបំផុត។ ទាំងនេះ បញ្ជាក់ប្រាប់ខ្ញុំយ៉ាងច្បាស់ និងដាច់ខាតថា ភស្តុតាងទាំងនេះមកដល់មូហាំម៉ាត់ពីអល់ឡោះជាម្ចាស់។

លោកបណ្ឌិត ដេរ៉ាលេត ដូរេនចឺ ជាសាស្ត្រាចារ្យក្រូណាសាស្ត្រនៃសាកលវិទ្យាល័យអាមេរិកនិយាយថា៖ វិទ្យាសាស្ត្រពិតជាច្រើនដែលលើកឡើង ដោយពួកអ្នកជំនាញខាងមូហាំម៉ាត់វចនៈឯកភាពជាមួយនឹងវិទ្យាសាស្ត្រពិតដែលស្រាវជ្រាវរកឃើញដោយវិទ្យាស្ត្រទំនើប។

## គម្ពីរអាល់គួរអាន និងដែនខណ្ឌចែករវាងសមុទ្រ

អល់ឡោះជាម្ចាស់បានមានព្រះបន្ទូលថា៖

﴿وَهُوَ ٱلَّذِى مَرَجَ ٱلْبَحْرَيْنِ هَٰذَا عَذْبٌ فُرَاتٌ وَهَٰذَا مِلْحٌ أُجَاجٌ وَجَعَلَ بَيْنَهُمَا بَرْزَخًا وَحِجْرًا مَّحْجُورًا ۝٥٣﴾ الفرقان : 53

មានន័យថា៖ «ទ្រង់ដែលបានធ្វើឱ្យសមុទ្រពីរប្រសព្វគ្នា មួយជាទឹកសាបមានឱជារស ហើយមួយទៀតជាទឹកប្រៃល្វីង ហើយទ្រង់បានបង្កើតរវាងសមុទ្រទាំងពីរនូវដែនខណ្ឌចែកបិទជិត» ។

ពិតប្រាកដ ភាពមិនច្របល់ចូលគ្នានៃទឹកសមុទ្រជាវិទ្យាសាស្ត្រពិតដែលពួកអ្នកប្រាជ្ញខាងភូគព្ភសាស្ត្រ ទើបតែស្រាវជ្រាវរកឃើញនារយៈពេលចុងក្រោយនេះប៉ុណ្ណោះ។ រកឃើញដោយសារថាមពលភូគព្ភរូបវន្តដែលគេឱ្យឈ្មោះថា (ដំណើរបិទជិតនៃផ្ទៃលើ) នៅទីនោះកំហាប់ទឹករារាំងមិនឱ្យច្របល់ចូលគ្នាហាក់បីដូចជាមានជញ្ជាំងខណ្ឌចែក។ ទឹកទន្លេដែលហូរចាក់ចូលទៅក្នុងសមុទ្រពុំជះឥទ្ធិលដល់ទឹកសមុទ្រធ្វើឱ្យប្រែប្រួលជាតិប្រៃនោះឡើយ។ ក៏ដូចគ្នាដែរ ទឹកសមុទ្រដែលមានបរិមាណច្រើនជាងមិនជះឥទ្ធិពលដល់ទឹកទន្លេ ដែលហូរចាក់ចូលទៅក្នុងសមុទ្រធ្វើឱ្យប្រែប្រួលជាតិសាបរបស់វាដែរ។ ឧទាហរណ៍ ទឹកទន្លេអាម៉ាហ្សូនដែលចាក់ចូលទៅក្នុងមហាសមុទ្រអាត្លង់ទិក ទឹកហូរចូលក្នុងជម្រៅ២០០ម៉ែល៍ទៅដល់ពាក់កណ្តាលមហាសមុទ្រ តែទឹកនេះនៅរក្សាជាតិសាបរបស់វាដដែល។

**គម្ពីរអាល់គួរអាន និងជម្រៅសមុទ្រ**

អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿أَوۡ كَظُلُمَٰتٖ فِي بَحۡرٖ لُّجِّيّٖ يَغۡشَىٰهُ مَوۡجٞ مِّن فَوۡقِهِۦ مَوۡجٞ مِّن فَوۡقِهِۦ سَحَابٞۚ ظُلُمَٰتُۢ بَعۡضُهَا فَوۡقَ بَعۡضٍ إِذَآ أَخۡرَجَ يَدَهُۥ لَمۡ يَكَدۡ يَرَىٰهَاۗ وَمَن لَّمۡ يَجۡعَلِ ٱللَّهُ لَهُۥ نُورٗا فَمَا لَهُۥ مِن نُّورٍ ٤٠﴾ النور : ٤٠

មានន័យថា៖ «ឬក៏ដូចជាភាពងងឹងទាំងឡាយនៅក្នុងសមុទ្រជ្រៅគ្របដណ្តប់ដោយរលកត្រួតពីលើរលក នៅពីលើរលកមានពពក ភាពងងឹតត្រួតលើគ្នា នៅពេលដែលគេលើកដៃចេញក្រៅ គេស្ទើរតែមើលមិនឃើញ ហើយចំពោះអ្នកដែលអល់ឡោះជាម្ចាស់មិនធ្វើឱ្យគេមានពន្លឺដូច្នេះគេនឹងគ្មានពន្លឺសម្រាប់បំភ្លឺផ្លូវជាដាច់ខាត» ។

តាមវិទ្យាសាស្ត្រពិតបានឱ្យដឹងថា បាតមហាសមុទ្រ និងសមុទ្រជ្រៅងងឹតគ្មានពន្លឺ ដោយសារគ្មានរស្មីព្រះអាទិត្យចូលទៅដល់។ ជម្រៅបាតសមុទ្រប្រហែលចាប់ពីរាប់រយម៉ែតទៅដល់១១០៣៤ម៉ែត្រ ភាពងងឹតចាប់ផ្តើមពីជម្រៅ២០០ម៉ែត្រចុះក្រោម នៅក្នុងជម្រៅនេះស្ទើរតែគ្មានពន្លឺតែម្តង។ លុះដល់ជម្រៅ១០០០ម៉ែត្រទទេគ្មានពន្លឺតែម្តង។ ដែនអូហ្សូនក្នុងស្រទាប់បរិយាកាសរបស់ផែនដីបានរុញច្រានរលកស្វ័យអុលត្រាវ៉ៃអូលៃតភាគច្រើនទៅកាន់លំហរបិតនៅក្រៅភពផែនដី។ រីឯពពកវិញចាំងផ្លាតរស្មីព្រះអាទិត្យប្រហែលជា៣០% និងស្រូបយកប្រហែលជា១៩%។ ដូច្នេះ ពន្លឺព្រះអាទិត្យដែលបញ្ជូនទៅដល់ផ្ទៃសមុទ្រ និងមហាសមុទ្រមានតែ៥១%ប៉ុណ្ណោះ។ បន្ទាប់មករលកផ្ទៃខាងលើបានចាំងផ្លាតទៅវិញ៥% និងស្រូបយក៣៥%នៃពន្លឺ

ពណ៌ក្រហមដើម្បីកម្ដៅទឹក ហើយក្នុងដំណើរនៃការវិភាគពន្លឺ ចំពោះរុក្ខជាតិសមុទ្រខ្លះ នៅពេលពន្លឺព្រះអាទិត្យដែលនៅសល់បានជ្រៀតចូលទៅក្នុងម៉ាស់ទឹក ពន្លឺត្រូវប្រឈមនឹងដំណើរការនៃការបាត់បង់ទៅម្ដងបន្តិចៗតាមវិសាលគមខុសៗគ្នា ត្រូវស្រូបយកតាមលំដាប់អាស្រ័យលើរយៈចម្ងាយនៃរលកពន្លឺចាប់ផ្ដើមដោយពន្លឺពណ៌ក្រហម និងបញ្ចប់ដោយពន្លឺពណ៌ស្វាយ។ នេះដោសារមូលហេតុរលកពន្លឺមើលឃើញភាគច្រើននៃរស្មីព្រះអាទិត្យជ្រៀតចូលទៅក្នុងជម្រៅប្រហែល ១០០ ម៉ែត្រ ពីនីវ៉ូទឹកសមុទ្រ និងមហាសមុទ្រ។ គេហៅតំបន់នោះថាជាតំបន់មានពន្លឺ ហើយរស្មីព្រះអាទិត្យបន្តពីជម្រៅនេះទៅដល់ជម្រៅ ១៥០ ម៉ែត្រ មានពន្លឺតែ ១% ប៉ុណ្ណោះ។ លុះដល់ជម្រៅ ២០០ម៉ែត្រ មានពន្លឺតែ 0.0១% ប៉ុណ្ណោះក្នុងផ្ទៃទឹកដ៏ថ្លាគ្មានប្លង់តង់ ក្នុងជម្រៅនេះពន្លឺក្សត់ខ្សោយខ្លាំងមែនទែន។ ពន្លឺមិនអាចជ្រៀតចូលទៅដល់ជម្រៅ ១០០ម៉ែត្រ ក្រោមនីវ៉ូសមុទ្រក្នុងករណីដែលគ្មានឧបសគ្គរលកក្នុងសមុទ្រ។ តែបើសិនជាមានរលកក្នុងសមុទ្រវិញពន្លឺមិនអាចទៅដល់ក្នុងជម្រៅនេះឡើយ។ រលកក្នុងសមុទ្រចាប់ផ្ដើមកើតមានក្នុងជម្រៅ ៤០ ម៉ែត្រពីនីវ៉ូទឹកសមុទ្រ ហើយកើតមានរលកក្រោមសមុទ្រផ្សេងទៀតក្នុងជម្រៅទាបជាងនោះ (វិទ្យាសាស្ត្រពិតនៃផ្ទៃមេឃក្នុងគម្ពីរអាល់គួរអាន លោកបណ្ឌិត សាហ្គលូល អាន់ណ៉ាចចារ)។

នៅរយៈពេលចុងក្រោយនេះ ពួកអ្នកប្រាជ្ញបានរកឃើញមានរលកក្រោមសមុទ្រកើតឡើងនៅត្រង់ដែនផ្ទៃទឹកដែលមានកំហាប់ខុសគ្នា។ រលកក្នុងសមុទ្រទាំងនេះគ្របដណ្ដប់លើជម្រៅទឹកសមុទ្រ និងមហាសមុទ្រ។ ពីព្រោះទឹកជ្រៅមានកំហាប់ច្រើនជាងផ្ទៃទឹកខាងលើ

ហើយរលកក្នុងសមុទ្រមានចលនាដូចរលកផ្ទៃទឹកខាងលើដែរ។ ទឹករលកបក់បោកគ្រាំៗដូចគ្នា តែមិនអាចមើលនឹងភ្នែកទទេឃើញឡើយ។ តែអាចរកឃើញដោយការទាញយកភស្តុតាងពីកាសិក្សាស្រាវជ្រាវលើបំរែបំរួលនៃដង់ស៊ីតេទឹក ឬបរិមាណជាតិអំបិលក្នុងតំបន់ណាមួយនៃសមុទ្រ និងមហាសមុទ្រ (ហារូន យ៉ះយ៉ា)។

ចរន្តទឹកសមុទ្របែបនេះ គឺនៅកន្លែងតែមួយមានរលកលើផ្ទៃសមុទ្រ និងរលកក្រោមសមុទ្រ មាននៅក្បែរតំបន់ភ្នំតោរិក។ នៅទីនោះ ទឹកសមុទ្រមេឌីទែរណេប្រសព្វជាមួយមហាសមុទ្រអាត្លង់ទិកមធ្យមភាគលំហូតទឹកសមុទ្រមេឌីទែរណេកើនឡើងខ្លាំងជាង បើប្រៀបទៅនឹងលំហូតមហាសមុទ្រអាត្លង់ទិក។ ពិតប្រាកដ ទឹកសមុទ្រមេឌីទែរណេមានកម្រិតជាតិប្រៃខ្ពស់បំផុត ចូលជ្រៅក្នុងបាតមហាសមុទ្រ បង្កើតបានជាចរន្តមួយមានលំហូរឆ្ពោះទៅកាន់មហាសមុទ្រ។ រីឯផ្ទៃទឹកខាងលើវិញមានកម្រិតជាតិប្រៃតិចជាង និងមានដង់ស៊ីតេខ្ពស់ជាងមហាសមុទ្របង្កើតបានជាចរន្តទឹកផ្ទៃខាងលើមួយបិតនៅលើចរន្តទឹកខាងក្រោម ហើយមានលំហូរផ្ទុយពីចរន្តទឹកខាងក្រោម គឺឆ្ពោះមកកាន់សមុទ្រមេឌីទែរណេវិញ។

ពត៌មានទាំងនេះគេទើបតែស្រាវជ្រាវរកឃើញនាពេលថ្មីៗនេះដោយសារការអភិវឌ្ឍន៍ផ្នែកឧបករណ៍ និងសម្ភារៈដែលអាចជ្រមុជទៅដល់បាតសមុទ្រជ្រៅបំផុត។ អ្នកនាំសារឥស្លាមរស់នៅក្នុងសង្គមវាលខ្សាច់សាហារ៉ានៅឆ្ងាយពីសមុទ្រ។ លោកមិនដែលធ្វើដំណើរឆ្លងកាត់មហាសមុទ្រ និងសមុទ្រ តែគម្ពីរអាល់គួរអានបានផ្តល់ពត៌មានយ៉ាង

លម្អិតពីវិទ្យាសាស្ត្រពិតជាភស្តុតាងបញ្ជាក់ថាទាំងនេះពិតជាពាក្យបន្ទូលរបស់អល់ឡោះជាម្ចាស់។

**គម្ពីរអាល់គួរអាន និងតួនាទីខ្យល់ក្នុងការបង្កើតពពក និងភ្លៀងធំ**

អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿وَهُوَ ٱلَّذِى يُرۡسِلُ ٱلرِّيَٰحَ بُشۡرَۢا بَيۡنَ يَدَىۡ رَحۡمَتِهِۦۖ حَتَّىٰٓ إِذَآ أَقَلَّتۡ سَحَابٗا ثِقَالٗا سُقۡنَٰهُ لِبَلَدٖ مَّيِّتٖ فَأَنزَلۡنَا بِهِ ٱلۡمَآءَ فَأَخۡرَجۡنَا بِهِۦ مِن كُلِّ ٱلثَّمَرَٰتِۚ كَذَٰلِكَ نُخۡرِجُ ٱلۡمَوۡتَىٰ لَعَلَّكُمۡ تَذَكَّرُونَ ٥٧﴾ الأعراف: ٥٧

មានន័យថា៖ «អល់ឡោះជាម្ចាស់ទ្រង់បញ្ជូនខ្យល់ជាដំណឹងល្អបក់នាំទឹកភ្លៀងមកដោយការអនុញ្ញាតពីទ្រង់។ សត្វលោករីករាយនិងក្ដីមេត្តារបស់អល់ឡោះ។ លុះខ្យល់នោះបក់នាំពពកទឹកភ្លៀងមក យើងបានបញ្ជូនពពកនោះទៅកាន់តំបន់ដីដែលហួតហែងគ្មានរុក្ខជាតិ យើងបានបញ្ចុះទឹកភ្លៀង យើងបានធ្វើឱ្យដុះចេញមកតាមរយៈទឹកភ្លៀងនោះនូវដំណាំរុក្ខជាតិផ្សេង ហើយមានផលានុផលគ្រប់ប្រភេទ ហើយយើងបង្កើតសាកសពឱ្យរស់ឡើងវិញចេញពីផ្នូរក៏ដូច្នោះដែរ សង្ឃឹមថាពួកអ្នកភ្ញាក់រឭក» ។

អល់ឡោះជាម្ចាស់បានមានព្រះបន្ទូលទៀតថា៖

﴿وَأَرۡسَلۡنَا ٱلرِّيَٰحَ لَوَٰقِحَ فَأَنزَلۡنَا مِنَ ٱلسَّمَآءِ مَآءٗ فَأَسۡقَيۡنَٰكُمُوهُ وَمَآ أَنتُمۡ لَهُۥ بِخَٰزِنِينَ ٢٢﴾ الحجر: ٢٢

មានន័យថា៖ «យើងបានបញ្ជូនខ្យល់ដើម្បីបង្កពពកទឹកភ្លៀង ហើយយើងបានបញ្ចុះពីពពកនោះនូវទឹកភ្លៀង សម្រាប់ឱ្យពួកអ្នកទទួលទាន ស្រោចស្រពដំណាំ និងទុកឱ្យសត្វពាហនៈផឹក ហើយពួកអ្នកគ្មានលទ្ធភាពនឹងស្តុកទឹកទាំងនោះឡើយ» ។

តាមការឱ្យដឹងរបស់វិទ្យាសាស្ត្រទំនើប ខ្យល់មានតួនាទីបង្កាត់ដំណាំរុក្ខជាតិជាច្រើន តាមរយៈការបក់លំអងផ្កាបង្កាត់គ្នាទៅវិញទៅមក និងបង្កពពកទឹកភ្លៀង។ វិទ្យាសាស្ត្រទំនើបបានកំណត់ថា ពពកទឹកភ្លៀង និងខ្យល់មានការពាក់ពាន់គ្នាជាប្រព័ន្ធ។ តាំងពីដើមរៀងមកមនុស្សគិតថា ទឹកភ្លៀងធ្លាក់ពីលើមេឃមកតែម្តង។ ក៏ប៉ុន្តែវិទ្យាសាស្ត្រពិតបានរកឃើញថា ខ្យល់មានតួនាទីធ្វើឱ្យពពកមានចលនា បក់នាំយកលំហួតចេញពីសមុទ្រ មហាសមុទ្រ និងប្រមូលផ្តុំផ្ទាំងពពកទាំងឡាយ ហើយបក់នាំយកលំហួតសមុទ្រទៅបំប៉នពពក។ ម្យ៉ាងវិញទៀត ខ្យល់មិនគ្រាន់តែនាំលំហួតសមុទ្រមកបំប៉នពពកប៉ុណ្ណោះទេ តែថែមទាំងបានស្រូបទាញយកពពកមកផ្តុំគ្នា ហើយបង្កាត់ពពកទាំងនោះ នឹងគ្រាប់តូចៗដែលមានផ្ទុកជាតិអំបិលសំបូរបែបដែលគេហៅថា (កំណកនុយក្លេអ៊ិក) ដែលរសាត់តាមចរន្តខ្យល់ពីសមុទ្រនិងមហាសមុទ្រ។

អល់ឡោះជាម្ចាស់បានមានព្រះបន្ទូលទៀតថា៖

﴿ٱللَّهُ ٱلَّذِى يُرْسِلُ ٱلرِّيَـٰحَ فَتُثِيرُ سَحَابًا فَيَبْسُطُهُۥ فِى ٱلسَّمَآءِ كَيْفَ يَشَآءُ وَيَجْعَلُهُۥ كِسَفًا فَتَرَى ٱلْوَدْقَ يَخْرُجُ مِنْ خِلَـٰلِهِۦ ۖ فَإِذَآ أَصَابَ بِهِۦ مَن يَشَآءُ مِنْ عِبَادِهِۦٓ إِذَا هُمْ يَسْتَبْشِرُونَ ﴿٤٨﴾﴾ الروم: ٤٨

មានន័យថាៈ «អល់ឡោះជាម្ចាស់ទ្រង់បញ្ជូនខ្យល់បក់ធ្វើឱ្យពពកមានចលនា ទ្រង់ពង្រាយពពកទាំងនោះតាមតែទ្រង់សព្វព្រះទ័យ ទ្រង់ធ្វើឱ្យវាក្លាយ**ជា**ផ្ទាំងជាច្រើនខុសៗគ្នា។ អ្នកនឹងឃើញទឹកភ្លៀងចេញពីចន្លោះពពកទាំងនោះ។ នៅពេលដែលអល់ឡោះជាម្ចាស់បញ្ជូនពពកនោះទៅកាន់ក្រុមខ្ញុំបម្រើណាដែលទ្រង់សព្វព្រះទ័យនោះ ពួកគេនាំគ្នាសប្បាយរីករាយ» ។

តាមវិទ្យាសាស្ត្របានទទួលស្គាល់ថា ជាការពិតណាស់ដំណាក់កាលនៃការបង្កពពកដែលចែងដោយគម្ពីរអាល់គួរអាន ខ្យល់ជាអ្នកនាំយកលំហួតទឹកដែលសំបូរទៅដោយសារធាតុផ្សំរបស់អំបិលពីសមុទ្រ និងមហាសមុទ្រទៅកាន់ស្រទាប់ផ្សេងៗនៃបរិយាកាស។ សារធាតុផ្សំដែលបកនាំយកទៅនោះគេហៅថា (កំណកនុយក្លេអ៊ុក) ជាគ្រាប់តូចល្អិតដែលប្រមូលផ្តុំជុំវិញវាដោយលំហួតទឹកឡើងលើក្នុងរូបភាពជាតំណក់ទឹករាយប៉ាយពាសពេញមេឃ បង្កើតបានជាពពក។ បន្ទាប់មក ដោយសារតំណក់ទឹកភ្លៀងធ្ងន់ជាងខ្យល់ ក៏បង្កើតបានផ្ទាំងពពកទឹកភ្លៀង ហើយនោះគេហៅថាភ្លៀងធំធ្លាក់មកលើផែនដី។

អល់ឡោះជាម្ចាស់បានមានព្រះបន្ទូលថាៈ

﴿ أَلَمْ تَرَ أَنَّ ٱللَّهَ يُزْجِى سَحَابًا ثُمَّ يُؤَلِّفُ بَيْنَهُۥ ثُمَّ يَجْعَلُهُۥ رُكَامًا فَتَرَى ٱلْوَدْقَ يَخْرُجُ مِنْ خِلَٰلِهِۦ وَيُنَزِّلُ مِنَ ٱلسَّمَآءِ مِن جِبَالٍ فِيهَا مِنۢ بَرَدٍ فَيُصِيبُ بِهِۦ مَن يَشَآءُ وَيَصْرِفُهُۥ عَن مَّن يَشَآءُ ۖ يَكَادُ سَنَا بَرْقِهِۦ يَذْهَبُ بِٱلْأَبْصَٰرِ ﴿٤٣﴾ ﴾ النور: ٤٣

មានន័យថាៈ «តើអ្នកមិនឃើញទេឬអល់ឡោះធ្វើឱ្យពពករសាត់តាមតែទ្រង់សព្វព្រះទ័យ ទ្រង់ប្រមូលផ្តុំបន្ទាប់ពីវានៅរាយប៉ាយ?

បន្ទាប់មក ទ្រង់បង្កើតវាជាពំនូកមួយ ហើយអ្នកឃើញទឹកភ្លៀងធ្លាក់ចេញពីចន្លោះពំនូកពពកនោះ។ ទ្រង់បញ្ចុះពីពពកនោះនូវសំណុំព្រិលដែលមានទំហំធំដូចភ្នំ។ ទ្រង់ធ្វើឱ្យសំណុំព្រិលនោះមកត្រូវប៉ះនរណាដែលទ្រង់សព្វព្រះទ័យ ហើយទ្រង់បញ្ចៀសវាពីនរណាដែលទ្រង់សព្វព្រះទ័យ។ ពន្លឺផ្លេកបន្ទោរចេញពីសំណុំព្រិលនោះស្ទើរតែឆក់យកខ្សែភ្នែកទាំងស្រុង» ។

នេះគឺជាដំណាក់កាលផ្សេងទៀត នៃដំណាក់កាលបង្កពពកទឹកភ្លៀងគឺជាពំនូកពពក។ នៅពេលដែលដុំពពកតូចៗប្រមូលផ្តុំគ្នាជាពំនូកគរឡើងលើ គឺកើតចេញពីចរន្តខ្យល់បក់ឡើងលើមានកម្លាំងខ្លាំងត្រង់ចំណុចកណ្តាលពពកជាងនៅសងខាង។ ពំនូកពពកខ្ពរឡើងលើរហូតដល់តំបន់សម្ពាធខ្យល់ត្រជាក់ខ្លាំងក៏បង្កើតជាដំណក់ទឹកភ្លៀងនិងព្រិល។ បន្ទាប់មកសំណុំដំណក់ភ្លៀងនោះកាន់តែធ្ងន់ឡើងៗធ្វើឱ្យចរន្តខ្យល់មិនអាចទ្រទ្រង់បានក៏ធ្លាក់ជាទឹកភ្លៀង។ ដូចដែលព្រះបន្ទូលខាងលើបានបញ្ជាក់ថា ព្រិលជាអ្នកទទួលខុសត្រូវចំពោះបន្ទុកអគ្គិសនីដែលជាមូលហេតុបង្កឱ្យមានរន្ទះ និងផ្លេកបន្ទោរ។ វិទ្យាសាស្ត្រពិតទាំងនេះ ពួកអ្នកប្រាជ្ញបានទទួលស្គាល់បន្ទាប់ពីធ្វើការស្រាវជ្រាវអស់រយៈកាល១០ឆ្នាំ។ នៅពេលដែលខ្យល់អាចផ្តាច់បន្ទុកដកខាងលើចេញពីបន្ទុកបូកខាងក្រោមធ្វើឱ្យកើតការបញ្ចេញអគ្គិសនីក្នុងរូបភាពជាផ្លេកបន្ទោរ ហើយផ្លេកបន្ទោរនោះបណ្តាលឱ្យមានកំដៅយ៉ាងខ្លាំងកើតឡើងភ្លាមៗក្នុងតំបន់នោះទាំងមូល ហើយចរន្តខ្យល់ត្រូវបែកខ្ចាត់ខ្ចាយបណ្តាលឱ្យកើតជាផ្គរលាន់។ រីឯការបញ្ចេញបន្ទុកអគ្គិ

សនីក្នុងរូបភាពណាមួយលើផ្ទៃផែនដី ក្នុងសភាពដូចនេះគេហៅថា រន្ទះបាញ់។ អល់ឡោះបានមានព្រះបន្ទូលថា៖

﴿وَيُرۡسِلُ ٱلصَّوَٰعِقَ فَيُصِيبُ بِهَا مَن يَشَآءُ﴾ الرعد: ١٣

មានន័យថា៖ «ទ្រង់បញ្ជូនរន្ទះមក ហើយទ្រង់ធ្វើឱ្យរន្ទះនោះបាញ់ត្រូវនរណាដែលទ្រង់មានចេតនា» ។

**គម្ពីរអាល់គួរអាន និងសត្វពាហនៈ**

អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿وَإِنَّ لَكُمۡ فِي ٱلۡأَنۡعَٰمِ لَعِبۡرَةٗۖ نُّسۡقِيكُم مِّمَّا فِي بُطُونِهِۦ مِنۢ بَيۡنِ فَرۡثٖ وَدَمٖ لَّبَنًا خَالِصٗا سَآئِغٗا لِّلشَّٰرِبِينَ ٦٦﴾ النحل: ٦٦

មានន័យថា៖ «ពិតប្រាកដ សម្រាប់ពួកអ្នក សត្វពាហនៈជាតួយ៉ាងគួរឱ្យត្រិះរិះពិចារណា ពួកអ្នកឃើញផ្ទាល់នឹងភ្នែកថា យើងបានផ្ដល់ទឹកដោះដ៏បរិសុទ្ធដល់ពួកអ្នក ដែលកើតចេញពីលាមកនិងឈាមរបស់វា មានឱជារសឆ្ងាញ់ពិសាសម្រាប់ពួកអ្នកទទួលទាន»។

អ្នកសិក្សាស្រាវជ្រាវវប្បធម៌បូព៌ា លោក ម៉ូរីស ពូកាយ បាននិយាយអំពីព្រះបន្ទូលនេះថា៖ ដើម្បីស្វែងយល់អត្ថន័យនៃព្រះបន្ទូលក្នុងទស្សនៈជាលក្ខណៈវិទ្យាសាស្ត្រ ចាំបាច់ត្រូវពឹងលើចំណេះវិជ្ជាទាក់ទងនឹងមុខងារអវយវៈដែលផលិតអាហារសំខាន់ដើម្បីផ្គត់ផ្គត់ដល់សរីរាង្គកាយទូទៅ។ អាហារនេះកើតចេញពីប្រតិកម្មគីមីដែលកើតឡើងក្នុងបំពង់រំលាយអាហារ... សារធាតុទាំងនេះកើតចេញពីអង្គធាតុ

ដែលមាននៅក្នុងពោះវៀន។ នៅពេលដែលសារជាតុនេះចូលដល់ពោះវៀនក្នុងដំណាក់កាលប្រតិកម្មគីមីចាំបាច់មួយ ឆ្លងកាត់តាមរយៈបំពង់ពោះវៀនជាចលនាជម្នាមួយ...ការធ្វើចលនាបំលាស់ទីនេះមានពីរផ្លូវគឺ ទី១ តាមរយៈបំពង់ជលិកា ទី២ ផ្លាស់ទីដោយមិនផ្ទាល់តាមរយៈចលនាសរសៃឈាមធំដែលនាំយកសារជាតុទាំងនេះទៅកាន់ថ្លើម ហើយនៅទីនេះកើតមានការប្រែប្រួល។ នៅទីបំផុតសារជាតុនេះចេញពីថ្លើមទៅកាន់ចរន្តឈាម។ នៅពេលសារជាតុគ្រប់យ៉ាងឆ្លងកាត់តាមចរន្តឈាមគឺមានទម្រង់បែបនេះ។

ក្រពេញដោះដែលបញ្ចេញសារជាតុបង្កើតទឹកដោះ ហើយក្រពេញទាំងនេះត្រូវផ្គត់ផ្គង់ដោយសារជាតុចិញ្ចឹមដែលកើតចេញពីការរំលាយអាហារដែលត្រូវបញ្ជូនមកតាមរយៈចរន្តឈាម។ ឈាមមានតួនាទីនាំយកសារជាតុចិញ្ចឹមដែលកើតចេញពីអាហារក្នុងពោះវៀនបញ្ជូនទៅចិញ្ចឹមក្រពេញដោះ ហើយបង្កើតបានជាទឹកដោះ ហើយសារជាតុចិញ្ចឹមទាំងនេះក៏ត្រូវផ្គត់ផ្គង់ដល់សរីរាង្គផ្សេងៗទៀតផងដែរ។

ទិន្នន័យទាំងនេះនៅមានកម្រិតនៅឡើយ សព្វថ្ងៃគេចាត់ទុកថាជាលទ្ធផលនៃការប្រតិកម្មគីមី និងជាសរីរសាស្ត្រនៃការរំលាយអាហារ។ ខ្ញុំគិតថាការមានព្រះបន្ទូលក្នុងគម្ពីរអាល់គួរអានបញ្ជាក់ពីទិន្នន័យនេះ មិនអាចបកស្រាយសមហេតុផលជាដាច់ខាតរហូតដល់សម័យក្រោយបន្ទាប់ពីគេសរសេរទិន្នន័យនេះឡើង។ ពិតប្រាកដណាស់ វិទ្យាសាស្ត្រពិត និងទិន្នន័យផ្សេងៗទៀតដែលមានចែងគឺជាការត្រាស់បន្ទូលមកពីអល់ឡោះជាម្ចាស់។ មនុស្សជាតិនាសម័យនោះមិនដឹងពីទិន្នន័យទាំងនេះជាវិទ្យាសាស្ត្រពិតនៅឡើយ។

អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿أَلَمۡ نَجۡعَلِ ٱلۡأَرۡضَ مِهَٰدٗا ٦ وَٱلۡجِبَالَ أَوۡتَادٗا ٧﴾ النبأ: ٦-٧

មានន័យថា៖ «តើមិនមែនទេឬយើងបង្កើតដីជាផ្ទៃរាបស្មើ ហើយភ្នំទាំងឡាយជាស្នឹង» ។

ពួកអ្នកប្រាជ្ញបកស្រាយពីតួនាទីភ្នំក្នុងការរក្សាតុល្យភាពថា៖ ពិតប្រាកដ ភ្នំមានការលាតសន្ធឹងយ៉ាងធំជេងក្រោមស្រទាប់ផែនដី។ គេរកឃើញថា សំបកផែនដីមានកំរាស់ប្រហែលចន្លោះពី ៣០ ទៅ ៦០គ.ម។ ពួកគេដឹងតាមរយៈឧបករណ៍ (សាក់មូក្រ័ហ្វ) ដែលបញ្ជាក់ឱ្យដឹងថា គ្រប់ភ្នំទាំងអស់មានឫសចាក់ជ្រៅក្នុងដីស្រទាប់ក្រោមដែលទន់ ដើម្បីទប់លំនឹងសំបកផែនដីស្រទាប់លើដែលរឹង។ ដូច្នេះមានឫសចុះទៅក្រោម និងលើស្រទាប់ផ្សេងៗនៃផ្ទៃផែនដី។ ភ្នំជួយរក្សាលំនឹងសំបកផែនី ទប់មិនឱ្យរសាត់អណ្តែតរវាងស្រទាប់នីមួយៗដូចជាស្នឹង។ ដូចដែលព្រះបន្ទូលបានពិពណ៌នាថាវាហាក់បីដូចជាដែកគោលដែលដំជាប់នឹងសាច់ឈើយ៉ាងមាំ។

អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលទៀតថា៖

﴿وَأَلۡقَىٰ فِي ٱلۡأَرۡضِ رَوَٰسِيَ أَن تَمِيدَ بِكُمۡ وَأَنۡهَٰرٗا وَسُبُلٗا لَّعَلَّكُمۡ تَهۡتَدُونَ ١٥﴾ النحل: ١٥

មានន័យថា៖«ទ្រង់បានទម្លាក់ភ្នំមកលើផែនដីដើម្បីទប់លំនឹងកុំឱ្យរញ្ជួយដល់ពួកអ្នក ហើយទ្រង់បង្កើតឱ្យមានទន្លេ និងផ្លូវដើម្បីឱ្យពួកអ្នកទៅដល់ទិសដៅដែលខ្លួនចង់ទៅ» ។

វិទ្យាសាស្ត្រទំនើបបានរកឃើញថា ភ្នំដែលដាក់ពង្រាយនៅលើផែនដីមានលក្ខណៈអស្ចារ្យជួយរក្សាតុល្យភាពផែនដី បោះបង្កប់ជាប់មិនងាយនឹងរបើក និងរញ្ជួយឡើយ ជាពិសេសភ្នំដែលពួកភូគព្ភវិទូហៅថា (ជួរភ្នំខ្វាត់ខ្វែង) ដែលមាននៅពាសពេញទ្វីបទាំងឡាយនៃសកលលោក។ តើបុរសអនក្ខរកម្មរស់នៅក្នុងសង្គមមួយមនុស្សភាគច្រើនមិនចេះអក្សរអាចដឹងពីវិទ្យាស្រ្តពិតនេះយ៉ាងដូចម្តេច?

## ទឹក និងជីវិត

អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿وَجَعَلْنَا مِنَ الْمَاءِ كُلَّ شَيْءٍ حَيٍّ أَفَلَا يُؤْمِنُونَ ﴿٣٠﴾﴾ الأنبياء: ٣٠

មានន័យថា៖ «ដោយសារទឹកធ្វើឱ្យអ្វីៗគ្រប់យ៉ាងមានជីវិត តើពួកគេមិនព្រមជឿទេឬ?» ។

វិទ្យាសាស្ត្រទំនើបបានរកឃើញថា ទឹកជាសារជាតុដើមក្នុងការបង្កើតកោសិកាមានជីវិត។ ហេតុនេះ គីមីវិទ្យាតាមការស្រាវជ្រាវទំនើបបានរកឃើញថា ទឹកជាជាតុចាំបាច់ និងសកម្មសម្រាប់អ្វីគ្រប់យ៉ាងដែលកើតឡើងទាំងការប្រែប្រួល និងការប្រតិកម្មនានាដែលប្រព្រឹត្តទៅនៅក្នុងរាងកាយ អាចជាមធ្យោបាយ ជាកត្តាជំនួយ ឬចូលរួមក្នុងការធ្វើប្រតិកម្ម ឬការផលិត។ ដោយហេតុនេះ ទឹកជាជាតុរាវតែមួយគត់ដែលសភាវៈមានជីវិតទាំងអស់មិនអាចខ្វះបាន ទោះជាសភាវៈ

នោះមានទំហំ ឬទ្រង់ទ្រាយតូច ឬធំ ចាប់ផ្តើមពីក្រុមមេក្រុបរហូតដល់សភាវៈមានជីវិតដ៏ធំបំផុតដែលមាននៅលើភពផែនដី។

ផ្ទៃទឹកដែលគ្របដណ្តប់លើផែនដី ក្នុងពេលបច្ចុប្បន្នមានប្រមាណជា ៧១% ហើយ ២៩% ដែលនៅសល់គឺជាដីគោក។ ប្រភពចម្បងនៃខ្លួនប្រាណមនុស្សយើង និងសត្វគឺជាជាតុទឹក ក៏ដូចគ្នាផងដែរចំពោះរុក្ខជាតិ។ តាមរយៈវិទ្យាសាស្រ្តវិភាគបានបង្ហាញឲ្យឃើញថា ខ្លួនប្រាណមនុស្សពេញវ័យ ដែលមានអាយុចាប់ពី ១៥ឆ្នាំ ឡើងទៅ មានជាតិទឹកប្រមាណជា ៧១% ចំពោះកុមារមានជាតិទឹក ៩៣% ដែលចង្អុលបង្ហាញឲ្យឃើញថា មានទឹក ៨០% ដែលមាននៅក្នុងខ្លួនប្រាណមនុស្ស និងភាគរយដែលនៅសល់គឺជាឈាម ហើយនៅក្នុងខ្លួនរបស់សត្វ និងរុក្ខជាតិមានជាតុទឹកច្រើនរហូតដល់ទៅ ៩០%។

**តើអ្នកដឹងអ្វីខ្លះអំពី** :

**១. វិហារកៈហ្ពះ :**

ជាវិហារដំបូងបង្អស់ដែលគេកសាងឡើងនៅលើផែនដី អល់ឡោះជាម្ចាស់បានមានព្រះបន្ទូលថា៖

﴿ إِنَّ أَوَّلَ بَيْتٍ وُضِعَ لِلنَّاسِ لَلَّذِى بِبَكَّةَ مُبَارَكًا وَهُدًى لِّلْعَٰلَمِينَ ٩٦ فِيهِ ءَايَٰتٌۢ بَيِّنَٰتٌ مَّقَامُ إِبْرَٰهِيمَ ﴾ آل عمران: ٩٦-٩٧

មានន័យថា៖ «ពិតប្រាកដ វិហារដំបូងបង្អស់ដែលគេកសាងឡើងសម្រាប់មនុស្ស គឺវិហារដែលនៅនគរមឹក្កះជាទីឋានដ៏មានពរជ័យ

ហើយជាទីដ៏មានប្រយោជន៍ និងជាសេចក្ដីចង្អុលបង្ហាញសម្រាប់សកលលោកទាំងមូល។ ក្នុងវិហារនេះមានភស្តុតាងបញ្ជាក់យ៉ាងច្បាស់ថាជាស្នាដៃកសាងរបស់អ៊ីព្រហ៊ីម គឺកន្លែងផ្ទាំងថ្មដែលអ៊ីព្រហីមឈរមើលនៅពេលសង់ខឿនវិហារនេះឡើង» ។

កសាងឡើងដោយអាដាំ ហើយកសាងឡើងវិញជាថ្មីដោយអ៊ីព្រហ៊ីមជាបិតានៃពួកព្យាការី។ នៅពេលដែលប្រពន្ធរបស់គាត់ឈ្មោះហាចើរកើតកូនប្រុសឈ្មោះអ៊ិស្មាអែល ប្រពន្ធគាត់ឈ្មោះសារ៉ោះប្រចណ្ឌ ហើយប្រើឱ្យអ៊ីព្រហ៊ីមយកពួកគេទាំងពីរទៅនៅឆ្ងាយពីខ្លួន។ ខណៈនោះ អល់ឡោះជាម្ចាស់ទ្រង់បានត្រាស់បន្ទូលមកគាត់ឱ្យនាំពួកគេទាំងពីរទៅកាន់ទឹកដីម៉ឹកក៉ះដ៏ពិសិដ្ឋ។ ឮដូច្នេះ អ៊ីព្រហ៊ីមបានស្ដាប់តាមការត្រាស់បន្ទូលរបស់ព្រះជាម្ចាស់របស់គាត់ ហើយបាននាំពួកគេទាំងពីរទៅកាន់ទីនោះ។ កាលនោះគាត់តែងមកសួរសុខទុក្ខប្រពន្ធកូនពីចន្លោះពេលមួយទៅចន្លោះពេលមួយ។ មួយរយៈក្រោយមក គាត់ទៅម្ដងទៀត ហើយអ៊ិស្មាអែលកំពុងធ្វើគ្រាប់ព្រួញនៅក្រោមដើមឈើមួយនៅក្បែរអណ្ដូងហ្សំហ្សំ។ លុះឃើញឪពុកមកដល់ ក៏ស្ទុះមកឱបឪពុក ហើយឪពុកក៏ស្ទុះទៅឱបកូន។ បន្ទាប់មកគាត់បាននិយាយថា៖ នែអ៊ិស្មាអែលកូនសម្លាញ់ ពិតប្រាកដ អល់ឡោះទ្រង់បានត្រាស់បង្គាប់ឱ្យឪពុកធ្វើកិច្ចការមួយ។ កូនក៏បានតបទៅឪពុលវិញថា សូមឪពុកធ្វើតាមការបង្គាប់របស់ព្រះជាម្ចាស់ចុះ! លោកសួរថា តើកូនឯងជួយឪពុកទេ? កូនតបវិញថា កូននឹងជួយឪពុក។ គាត់និយាយថា ពិតប្រាកដ អល់ឡោះជាម្ចាស់បានបង្គាប់ឱ្យឪពុកកសាងវិហារមួយនៅទីនេះ គាត់ក៏បានចង្អុលទៅផ្ទាំងថ្មខ្ពស់មួយ។ នៅទីនោះ ដែលពួក

គាត់ទាំងពីរបានលើកខឿនវិហារ អ៊ិស្មាអែលជាអ្នកជញ្ជូនថ្ម ហើយ អ៊ីព្រហ៊ីមជាអ្នករៀបថ្មដើម្បីកសាង។ លុះរៀបបានខ្ពស់ហើយ អ៊ិស្មាអែលបានលីដុំថ្មមួយ (ថ្មអាល់ម៉ាកោម) ដាក់ឱ្យឪពុក។ គាត់ឈរលើថ្មនេះដើម្បីកសាងបន្ត ហើយអ៊ិស្មាអែលហុចថ្មឱ្យគាត់។ ក្នុងពេលកំពុងកសាងនោះ ទាំងកូនទាំងឪពុកបួងសួងថា៖

( رَبَّنَا تَقَبَّلْ مِنَّا إِنَّكَ أَنْتَ السَّمِيْعُ الْعَلِيْمُ )

មានន័យថា៖ «ឱព្រះជាម្ចាស់សូមទ្រង់មេត្តាទទួលយកពីពួកយើងផងចុះ ទ្រង់មហាឮ មហាដឹង»។ គាត់ទាំងពីរបានកសាងរហូតដល់ជុំវិញវិហារ (ហ្វាត់ហុលហ្ពារី ៣៣៦៤)។

កៈហ្ពះជាទីកន្លែងដែលពួកមូស្លីមទូទាំងសកលលោកឆ្ពោះសំដៅទៅពេលចង់ថ្វាយបង្គំ ជានិមិត្តសញ្ញាសម្គាល់ការឯកភាពខាងជំនឿ និងជាទិសដៅសម្រាប់ពួកអ្នកមូស្លីមសំដៅឆ្ពោះទាំងកាយ ចិត្ត វិញ្ញាណទៅកាន់អល់ឡោះជាម្ចាស់នៃសកលលោក។ អល់ឡោះជាម្ចាស់បានមានព្រះបន្ទូលថា៖

﴿فَأَيۡنَمَا تُوَلُّواْ فَثَمَّ وَجۡهُ ٱللَّهِ﴾ البقرة: ١١٥

មានន័យថា៖ «បើទោះជាទិសណាក៏ដោយដែលពួកអ្នកតម្រង់ទៅគឺទីនោះជាទិសរបស់អល់ឡោះ» ។

ពួកអ្នកមូស្លីមសំដៅទៅកាន់កៈហ្ពះ តាវ៉ាហ្វជុំវិញ (ធ្វើធម្មយាត្រាជុំវិញ)កៈហ្ពះ។ ពុំមែនសក្ការៈចំពោះវិហារនេះទេ តែជាការគោរពសក្ការៈចំពោះអល់ឡោះជាម្ចាស់។ ដូចទ្រង់បានមានព្រះបន្ទូលថា៖

﴿ فَلۡيَعۡبُدُواْ رَبَّ هَٰذَا ٱلۡبَيۡتِ ٣ ٱلَّذِيٓ أَطۡعَمَهُم مِّن جُوعٖ وَءَامَنَهُم مِّنۡ خَوۡفِۭ ٤ ﴾ قريش: ٣-٤

មានន័យថា៖ «ចូរឱ្យពួកគេគោរពសក្ការៈចំពោះព្រះជាម្ចាស់នៃវិហារនេះ ដែលទ្រង់បានប្រទានចំណីអាហារដល់ពួកគេឱ្យរួចផុតពីគ្រោះទុរភិក្ស និងប្រទានសេចក្ដីសុខសុវត្ថិភាពមិនឱ្យពួកគេភ័យខ្លាច»។

## ២. ថ្មខ្មៅ :

ជាថ្មមួយមកពីឋានសួគ៌ ដូចជាអ្នកនាំសារមូហាំម៉ាត់បានមានប្រសាសន៍ថា៖ «ថ្មខ្មៅមកពីឋានសួគ៌»។

នៅពេលដែលអ៊ីព្រហ៊ីមកសាងកៈហ្ពះ ហើយកូនប្រុសរបស់គាត់អ៊ីស្មាអែលជញ្ជូនថ្មឱ្យគាត់។ លុះកសាងដល់កន្លែងថ្មខ្មៅអ៊ីព្រហ៊ីមនិយាយទៅកាន់អ៊ីស្មាអែលថា កូនឯងរកថ្មមួយដុំ ឪពុកចង់យកវាដាក់ត្រង់នេះ ដើម្បីជាសញ្ញាប្រាប់ឱ្យមនុស្សចាប់ផ្ដើមតាវ៉ាហ្វជុំវិញកៈហ្ពះនៅត្រង់នេះ។ អ៊ីស្មាអែលក៏ដើរទៅរក លុះត្រឡប់មកវិញស្រាប់តែឃើញឪពុកខ្លួនបានរៀបថ្មខ្មៅត្រង់កន្លែងនោះ ក៏និយាយថា លោកឪពុក! តើនរណាយកដុំថ្មនេះមកឱ្យឪពុក? គាត់តបវិញថា នាំមកដោយអ្នកដែលមិនពឹងលើការកសាងរបស់កូនឯង គឺទេវតាជីព្រីលនាំមកពីលើមេឃ បន្ទាប់មកពួកគេទាំងពីរក៏កសាងបង្ហើយ...។

ថ្មនេះពណ៌ខ្មៅរាងក្រហមនៅត្រង់ជ្រុងខាងត្បូងនៃកៈហ្ពះ នៅខាងឆ្វេងទ្វារកៈហ្ពះ។ ខ្ពស់ផុតពីដីប្រហែលជា១.១០ម៉។ រៀបបង្គប់

ភ្ជាប់នឹងជញ្ជាំងកៈហ្ពះ អ្នកដែលតាវ៉ហ្វត្រូវឈរពីខាងស្តាំថ្មនេះ ចាប់ផ្តើមតាវ៉ាហ្វ ហើយបញ្ចប់មួយជុំតាវ៉ាហ្វនៅត្រង់កន្លែងនេះផងដែរ។

**៣. ម៉ាកោមអ៊ីព្រហ៊ីម :**

គឺជាផ្ទាំងថ្មដែលអ៊ីព្រីមឈរមើលនៅពេលកសាងកៈហ្ពះ។ នៅពេលដែលកសាងរឹតតែខ្ពស់ផុតដៃ ហើយពិបាកនឹងរៀបថ្ម គាត់បានលើកបន្ទប់ថ្ម ហើយឈរលើនោះដើម្បីបន្តរៀបថ្មដែលកូនរបស់គាត់បានជញ្ជូនមកឱ្យគាត់។ រហូតដល់មានស្នាមដានបាតជើងជាប់នឹងថ្មនោះ។ អ៊ីព្រហ៊ីមជាអ្នកកសាង ហើយអ៊ីស្មាអែលកូនរបស់គាត់ជាអ្នកជញ្ជូនថ្មរហូតដល់កសាងរួចរាល់។ ពួកគាត់ទាំងពីរបួងសួងថា៖

( رَبَّنَا تَقَبَّلْ مِنَّا إِنَّكَ أَنْتَ السَّمِيْعُ الْعَلِيْمُ )

មានន័យថា៖ «ឱព្រះជាម្ចាស់សូមទ្រង់មេត្តាទទួលយកពីពួកយើងផងចុះ ទ្រង់មហាឮ មហាដឹង» (អាល់ហ្បាកោរ៉ោះ ១២៧)។

ដានជើងទាំងពីររបស់អ៊ីព្រីមនៅសល់រហូតដល់សព្វថ្ងៃ ត្រូវគេហ៊ុំព័ទ្ធដោយកញ្ចក់ក្រាស់បិទជិតដើម្បីរក្សាពីសំណឹកដោយសារអាកាសធាតុ។ គាត់បានបង្គាប់ឱ្យពួកអ្នកមូស្លីមថ្វាយបង្គំនៅទីនោះអនុវត្តតាមព្រះបន្ទូលរបស់ទ្រង់ថា៖

﴿ وَإِذْ جَعَلْنَا ٱلْبَيْتَ مَثَابَةً لِّلنَّاسِ وَأَمْنًا وَٱتَّخِذُوا۟ مِن مَّقَامِ إِبْرَٰهِـۧمَ مُصَلًّى ﴾
البقرة: ١٢٥

មានន័យថា៖ «មូហាំម៉ាត់ ចូររំឭកចុះ នៅពេលដែលយើងបានបង្កើតវិហារកៈហ្ពះជាទីសក្ការៈសម្រាប់មនុស្ស និងជាទីដ៏មានសុវត្ថិភាព

ហើយយើងបានបង្គាប់ឱ្យពួកគេយកម៉ាកោមរបស់អ៊ីព្រហ៊ីមជាកន្លែងសម្រាប់ថ្វាយបង្គំ» ។

ដានបាតជើងនេះជានិមិត្តញ្ញានៃនិមិត្តសញ្ញាទាំងឡាយរបស់អល់ឡោះ ហើយអានុស្សាវរីយ៍ដ៏អមតៈរបស់គាត់។ ថ្មជ្រុង និងថ្មម៉ាកោមរបស់អ៊ីព្រហ៊ីមានប្រភពជាត្បូងនៅឋានសួគ៌ ដោយព្យាការីមូហាំម៉ាត់លោកបានមានប្រសាសន៍ថា៖

مسافع بن شيبة الحجبي قال : سمعت عبد الله بن عمرو يقول : سَمِعْتُ رَسُوْلَ الله صلى الله عليه وسلم يَقُوْلُ وَهُوَ مُسْنِدُ ظَهْرِهِ إِلَى الْكَعْبَةِ : ( اَلرُّكْنُ وَالْمَقَامُ يَاقُوْتَتَانِ مِنْ يَوَاقِيْتِ الْجَنَّةِ وَلَوْلَا أَنَّ اللهَ طَمِسَ عَلَى نُوْرِهِمَا لَأَضَاءَتَا مَا بَيْنَ الْمَشْرِقِ وَالْمَغْرِبِ) رواه ابن حبان

មានន័យថា៖ «នៅពេលដែលអ្នកនាំសារផ្អែកនឹងជញ្ជាំកៈហ្បះគាត់បានមានប្រសាសន៍ថា ជ្រុងកៈហ្បះ និងម៉ាកោមអ៊ីព្រហ៊ីមជាត្បូងមកពីឋានសួគ៌ កុំតែអល់ឡោះរំលាយពន្លឺរបស់វា ម្ល៉េះត្បូងទាំងពីរនេះនឹងបញ្ចេញពន្លឺបំភ្លឺពីទិសខាងកើតរហូតដល់ខាងលិច» ។

**៤. ភ្នំនួរ :**

ភ្នំនេះដែលអ្នកនាំសារមូហាំម៉ាត់បានទៅតាំងនៅ ដើម្បីធ្វើសក្ការៈក្នុងរូងភ្នំ គេហៅថា រូងហេរ៉ក មុននឹងគេតែងតាំងលោកជាអ្នកនាំសារ។ កាលនោះ គាត់ពេញចិត្តចង់នៅតែឯងដាច់ពីគេ គាត់ចំណាយពេលក្នុងរូងភ្នំនេះរាប់យប់មានចំនួនកំណត់ ដើម្បីគោរពសក្ការៈចំពោះព្រះជាម្ចាស់ ត្រិះរិះពិចារណាអ្វីទាំងឡាយដែលនៅជុំវិញគាត់។ គាត់មិនសប្បាយចិត្តចំពោះអ្វីដែលសាសន៍របស់គាត់កំពុងប្រព្រឹត្តដូចជាអំពើពហុទេព និងជំនឿខុស។ ក្នុងរូងភ្នំនេះដែរ ទេវតា

ជីព្រីលបានចុះមកផ្តល់ការត្រាស់បន្ទូលរបស់អល់ឡោះជាម្ចាស់ពីលើមេឃមកជូនគាត់ ជាសេចក្តីប្រកាសឱ្យដឹងពីការចាប់ផ្តើមតែងតាំងគាត់ជាព្យាការី។

**៤. អណ្តូងហ្សាំហ្សាំ :**

ខណៈដែលអ៊ីព្រហ៊ីមបាននាំម្តាយអ៊ីស្មាអែល និងកូនរបស់គាត់ដែលនៅបៅដោះឈ្មោះអ៊ីស្មាអែល ដោយការត្រាស់បង្គាប់ពីអល់ឡោះជាម្ចាស់ឱ្យដាក់**គាត់**នៅត្រង់វិហារដែលមានដើមឈើដុះនៅក្បែរអណ្តូងហ្សាំហ្សាំ។ កាលនោះមឹក្កះពុំទាន់មានរណាម្នាក់រស់នៅ គ្មានទឹក គ្មានអ្វីទាំងអស់ ហើយអ៊ីព្រហ៊ីបានដាក់ម្តាយកូនឱ្យនៅទីនោះ។ គាត់បានទុកផ្លែល្មើឱ្យមួយថង់ និងទឹកមួយថង់ស្បែក។ បន្ទាប់មក អ៊ីព្រហ៊ីមបានត្រលប់ក្រោយ ហើចាកចេញទៅ។ ម្តាយអ៊ីស្មាអែលបានរត់តាមពីក្រោយ ហើយនិយាយ**ថា៖** នែអ៊ីព្រីហ៊ីម តើអ្នកទៅណា តើលោកប្រុងទុកយើងចោលនៅជ្រលងភ្នំដែលគ្មានមនុស្សគ្មានអ្វីទាំងអស់នេះមែនទេ? គាត់បាននិយាយពាក្យនេះដដែលៗច្រើនដង តែអ៊ីព្រហ៊ីមមិនព្រមងាកមើលគាត់សោះ។ **គាត់**ក៏សួរបន្តថា តើអល់ឡោះប្រើឱ្យអ្នកធ្វើអ៊ីចឹងឬ? អ៊ីព្រហ៊ីមឆ្លើយថា ត្រូវហើយ។ គាត់ក៏តបវិញថា៖ បើអ៊ីចឹងទ្រង់នឹងមិនបោះបង់យើងចោលឡើយ។ គាត់ក៏ត្រលប់មកក្រោយវិញ ហើយអ៊ីព្រហ៊ីមចាកចេញទៅរហូតដល់តំបន់ សានីយះ ដែលពួកគេលែងឃើញគាត់ គាត់ក៏បែរមុខទៅកាន់វិហារ ហើយបានបួងដោយពាក្យប៉ុន្មានម៉ាត់លើកដៃឡើងលើថា៖

﴿رَّبَّنَآ إِنِّيٓ أَسۡكَنتُ مِن ذُرِّيَّتِي بِوَادٍ غَيۡرِ ذِي زَرۡعٍ عِندَ بَيۡتِكَ ٱلۡمُحَرَّمِ

﴿رَبَّنَا لِيُقِيمُواْ ٱلصَّلَوٰةَ فَٱجۡعَلۡ أَفۡـِٔدَةٗ مِّنَ ٱلنَّاسِ تَهۡوِيٓ إِلَيۡهِمۡ وَٱرۡزُقۡهُم مِّنَ ٱلثَّمَرَٰتِ لَعَلَّهُمۡ يَشۡكُرُونَ ٣٧﴾ إبراهيم: ٣٧

មានន័យថា៖ «បពិត្រព្រះជាម្ចាស់ ខ្ញុំបានដាក់គ្រួសារខ្ញុំឱ្យរស់នៅកន្លែងជ្រលងភ្នំដែលគ្មានដំណាំនៅឯវិហារដ៏ពិសិដ្ឋរបស់ទ្រង់។ បពិត្រព្រះជាម្ចាស់ ខ្ញុំធ្វើតាមការបង្គាប់របស់ទ្រង់ ដើម្បីឱ្យពួកគេប្រតិបត្តិការថ្វាយបង្គំតាមពេលកំណត់ សូមទ្រង់ប្រែចិត្តមនុស្សឱ្យមានសេចក្តីប្រាថ្នាចង់ទៅកាន់ពួកគេ សូមទ្រង់មេត្តាប្រទានលាភសក្ការៈដល់ពួកគេនូវផ្លែឈើច្រើនប្រភេទ សង្ឃឹមថា ពួកគេនឹកដឹងគុណចំពោះទ្រង់»។

ម្តាយអ៊ីស្មាអែលបានចិញ្ចឹមកូន ហើយទទួលទានចំណី និងទឹកដែលប្តីបានទុកឱ្យ។ លុះដល់អស់ស្បៀង រូបគាត់ ព្រមទាំងកូនស្រេកទឹក គាត់ឃើញកូនស្រេកយំខ្លាំងពេក ព្រោះស្រេកទឹក ទ្រាំទៀតមិនបាន មើលឃើញភ្នំសាហ្វានៅជិតជាងគេ គាត់ក៏រត់ឡើងទៅលើភ្នំនោះ សំឡឹងមើលទៅជ្រលងភ្នំ ខ្លាចក្រែងឃើញមានមនុស្សមនា តែមិនឃើញមានមនុស្សណាម្នាក់សោះ។ គាត់បានចុះពីលើភ្នំសាហ្វា ដើរចុះទៅជ្រលងភ្នំ គាត់បានកាន់ជាយសំពត់ម្ខាងហើយប្រឹងដើរដូចជាមនុស្សដើរអស់ជើង ដើររហូតផុតជ្រលងភ្នំ។ បន្ទាប់មក គាត់បានសំដៅទៅកាន់ភ្នំម៉ារ៉ាវ៉ះ ឡើងលើភ្នំ ហើយឈរសំឡឹងមើលទៅក្រោមខ្លាចក្រែងមានមនុស្សមនា តែពុំមានឃើញនរណាម្នាក់សោះ គាត់ធ្វើដូច្នេះប្រាំពីរដង។ អិពនូ អាបាស និយាយថា អ្នកនាំសារមូហាំម៉ាត់បានមានប្រសាសន៍ថា៖ នោះគឺជាសាអ៊ី (ដំណើរឡើងចុះ) របស់អ្នកធ្វើបុណ្យហ៍ជរវាងភ្នំទាំងពីរ។ លុះគាត់ឡើងដល់លើភ្នំ គាត់បានឮសំ

លេង ហើយនិយាយថា នៅស្ងៀម និយាយជាមួយខ្លួនឯង។ បន្ទាប់មក គាត់បានឮសំលេងទៀត ហើយគាត់និយាយជាមួយខ្លួនឯងថា ឮទេ! មានគេមកជួយសង្គ្រោះហើយ ក៏ស្រាប់តែមានទេវតានៅត្រង់កន្លែងអណ្តូងហ្សាំហ្សាំ ទេវតានោះបានយកស្លាបចាក់ទៅក្រោម ធ្វើឱ្យផុសទឹកចេញក្រៅ ហើយគាត់ចាប់ផ្តើមយកដៃកាយដីទប់ទឹក។ គាត់បាន**ក**ក្បង់ទឹកដាក់ក្នុងថង់ស្បែក ទឹកនោះបានស្រកទៅវិញបន្ទាប់ពីគាត់បានក្បង់។ អិពន្ធ អាបាសនិយាយថា អ្នកនាំសារមូហាំម៉ាត់បានប្រសាសន៍ថា អល់ឡោះជាម្ចាស់ទ្រង់អាណិតមេត្តាចំពោះម្តាយអ៊ិស្មាអែល បើសិនជាគាត់ទុកឱ្យទឹកហ្សាំហ្សាំហៀចោល ឬមិនបានក្បង់ដាក់ក្នុងថង់ស្បែកទេនោះ ម្ល៉េះទឹកហ្សាំហ្សាំនឹងហូរក្លាយទៅជាទន្លេ។ គាត់បានផឹកទឹកហ្សាំហ្សាំនោះ ហើយបានបំបៅកូន ទេវតាបានប្រាប់គាត់ថា ចូរកុំខ្លាចអស់ទឹក ពីព្រោះទីនេះ ជាវិហាររបស់អល់ឡោះ ដែលក្មេងនេះនិងឪពុករបស់គេនឹងកសាងវិហារនេះឡើង។ ពិតប្រាកដ អល់ឡោះនឹងមិនទុកពួកអ្នកចោលឡើយ (ហ្វាត់ហុលបារីយ៍ ៣៣៦៤)។ អណ្តូងនេះនៅសល់រហូតដល់សព្វថ្ងៃ ពួកអ្នកមូស្លីមបានយកមកផឹក និងទុកនាំយកទៅកាន់ស្រុកទេសរបស់ខ្លួនផងដែរថ។

### <u>៥- ភ្នំសាហ្វា និងម៉ារ៉េវ៉ះ :</u>

សាហ្វា និងម៉ារ៉េវ៉ះជាភ្នំពីរដែលម្តាយរបស់អ៊ីស្មាអែលបានឡើងចុះដើម្បីរកអ្នកជួយសង្គ្រោះខ្លួនឯង និងកូនរបស់គាត់អ៊ីស្មាអែលខណៈដែលអស់ទឹក និងអស់ស្បៀង។ ក្នុងការប្រារព្ធពិធីបុណ្យហាជ្ជ ឬអ៊ុំរ៉ោះ មនុស្សនាំគ្នាធ្វើដំណើរឡើងចុះលើភ្នំទាំងពីរនេះជាការរក្សាភាពអមតៈនៃអនុស្សាវរីយ៍នេះ ហើយក៏ជាការប្រតិបត្តិតាមធម្មនិយម និង

តំកើងអត្តសញ្ញាណសាសនាឥស្លាម ព្រមទាំងជាការរំឭកដល់ពរជ័យរបស់អល់ឡោះចំពោះហាចើរ និងកូនរបស់គាត់ឈ្មោះអ៊ិស្មាអែល ខណៈដែលទ្រង់បានជួយសង្គ្រោះគាត់ពីការស្រេកឃ្លាន។ ដូចមាននិយាយនៅក្នុងហាទីសរបស់អ៊ិពនូអាបាសថា៖ «ទ្រាំទៀតមិនបានមើលឃើញភ្នំសាហ្វានៅជិតជាងគេ គាត់ក៏រត់ឡើងទៅលើភ្នំនោះ សំឡឹងមើលទៅជ្រលងភ្នំ ខ្លាចក្រែងឃើញមានមនុស្សមនា តែមិនឃើញមានមនុស្សណាម្នាក់សោះ។ គាត់បានចុះពីលើភ្នំសាហ្វា ដើរចុះទៅជ្រលងភ្នំ គាត់បានកាន់ជាយសំពត់ម្ខាងហើយប្រឹងដើរដូចជាមនុស្សដើរអស់ជើង ដើររហូតផុតជ្រលងភ្នំ។ បន្ទាប់មក គាត់បានសំដៅទៅកាន់ភ្នំម៉ារ៉ាវ៉ះ ឡើងលើភ្នំ ហើយឈរសំឡឹងមើលទៅក្រោមខ្លាចក្រែងមានមនុស្សមនា តែពុំមានឃើញនរណាម្នាក់សោះ គាត់ធ្វើដូច្នេះប្រាំពីរដង។ អ៊ិពនូ អាបាស និយាយថា អ្នកនាំសារមូហាំម៉ាត់បានប្រសាសន៍ថា៖ នោះគឺជាសាអ៊ី (ដំណើរឡើងចុះ) របស់ពួកអ្នកធ្វើបុណ្យហ័ជរវាងភ្នំទាំងពីរ»។ អាល់ពូខោរីយ៍។

**៦-ការគប់ក្រួស :**

ជាកន្លែងទាំងឡាយដែលបិសាចស្សៃតោនបានបង្ហាញខ្លួនឱ្យអ៊ីព្រហីមឃើញ នៅពេលដែលគាត់បានចាប់ផ្តើមអនុវត្តតាមការបង្គាប់របស់ព្រះជាម្ចាស់យកកូនទៅធ្វើពិឃាតបូជា។ បិសាចចង់ល្បួងឱ្យអ៊ីព្រហីមបោះបង់ការអនុវត្តតាមការបង្គាប់របស់អល់ឡោះ។ នៅត្រង់កន្លែងទាំងនេះ អ៊ីព្រហីមបានកាន់គ្រាប់ក្រួស ហើយគប់ចំមុខបិសាចនោះដោយពោលពាក្យថា (الله أكبر) មានន័យថាអល់ឡោះមហាធំ ហើយបួងសួងសុំឱ្យទ្រង់ការពារគាត់ពីបិសាចនោះ។ អ៊ិពនូ អាបាស

ដែលមានងារជាដបទឹកខ្មៅនៃប្រជាជាតិឥស្លាមបាននិយាយថា ខណៈដែលអ៊ីព្រហីមសំណព្វចិត្តរបស់អល់ឡោះ មកដល់ទីសក្ការៈទាំងឡាយ (مناسك) បិសាចបានបង្ហាញខ្លួននៅទ្រង់គោលអាកោហ្គះ គាត់បានគប់វាចំនួន៧គ្រាប់គ្រួស រហូតដល់កប់បាត់ទៅក្នុងដី។ វាបង្ហាញខ្លួនម្តងទៀតនៅគោលទី២ គាត់បានគប់វាចំនួន៧គ្រាប់គ្រួស រហូតដល់កប់បាត់ទៅក្នុងដី។ បន្ទាប់មក វាបានបង្ហាញខ្លួនឱ្យគាត់ឃើញនៅគោលទី៣ គាត់បានគប់វាចំនួន៧គ្រាប់គ្រួសទៀត រហូតដល់កប់បាត់ទៅក្នុងដី។ អិពនូ អាបាស និយាយថា បិសាចស្បៃតោនត្រូវគេគប់ប្រហារ ហើយពួកអ្នកធ្វើតាមសាសនាបិតារបស់ពួកអ្នកគឺ អ៊ីព្រហ៊ីម។

នៅពេលអល់ឡោះជាម្ចាស់សាកដឹងពីចិត្តស្មោះត្រង់របស់អ៊ីព្រហ៊ីមក្នុងការអនុវត្តតាមការបង្គាប់របស់ទ្រង់ ទ្រង់បានឱ្យថ្នូរនឹងកូនរបស់គាត់អ៊ីស្មាអែលដោយសត្វពពែធំមួយក្បាលដើម្បីសំឡេះជំនួសកូនរបស់គាត់។ ដូច្នេះ ការធ្វើពិឃាតសត្វបូជារបស់ពួកអ្នកមូស្លីមក្លាយជាធម្មនិយមសម្រាប់ពួកគេដើម្បីបូជាចំពោះអល់ឡោះ ដឹងគុណចំពោះទ្រង់ ហើយជាការរំឭកអនុស្សាវរីយ៍អមតៈរបស់គាត់ទាំងពីរ។ អល់ឡោះជាម្ចាស់បានមានព្រះបន្ទូលថា៖

﴿ وَفَدَيْنَٰهُ بِذِبْحٍ عَظِيمٖ ﴿١٠٧﴾ ﴾ الصافات: ١٠٧

មានន័យថា៖ «យើងបានសង្គ្រោះអ៊ីស្មាអែលជំនួសដោយសត្វពពែធំមួយក្បាល»។

ពួកអ្នកមូស្លីមក្នុងពិធីបុណ្យហាជ់របស់ពួកគេនៅពេលគប់គោល ពួកគេអនុវត្តតាមធម្មនិយមបិតារបស់ពួកគេអ៊ីព្រហ៊ីម ហើយបានដាក់បណ្តាសាចំពោះបិសាចស្ហៃតោនជាសត្រូវរបស់ពួកគេ។ ចាំបាច់ត្រូវប្រយុទ្ធប្រឆាំងជាមួយនឹងគេដោយការជំនះនឹងខ្លួនឯងខំប្រឹងប្រតិបត្តិតាមការបង្គាប់របស់អល់ឡោះ ហើយជៀសវាងពីបំរាមរបស់ទ្រង់។

**៧-ថ្ងៃបុណ្យឥស្លាម :**

សម្រាប់ពួកអ្នកមូស្លីមមានបុណ្យពីរដងក្នុង១ឆ្នាំ ទី១គឺបុណ្យរយ៉ាហ្វិតត្រោះ ប្រព្រឹត្តទៅនៅចុងខែរ៉ម៉ាដាន គេហៅដូច្នេះ ព្រោះពួកអ្នកមូស្លីមចាំបាច់ត្រូវបញ្ចប់បួសរបស់ពួកគេដោយការបង់ហ្សាកត់ហ្វិតត្រោះ។ ចែកចាយហ្សាកាត់នេះ ពីចំណីអាហារដែលប្រទេសនីមួយៗចាត់ទុកជាស្បៀង ចែកជូនដល់ពួកអ្នកទីទ័លក្រ និងពួកអ្នកខ្វះខាត។ បុណ្យរយ៉ាទី២គឺ បុណ្យរយ៉ាអាត់ហា (រយ៉ាហាជី) គេឱ្យឈ្មោះដូច្នេះព្រោះជាថ្ងៃដែលពួកអ្នកមូស្លីមនាំគ្នាសក្ការៈបូជាចំពោះអល់ឡោះជាម្ចាស់ដោយការសំឡេះសត្វប្រតិបត្តិតាមធម្មនិយមរបស់អ៊ីព្រហ៊ីម។ នៅពេលដែលគាត់យល់សប្តិឃើញអល់ឡោះប្រើឱ្យសំឡេះកូនរបស់គាត់អ៊ីស្មាអែល ហើយការយល់សប្តិរបស់ពួកព្យាការីគឺជាការពិត។ នៅពេលដែលអ៊ីព្រហ៊ីមប្តេជ្ញាចិត្តសំឡេះកូនរបស់គាត់អនុវត្តតាមការបង្គាប់របស់អល់ឡោះជាម្ចាស់ ទ្រង់បានជ្រាបពីចិត្តស្មោះត្រង់របស់គាត់ ទ្រង់បានជំនួសដោយសត្វពពែដ៏ធំមួយក្បាលចុះពីលើមេឃ ទ្រង់ប្រើឱ្យសំឡេះវាជំនួសកូនរបស់គាត់ (ស៊ូរ៉ោះ សាហ្វហ្វាត ១៩-១០១)។ ពួកអ្នកមូស្លីមបានរក្សាធម្មនិយមនេះដោយការអនុវត្តតាមបិតារបស់

ពួកគេអ៊ីព្រហ៊ីម ពួកគេនាំគ្នាសំឡេះសត្វធ្វើពិឃាតបូជា ហើយសាច់របស់វាចែកជូនដល់ពួកអ្នកទីទ័លក្រ និងខ្វះខាត។

## ៨- វិហាររបស់ព្យាការីមូហាំម៉ាត់ :

វិហារដំបូងបង្អស់ដែលគេកសាងឡើងក្នុងឥស្លាម កសាងដោយអ្នកនាំសារមូហាំម៉ាត់ជាមួយនឹងពួកអ្នកគាំទ្ររបស់គាត់ ខណៈដែលគាត់បានទៅដល់ទីក្រុងម៉ាឌីណះ។ គេកសាងត្រង់កន្លែងដែលសត្វអូដ្ឋរបស់គាត់បានទ្រោមចុះដោយការបង្គាប់ពីអល់ឡោះជាម្ចាស់។ នៅពេលគាត់ទៅដល់ម៉ាឌីណះ មនុស្សទាំងឡាយចង់កាន់ខ្សែអូដ្ឋនាំទៅចូលផ្ទះរបស់ពួកគេរៀងៗខ្លួន តែអ្នកនាំសារមូហាំម៉ាត់បានប្រាប់ឱ្យវាដើរដោយខ្លួនឯង ទុកឱ្យវាទ្រោមខ្លួនចុះនៅទីណាដែលអល់ឡោះជាម្ចាស់ទ្រង់បានបង្គាប់វា។ នៅត្រង់កន្លែងនោះទៀត ជាបន្ទប់ដេករបស់អ្នកនាំសារមូហាំម៉ាត់ ក៏ជាកន្លែងដែលគេបញ្ចុះសពរបស់គាត់។ ពីព្រោះពួកអ្នកនាំសារ ឬពួកព្យាការីទាំងអស់ត្រូវគេបញ្ចុះសពនៅត្រង់កន្លែងដែលពួកគាត់បានទទួលមរណភាព។ ចំពោះពួកអ្នកមូស្លីមនៅពេលទៅថ្វាយបង្គំនៅវិហាររបស់គាត់ ពួកគេនឹងដើរកាត់បន្ទប់ដេករបស់គាត់ គប្បីឱ្យសាឡាមស្វាគមន៍ចំពោះគាត់ និងបួងសួងសុំពីអល់ឡោះ ជូនគាត់។

## ៩-វិហារ បៃតុលមឹកឌិស ឬម៉ាស្ជិត អឹកសា

វិហារ បៃតុលមឹកឌិស ឬម៉ាស្ជិត អឹកសាជាតំបន់ដីដ៏ពិសិដ្ឋ ព្រះជាម្ចាស់ទ្រង់បានជ្រើសរើសតាំងពីទ្រង់បានបង្កើតសត្វលោកជាកន្លែងសក្ការៈសម្រាប់ពួកអ្នកដែលមានជំនឿលើព្រះតែមួយ។ គឺជាវិហារទី២

ដែលគេកសាងមុនដំបូងបង្អស់នៅលើផែនដី។ អំពី អាពូ ស៊ើរ និយាយថា ខ្ញុំបានសួរថា បពិត្រអ្នកនាំសាររបស់អល់ឡោះ តើវិហារណាដែលគេកសាងលើផែនដីនេះមុនគេបង្អស់? គាត់តបវិញថា គឺវិហារកៈហ្ពះ។ ចុះបន្ទាប់មកតើវិហារណាទៀត? គាត់តបវិញថា គឺវិហារម៉ាស្ជិតអឹកសា។ ខ្ញុំសួរទៀតថា តើរវាងវិហារទាំងពីរមានរយៈពេលប៉ុន្មានឆ្នាំ? គាត់តបវិញថា រយៈពេល៤០ឆ្នាំ បើអ្នកទៅទាន់ថ្វាយបង្គំ ចូរថ្វាយបង្គំចុះនៅទីនោះ ព្រោះវាជាវិហារ។ សហេស មូស្លីម

នៅពេលដែលអាដាំបានកសាងកៈហ្ពះរួច អល់ឡោះជាម្ចាស់ទ្រង់បានបង្គាប់ឱ្យគាត់ឆ្ពោះទៅកាន់វិហារបៃតុលមឹកឌិស។ ទ្រង់បង្គាប់ឱ្យគាត់កសាងវិហារនេះ គាត់ក៏បានកសាងវិហារនេះ ហើយបានធ្វើការសក្ការៈចំពោះអល់ឡោះក្នុងវិហារនេះ។ វិហារនេះជាការកសាងមុនដំបូងបង្អស់នៅលើទឹកដីកូឌុស។

ព្យាការីស៊ូឡៃម៉ាន ជាអ្នកកសាងឡើងវិញ ហើយពង្រីកវិហារនេះ។ អ្នកនាំសារមូហាំម៉ាត់បានមានប្រសាសន៍ថា៖ «ពិតប្រាកដស៊ូឡៃម៉ាន កូន ដាវូត នៅពេលកសាងវិហារ បៃតុលមឹកឌិសរួច គាត់បានបួងសួងសុំពីអល់ឡោះឱ្យទ្រង់ផ្តល់អំណាចដល់គាត់ស្រដៀងនឹងអំណាចរបស់ទ្រង់ ហើយក្លាយជាស្តេចដែលគ្មានមនុស្សជំនាន់ក្រោយណាដូចគាត់ ហើយបួងសួងសុំថា អ្នកដែលមកកាន់វិហារនេះគ្មានបំណងអ្វីក្រៅពីថ្វាយបង្គំនោះ លើកលែងតែគេលុបលាងកំហុសរបស់គេដូចថ្ងៃដែលខ្លួនគេកើតចេញពីពោះម្តាយរបស់គេ។ អ្នកនាំសារបានមានប្រសាសន៍ថា សំណូមពរទាំងពីរគេបានប្រទានឱ្យ ហើយខ្ញុំ

សង្ស៊ឹមថា សំណូមពរទីពាក់គេយល់ព្រមដែរ»។ (សហេស អិពនូ យូស៊ែម៉ះ)

វិហារនេះជាកិពឡាត់ដំបូងបង្អស់ ដែលអ្នកនាំសារមូហាំម៉ាត់បានថ្វាយបង្គំឆ្ពោះទៅវិហារនេះ ហើយពួកអ្នកមូស្លីមក៏ឆ្ពោះទៅកាន់វិហារនេះមុននឹងគេប្រើឱ្យពួកគេប្តូរមកវិហារកៈហ្ពះវិញ។ វិហារនេះជាទីដែលអ្នកនាំសារបានចេញដំណើរទៅកាន់នៅពេលយប់ ហើយទីនោះដែរដែលគាត់ឡើងទៅលើមេឃ។ នៅទីនោះលោកថ្វាយបង្គំដឹកនាំពួកព្យាការីទាំងឡាយក្នុងយប់ចេញដំណើរឡើងលើមេឃ។ ម្យ៉ាងទៀត វិហារនេះ ជាវិហារពិសិដ្ឋទីបីបន្ទាប់ពីវិហារពិសិដ្ឋទាំងពីរនៅមឹក្កះ និងម៉ាឌីណះ អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿سُبۡحَٰنَ ٱلَّذِيٓ أَسۡرَىٰ بِعَبۡدِهِۦ لَيۡلٗا مِّنَ ٱلۡمَسۡجِدِ ٱلۡحَرَامِ إِلَى ٱلۡمَسۡجِدِ ٱلۡأَقۡصَا ٱلَّذِي بَٰرَكۡنَا حَوۡلَهُۥ﴾ الإسراء: ١

មានន័យថា៖ «អល់ឡោះទ្រង់បានតំកើងព្រះអង្គឯង ដែលទ្រង់បានបង្គាប់ឱ្យនាំដំណើរខ្ញុំបម្រើរបស់ទ្រង់មូហាំម៉ាត់នៅពេលយប់ទៅទាំងរូបកាយ និងវិញ្ញាណចេញពីវិហារអាល់ហារ៉ាមទៅកាន់វិហារម៉ាស្ជិតអឹកសាដែលយើងបានប្រទានពរជ័យជុំវិញតំបន់នោះ»។

មិនតែប៉ុណ្ណោះ វិហារនេះ ឋិតក្នុងចំណោមវិហារដែលគេអនុញ្ញាតិឱ្យធ្វើដំណើរទៅដើម្បីថ្វាយបង្គំនៅទីនោះ មានហាទីសមួយបានឱ្យដឹងថា ការថ្វាយបង្គំក្នុងវិហារនេះ ផលបុណ្យកើនទ្វេជា៥០០សឡាត។ អ្នកនាំសារបានប្រសាសន៍ថា៖ "ចូរពួកអ្នកកុំធ្វើដំណើរទៅ

លើកលែងតែទៅកាន់វិហារទាំងបី វិហាររបស់ខ្ញុំ វិហារអាល់ហារ៉ាម និង វិហារម៉ាស្ជិតអឹកសា»។ សហេស អាល់ពូខោរីយ៍

**១០- វិហារសិលា**

សឹខរ៉ោះជាសិលា ឬជាផ្ទាំងថ្មមួយនៅវិហារ បៃតុលមឹកឌិស បិតនៅចំកណ្តាលទីធ្លាវិហារម៉ាស្ជិតអឹកសា។ ផ្ទាំងថ្មនេះមានកំពស់ ១៨ម៉ែត្រ ទទឹងលើសខ្ទះ១៣ម៉។ ដើមឡើយ ផ្ទាំថ្មនេះជាកិពឡាត់ ឬ ជាទិសថ្វាយបង្គំសម្រាប់ពួកអ្នកនាំសារនៃកូនចៅអ៊ីស្រាអែល ហើយក៏ ធ្លាប់ជាទិសថ្វាយបង្គំសម្រាប់ពួកអ្នកមូស្លីមមួយរយៈពេលខ្លីនៅដើម សម័យឥស្លាម។ បន្ទាប់មក គេបានលុបចោលដោយជំនួសកៈហ្ពះជា ទិសថ្វាយបង្គំវិញ។ អាល់បារ៉ក ពិន អាស៊ិបបាននិយាយថា៖ ពួកយើង បានថ្វាយបង្គំជាមួយអ្នកនាំសារមូហាំម៉ាត់ឆ្ពោះទៅទិសវិហារ បៃតុល មឹកឌិស រយៈពេល១៦ខែ ឬ១៧ខែ បន្ទាប់មកគេប្រើឱ្យពួកយើងបែរ ឆ្ពោះទៅកៈហ្ពះវិញ។

**ចងកំហឹង និងភ័យខ្លាចអំពីឥស្លាម ហេតុអ្វី?**

បងប្អូនប្រិយមិត្តអ្នកអានជាទីមេត្រី ក្រោយពេលអានសៀវភៅ នេះរួច គួរគប្បីប្តូរការយល់ខុសរបស់អ្នកអំពីឥស្លាម ជាពិសេសចំពោះ បងប្អូនដែលស្វែងយល់អំពីឥស្លាមពីប្រភពដែលគ្មានសេចក្តីទុកចិត្ត។ ឥស្លាមមានលក្ខណៈដូចតទៅ៖

- ជាសាសនារំដោះមនុស្សឱ្យមានសេរីភាពផ្នែកសាសនា។ អំពាវ នាវទៅរកការគោរពសក្ការៈចំពោះព្រះជាម្ចាស់តែមួយគត់។

អំពាវនាវឱ្យគោរពសិទ្ធិមនុស្ស អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿وَٱعۡبُدُواْ ٱللَّهَ وَلَا تُشۡرِكُواْ بِهِۦ شَيۡـٔٗاۖ وَبِٱلۡوَٰلِدَيۡنِ إِحۡسَٰنٗا وَبِذِي ٱلۡقُرۡبَىٰ وَٱلۡيَتَٰمَىٰ وَٱلۡمَسَٰكِينِ وَٱلۡجَارِ ذِي ٱلۡقُرۡبَىٰ وَٱلۡجَارِ ٱلۡجُنُبِ وَٱلصَّاحِبِ بِٱلۡجَنۢبِ وَٱبۡنِ ٱلسَّبِيلِ وَمَا مَلَكَتۡ أَيۡمَٰنُكُمۡۗ إِنَّ ٱللَّهَ لَا يُحِبُّ مَن كَانَ مُخۡتَالٗا فَخُورًا ٣٦﴾ النساء: ٣٦

មានន័យថា៖ «ចូរគោរពសក្ការៈចុះចំពោះអល់ឡោះ ស្តាប់តាមបង្គាប់ទ្រង់។ ចូរកុំគោរពរួមជាមួយទ្រង់នូវអ្វីមួយ។ ចូរកតញ្ញូ និងគោរពសិទ្ធិឪពុកម្តាយ សាច់ញាតិ កុមារកំព្រា អ្នកទីទ័លក្រ អ្នកជិតខាងដែលជាប់សាច់ញាតិ ញាតិជិតខាង មិត្តភក្តិរួមដំណើរ និងមិត្តភ័ក្តិរស់នៅក្នុងភូមិជាមួយគ្នា ហើយផ្តល់សិទ្ធិចំពោះខ្ញុំបម្រើទាំងប្រុសទាំងស្រី។ ពិតប្រាកដ អល់ឡោះជាម្ចាស់ទ្រង់មិនសព្វព្រះទ័យចំពោះមនុស្សក្អេងក្អាង និងក្រអឺតក្រទម»។

- ជាសាសនាសន្តិភាពប្រយុទ្ធប្រឆាំងនឹងអំពើហិង្សា អំពើអយុត្តិធម៌។ អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿لَّا يَنۡهَىٰكُمُ ٱللَّهُ عَنِ ٱلَّذِينَ لَمۡ يُقَٰتِلُوكُمۡ فِي ٱلدِّينِ وَلَمۡ يُخۡرِجُوكُم مِّن دِيَٰرِكُمۡ أَن تَبَرُّوهُمۡ وَتُقۡسِطُوٓاْ إِلَيۡهِمۡۚ إِنَّ ٱللَّهَ يُحِبُّ ٱلۡمُقۡسِطِينَ ٨﴾ الممتحنة: ٨

មានន័យថា៖ «អល់ឡោះជាម្ចាស់ទ្រង់មិនហាមឃាត់ពួកអ្នកពីពួកអ្នកមិនមែនមូស្លីមដែលមិនបានធ្វើសង្គ្រាមកាប់សម្លាប់ពួកអ្នកក្នុងបញ្ហាសាសនា ហើយពុំបានដេញពួកអ្នកចេញពីភូមិស្រុករបស់ពួកអ្នក ចូរ

ធ្វើល្អចំពោះពួកគេ និងផ្តល់យុត្តិធម៌ជូនពួកគេ។ ពិតប្រាកដណាស់ អល់ឡោះទ្រង់សព្វព្រះទ័យចំពោះពួកអ្នកដែលប្រកាន់នូវភាពយុត្តិធម៌»។

- ជាសាសនាឱ្យតម្លៃទៅលើចំណេះដឹង ដូចអល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿قُلۡ هَلۡ يَسۡتَوِي ٱلَّذِينَ يَعۡلَمُونَ وَٱلَّذِينَ لَا يَعۡلَمُونَ﴾ الزمر: ٩

មានន័យថា៖ «មូហាំម៉ាត់ ចូរប្រសាសន៍ចុះថា តើស្មើគ្នាដែរឬទេរវាងពួកអ្នកដែលមានចំណេះដឹងនិងពួកអ្នកដែលអវិជ្ជា»។

- ជាសាសនាស្អាតស្អំ និងអនាម័យ អល់ឡោះជាម្ចាស់បានមានព្រះបន្ទូលថា៖

﴿إِنَّ ٱللَّهَ يُحِبُّ ٱلتَّوَّٰبِينَ وَيُحِبُّ ٱلۡمُتَطَهِّرِينَ ٢٢٢﴾ البقرة: ٢٢٢

មានន័យថា៖ «ពិតប្រាកដ អល់ឡោះទ្រង់សព្វព្រះទ័យចំពោះពួកអ្នកដែលសារភាពកំហុស និងសព្វព្រះទ័យចំពោះពួកអ្នកដែលស្អាតស្អំ»។

- ជាសាសនាដែលជំរុញឱ្យសាសនិករបស់ខ្លួនបង្ហាញនូវសោភ័ណភាព ដូចអ្នកនាំសារមូហាំម៉ាត់បានមានប្រសាសន៍ថា៖

يقول صلى الله عليه وسلم :" إِنَّ اللهَ جَمِيْلٌ يُحِبُّ الْجَمَالَ ... صحيح مسلم ج1 ص93 رقم الحديث 91

មានន័យថា៖ «ពិតប្រាកដ អល់ឡោះទ្រង់ជាព្រះដ៏មហាសោភ័ណ ទ្រង់សព្វព្រះទ័យនឹងសោភ័ណភាព»។

- ជាសាសនាយុត្តិធម៌ កុសលធម៌ អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿إِنَّ ٱللَّهَ يَأۡمُرُ بِٱلۡعَدۡلِ وَٱلۡإِحۡسَٰنِ وَإِيتَآيِٕ ذِي ٱلۡقُرۡبَىٰ وَيَنۡهَىٰ عَنِ ٱلۡفَحۡشَآءِ وَٱلۡمُنكَرِ وَٱلۡبَغۡيِۚ يَعِظُكُمۡ لَعَلَّكُمۡ تَذَكَّرُونَ ٩٠﴾

النحل: ٩٠

មានន័យថា៖ «ពិតប្រាកដ អល់ឡោះបង្គាប់ឱ្យប្រកាន់នូវភាពយុត្តិធម៌ និងកុសលធម៌ រាប់អានបងប្អូនសាច់ញាតិ ហើយទ្រង់ហាមឃាត់ពីអំពើអបាយមុខ អំពើអាក្រក់ និងអំពើជិះជាន់រំលោភបំពាន ទ្រង់ទូន្មានដាស់តឿនដល់ពួកអ្នក សង្ឃឹមថាពួកអ្នកភ្ញាក់រលឹក»។

- ជាសាសនាអត់ឱន និងងាយស្រួល អ្នកនាំសារឥស្លាម បានមានប្រសាសន៍ថា៖

﴿يُرِيدُ ٱللَّهُ بِكُمُ ٱلۡيُسۡرَ وَلَا يُرِيدُ بِكُمُ ٱلۡعُسۡرَ﴾ البقرة: ١٨٥

មានន័យថា៖ "អល់ឡោះជាម្ចាស់ទ្រង់សព្វព្រះទ័យឱ្យពួកអ្នកនូវភាពងាយស្រួល ទ្រង់មិនសព្វព្រះទ័យឱ្យពួកអ្នកពិបាកនោះឡើយ»។

- ជាសាសនានៃក្តីមេត្តា និងអាណិតស្រលាញ់ អ្នកនាំសារឥស្លាម បានមានប្រសាសន៍ថា៖

قال رسول الإسلام : (اَلرَّاحِمُوْنَ يَرْحَمُهُمُ الرَّحْمَنُ اِرْحَمُوْا مَنْ فِي الْأَرْضِ يَرْحَمُكُمْ مَنْ فِي السَّمَاءِ ) سنن الترمذي ج 4 ص 323 رقم الحديث 1924

មានន័យថា៖ "ពួកអ្នកដែលមានក្តីមេត្តា ព្រះជាម្ចាស់នឹងមេត្តាចំពោះពួកគេ ចូរមេត្តាចំពោះអ្នកនៅលើដី នោះអ្នកនៅលើមេឃនឹងមេត្តាចំពោះពួកអ្នក»។

- ជាសាសនាប្រណីមេត្តា និងយោគយល់ អ្នកនាំសារបានមាន

ប្រសាសន៍ថា៖

يقول صلى الله عليه وسلم: ( إِنَّ الرِّفْقَ لَا يَكُوْنُ فِيْ شَيْءٍ إِلاَّ زَانَهُ وَلاَ يُنْزَعُ مِنْ شَيْءٍ إِلاَّ شَانَهُ) صحيح مسلم ج4 ص2004 رقم الحديث 2594

មានន័យថា៖ «ពិតប្រាកដ ភាពប្រណីមេត្តាតែងតែមានសោភ័ណភាពចំពោះអ្វីគ្រប់យ៉ាង ហើយអ្វីទាំងឡាយដែលខ្វះភាពប្រណីមេត្តានោះនឹងត្រូវបាត់បង់សោភ័ណភាព»។

- ជាសាសនាមានសីលធម៌ឧត្តុង្គឧត្តម អ្នកនាំសាររបស់អល់ឡោះបានមានប្រសាសន៍ថា៖

يقول صلى الله عليه وسلم : (بُعِثْتُ لِأُتَمِّمَ صَالِحَ الْأَخْلَاقِ) المستدرك على الصحيحين ج 2 ص 670 رقم الحديث 4221

មានន័យថា៖ «គេបញ្ជូនរូបខ្ញុំមកដើម្បីបំពេញនូវសីលធម៌ដ៏ប្រពៃ»។

- ជាសាសនាសប្បុរស និងចិត្តទូលំទូលាយ អ្នកនាំសារបានមានប្រសាសន៍ថា៖

يقول صلى الله عليه وسلم : ( السَّخِيُّ قَرِيبٌ مِنْ اللَّهِ قَرِيبٌ مِنْ الْجَنَّةِ قَرِيبٌ مِنْ النَّاسِ بَعِيدٌ مِنْ النَّارِ وَالْبَخِيلُ بَعِيدٌ مِنْ اللَّهِ بَعِيدٌ مِنْ الْجَنَّةِ بَعِيدٌ مِنْ النَّاسِ قَرِيبٌ مِنْ النَّارِ وَلَجَاهِلٌ سَخِيٌّ أَحَبُّ إِلَى اللَّهِ عَزَّ وَجَلَّ مِنْ عَالِمٍ بَخِيلٍ ) سنن الترمذي ج4 ص342 رقم الحديث 1961

មានន័យថា៖ «មនុស្សដែលមានចិត្តសប្បុរសនៅជិតអល់ឡោះ នៅជិតឋានសួគ៌ នៅក្បែរមនុស្ស ឆ្ងាយពីឋាននរក។ រីឯមនុស្សចិត្តកំណាញ់វិញ ឆ្ងាយពីអល់ឡោះ ឆ្ងាយពីឋានសួគ៌ ឆ្ងាយពីមនុស្ស នៅ

ជិតឋាននរក។ អ្នកចិត្តល្អជាមនុស្សល្ងង់ជាទីស្រលាញ់ចំពោះអល់ឡោះជាងមនុស្សចេះដឹងតែចិត្តរិះកំណាញ់»។

- ជាសាសនាស្រលាញ់នូវសេចក្តីល្អសម្រាប់មនុស្សលោកទូទៅ អ្នកនាំសារបានមានប្រសាសន៍ថា៖

يقول رسول الله صلى الله عليه وسلم الإسلام : ( أَحَبُّ النَّاسِ إِلَى اللهِ أَنْفَعُهُمْ لِلنَّاسِ ) المعجم الصغير ج 2 ص 106 رقم الحديث 861

មានន័យថា៖ «មនុស្សដែលជាទីស្រលាញ់ចំពោះអល់ឡោះគឺអ្នកដែលមានប្រយោជន៍ជាងគេសម្រាប់មនុស្ស»។

- ជាសាសនាមានសមធម៌ពេញលេញចំពោះសង្គមមនុស្សទាំងមូល មនុស្សម្នាក់ៗប្រសើរជាងគ្នាដោយសេចក្តីគោរពកោតខ្លាចចំពោះអល់ឡោះជាម្ចាស់។ អ្នកនាំសារបានមានប្រសាសន៍ថា៖

يقول رسول الإسلام : (النَّاسُ سَوَاسِيَّةٌ كَأَسْنَانِ الْمُشْطِ ، لاَ فَضْلَ لِعَرَبِيٍّ عَلَى أَعْجَمِيٍّ إِلَّا بِالتَّقْوَى )

មានន័យថា៖ «មនុស្សទាំងឡាយមានភាពស្មើគ្នាដូចធ្មេញក្រាសសិតសក់ ជនជាតិអារ៉ាប់មិនប្រសើរជាងជនជាតិដទៃ លើកលែងតែដោយសេចក្តីគោរពកោតខ្លាច»។

- ជាសាសនាយុត្តិធម៌ដាច់ខាតរួមទាំងចំពោះសត្រូវផងដែរ។ អល់ឡោះជាម្ចាស់បានមានព្រះបន្ទូលថា៖

﴿وَلَا يَجۡرِمَنَّكُمۡ شَنَـَٔانُ قَوۡمٍ عَلَىٰٓ أَلَّا تَعۡدِلُواْۚ ٱعۡدِلُواْ هُوَ أَقۡرَبُ لِلتَّقۡوَىٰ﴾ المائدة: ٨

មានន័យថា៖ «ចូរកុំព្រោះតែកំហឹងរបស់ មនុស្សមួយក្រុមធ្វើឱ្យពួកអ្នកប្រព្រឹត្តអយុត្តិធម៌ ចូរប្រកាន់នូវភាពយុត្តិធម៌ឱ្យស្មើគ្នា ទោះចំពោះសត្រូវឬមិត្ត ព្រោះវាខិតជិតទៅរកភាពកោតខ្លាចចំពោះអល់ឡោះ»។

- ជាសាសនាដែលមានសេរីភាពខាងជំនឿ។ អល់ឡោះជាម្ចាស់បន្ទូលថា៖

﴿ لَآ إِكۡرَاهَ فِي ٱلدِّينِ ﴾ البقرة: ٢٥٦

មានន័យថា៖ «គ្មានការបង្ខិតបង្ខំក្នុងសាសនាឥស្លាម»។

- ជាសាសនាមានសាមគ្គីភាពលើអំពើល្អ។ អល់ឡោះជាម្ចាស់បានមានព្រះបន្ទូលថា៖

﴿وَتَعَاوَنُواْ عَلَى ٱلۡبِرِّ وَٱلتَّقۡوَىٰۖ وَلَا تَعَاوَنُواْ عَلَى ٱلۡإِثۡمِ وَٱلۡعُدۡوَٰنِ﴾ المائدة: ٢

មានន័យថា៖ «ចូរសាមគ្គីគ្នាលើសេចក្តីកតញ្ញូ និងសេចក្តីកោតខ្លាចហើយចូរកុំសាមគ្គីគ្នាលើអំពើបាប និងការចងសត្រូវឱ្យសោះ»។

- ជាសាសនាសម្រាប់មនុស្សទូទៅ សំដៅទៅកាន់ពិភពលោកទាំងមូល ពុំចំពោះតែជាតិសាសន៍ណាមួយឡើយ។ អល់ឡោះជាម្ចាស់បានមានព្រះបន្ទូលថា៖

﴿ وَمَآ أَرۡسَلۡنَٰكَ إِلَّا كَآفَّةً لِّلنَّاسِ بَشِيرًا وَنَذِيرًا وَلَٰكِنَّ أَكۡثَرَ ٱلنَّاسِ لَا يَعۡلَمُونَ ٢٨ ﴾ سبأ: ٢٨

មានន័យថា៖ «យើងពុំបានបញ្ជូនអ្នកមក លើកលែងតែសម្រាប់មនុស្សទូទៅ ជាអ្នកនាំដំណឹងល្អ និងជាស់តឿន។ ក៏ប៉ុន្តែមនុស្សភាគច្រើនមិនដឹងពីការពិត»។

- ជាសាសនាលុបលាងនូវអំពើបាប និងកំហុសឆ្គងទាំងឡាយ។ អល់ឡោះជាម្ចាស់បានមានព្រះបន្ទូលថា៖

﴿قُلۡ يَٰعِبَادِيَ ٱلَّذِينَ أَسۡرَفُواْ عَلَىٰٓ أَنفُسِهِمۡ لَا تَقۡنَطُواْ مِن رَّحۡمَةِ ٱللَّهِۚ إِنَّ ٱللَّهَ يَغۡفِرُ ٱلذُّنُوبَ جَمِيعًاۚ إِنَّهُۥ هُوَ ٱلۡغَفُورُ ٱلرَّحِيمُ ٥٣﴾ الزمر: ٥٣

មានន័យថា៖ «មូហាំម៉ាត់ចូរប្រាប់ពួកខ្ញុំមប្រើរបស់យើងដែលជ្រុលខ្លួនប្រព្រឹត្តអំពើបាបថា ចូរពួកអ្នកកុំទាន់អស់សង្ឃឹមចំពោះក្តីមេត្តារបស់អល់ឡោះ។ ពិតប្រាកដ អល់ឡោះទ្រង់លើកលែងនូវរាល់អំពើបាបទាំងឡាយ។ ពិតប្រាកដ ទ្រង់មហាអភ័យ មហាមេត្តា»។

បងប្អូនប្រិយមិត្តអ្នកអានទាំងឡាយជាទីស្រលាញ់ តើអ្នកមិនយល់ព្រមជាមួយខ្ញុំទេថា នេះជាគោលការណ៍សាសនា និងអ្វីដែលសាសនានេះអំពាវនាវ។ គួរណាស់យើងប្រតិបត្តិតាម និងត្រួសត្រាយផ្លូវដើម្បីផ្សព្វផ្សាយ ហើយយ៉ាងហោចណាស់ក៏យើងមិនត្រូវចងកំហឹងនិងមិនត្រូវរារាំងមនុស្សចំពោះការកាន់តាមសាសនានេះដែរ។

## ហេតុអ្វីបានជាអ្នកចាំបាច់ត្រូវក្លាយជាមូស្លីម យកចិត្តទុកដាក់នឹងឥស្លាម

1. ពីព្រោះឥស្លាមជាសាសនាចុងក្រោយបង្អស់ដែលគេបញ្ចុះមកពីលើមេឃ។
2. ពីព្រោះឥស្លាមមានជំនឿចំពោះសារទាំងឡាយដែលមកពីលើមេឃនៅសម័យមុន ហើយគេចាត់ទុកឥស្លាមជាសាសនាបន្ត

ពីសារមុនៗ។ ដូចជាពួកជ្វីហ្វមិនទទួលស្គាល់យេស៊ូ ហើយពួកគ្រិស្តសាសនិកមិនទទួលស្គាល់ព្យាការីមូហាំម៉ាត់។ ក៏ប៉ុន្តែពួកអ្នកមូស្លីមទទួលស្គាល់ព្យាការីមូសា និងអ៊ីសា។

3. ពីព្រោះឥស្លាមធ្វើឱ្យមនុស្សមានចំណងទាក់ទងជាមួយនឹងព្រះជាម្ចាស់របស់គេចំពោះគ្រប់កិច្ចការ និងស្ថានភាពទាំងអស់។
4. ពីព្រោះសាសនាឥស្លាមពុំមានការកែប្រែ ឬផ្លាស់ប្តូរ។ ខុសពីសាសនាដទៃដែលត្រូវគេកែប្រែ និងផ្លាស់ប្តូរ។ លោកម៉ៃឃើលហាត បាននិយាយក្នុងសៀវភៅវីរជនទាំង១០០នាក់របស់លោកថា ពុំមានក្នុងប្រវត្តិសាស្ត្រសារគម្ពីរសាសនាដែលរក្សាសំណេររបស់វាពេញលេញដោយគ្មានការកែប្រែ លើកលែងតែគម្ពីរអាល់គួរអាន ដែលនាំមកដោយមូហាំម៉ាត់។
5. ពីព្រោះឥស្លាមជាសាសនាពេញលេញដែលគ្របដណ្តប់លើវិស័យសាសនា និងលោកីយ៍ជាមួយគ្នា។ មិនធ្វេសប្រហែសចំពោះអ្វីមួយតូចតាចក្នុងជីវិតអ្នកមូស្លីម។

يقول عبد الرحمن بن زيد رضي الله عنه قِيلَ لَسلمان : ( قَدْ عَلَّمَكُمْ نَبِيُّكُمْ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ كُلَّ شَيْءٍ حَتَّى الْخِرَاءَةَ قَالَ فَقَالَ أَجَلْ لَقَدْ نَهَانَا أَنْ نَسْتَقْبِلَ الْقِبْلَةَ لِغَائِطٍ أَوْ بَوْلٍ أَوْ أَنْ نَسْتَنْجِيَ بِالْيَمِينِ أَوْ أَنْ نَسْتَنْجِيَ بِأَقَلَّ مِنْ ثَلَاثَةِ أَحْجَارٍ أَوْ أَنْ نَسْتَنْجِيَ بِرَجِيعٍ أَوْ بِعَظْمٍ ) صحيح مسلم ج 1 ص 223 رقم الحديث 262

មានន័យថា៖ “អាប់ឌុរ៉ោះម៉ាន ពិន ហ្សេត បាននិយាយទៅកាន់សាល់ម៉ានថា៖ ពិតប្រាកដ ព្យាការីរបស់ពួកអ្នកបានបង្រៀនអ្នកនូវអ្វីគ្រប់យ៉ាង សូម្បីតែរឿងបញ្ចាបត់ជើងក៏គាត់មិនចោលដែរ។ សាល់ម៉ានបាន

តបវិញថា ពិតមែនហើយ។ គាត់ឃាត់យើងពីការបែរមុខទៅកិបឡ័តនៅពេលបត់ជើងតូច ឬបត់ជើងធំ ឬហាមមិនឱ្យជូតសម្អាតការបត់ជើងរបស់យើងនឹងដៃស្តាំឬជូតសម្អាតតិចជាងបីដុំថ្ម ឬជូតសម្អាតដោយដុំលាមកស្ងួត ឬឆ្អឹង»។ ទស្សនវិទូ អាជី ហាមិលតុន បាននិយាយថា៖ បើសិនជាមនុស្សស្វែងរកការពិតនោះ គេនឹងដឹងថាសាសនាឥស្លាមជាដំណោះស្រាយតែមួយគត់សម្រាប់បញ្ហាទាំងឡាយរបស់មនុស្សជាតិ។

6. ពីព្រោះឥស្លាមជាសាសនាដែលជួយបំពេញនូវតម្រូវការរបស់មនុស្សទាំងផ្នែកផ្លូវចិត្ត និងផ្លូវកាយឱ្យមានតុល្យភាពដ៏អស្ចារ្យបដិសេធចំពោះភាពលំអៀងទៅម្ខាងណាមួយ។ ឥស្លាមអាចរៀបចំជីវិតមនុស្សឱ្យមានតុល្យភាពដ៏អស្ចារ្យ។ ព្រះអង្គម្ចាស់ឆាលិសបាននិយាយថា៖ ពិតប្រាកដ ឥស្លាមអាចបង្រៀនយើងពីរបៀបរស់នៅ និងមានសុខដុមនីយកម្មនឹងគ្នាក្នុងពិភពលោកដែលគ្រិស្តសាសនាបានបាត់បង់។ ឥស្លាមបដិសេធចំពោះការបែងចែករវាងមនុស្សនិងធម្មជាតិ សាសនានិងចំណេះដឹង បញ្ញានិងរូបធាតុ។
7. ពីព្រោះឥស្លាមជាសាសនាដែលមិនផ្ទុយនឹងបញ្ញានិងឧបនិស្ស័យដែលត្រឹមត្រូវ។ លោកតូលស្តូយបាននិយាយថា៖ ច្បាប់ស្សារីអាត់ឥស្លាមនឹងដឹកនាំពិភពលោក ដោយសារច្បាប់នេះស្របជាមួយនឹងបញ្ញានិងគតិបណ្ឌិត។
8. ពីព្រោះឥស្លាមគេបញ្ជូនមកកាន់មនុស្សទាំងមូលសម្រាប់គ្រប់ស្រទាប់ទាំងអស់ នៅគ្រប់ជំនាន់ និងគ្រប់សម័យកាល ផ្ទុយពី

សាសនាមុនៗដែលគេបញ្ជូនមកសម្រាប់តែប្រជាជាតិ និងសម័យកាលមួយមានកំណត់ដូចជា សាសនាជិហ្វ មិនក្លាយជាជិហ្វលើកលែងតែមានដើមកំណើតជាសាសន៍ជិហ្វ។ ចំពោះគ្រិស្តសាសនាវិញព្យាការីអ៊ីសាលោកបានមានប្រសាសន៍ថា៖ «គេមិនបញ្ជូនខ្ញុំមក លើកលែងតែសម្រាប់មនុស្សមួយក្រុមដែលវង្វេងនៃពួកកូនចៅអ៊ីស្រាអែលតែប៉ុណ្ណោះ»។

អំណះអំណាងដែលបញ្ជាក់ពីសកលភាវូបនីយកម្មនៃសាសនាឥស្លាម គឺឥស្លាមជាសាសនាសម្រាប់មនុស្សទូទៅដោយមិនគិតពីជាតិសាសន៍ ភាសា សម័យកាល រហូតដល់ថ្ងៃបរលោក។ ពិតប្រាកដ អ្នកនាំសារមូហាំម៉ាត់នៅពេលដែលព្រះបន្ទូលចុះពីលើមេឃមកចំពោះគាត់ដំបូងបង្អស់គឺៈ

﴿يَٰٓأَيُّهَا ٱلۡمُدَّثِّرُ ١ قُمۡ فَأَنذِرۡ ٢ وَرَبَّكَ فَكَبِّرۡ ٣ وَثِيَابَكَ فَطَهِّرۡ ٤﴾
المدثر: ١-٤

មានន័យថា៖ «ឱអ្នកដែលកំពុងដេកដណ្ដប់ភួយ។ ចូរក្រោកឡើង រួចទៅដាស់តឿនមនុស្សឱ្យប្រុងប្រយ័ត្នពីទារុណកម្មរបស់អល់ឡោះ។

ចូរតម្កើងចំពោះព្រះជាម្ចាស់របស់អ្នកដោយការគោរពសក្ការៈចំពោះទ្រង់»។

ស៊ូរ៉ោះនេះជាដំណាក់កាលផ្លាស់ប្តូរពីការអំពាវនាវដោយលាក់បាំងទៅបើកចំហ។ គាត់បានចាប់អនុវត្តការអំពាវនាវសាសន៍របស់គាត់ឱ្យមកកាន់សាសនារបស់អល់ឡោះ ហើយបញ្ជាក់ពីភាពមោឃៈនៃអ្វីដែលពួកគេកំពុងកាន់ដូចជាការគោរពរូបជិមា។ គាត់បានអំពាវនាវឱ្យពួកគេគោរពសក្ការៈចំពោះអល់ឡោះតែមួយគាត់ ហើយបោះបង់

ព្រះផ្សេងៗក្រៅពីទ្រង់ដែលពួកគេនៅគោរពបូជា។ គាត់ត្រូវបានទទួលរងការប្រមាថ គំរាមកំហែងពីពួកគេ។ បន្ទាប់មក គាត់បានផ្ញើសារលិខិតជូនដល់អាណាចក្រទាំងឡាយដែលនៅជុំវិញ បញ្ជូនសារដើម្បីអំពាវនាវពួកគេឱ្យចូលសាសនាឥស្លាម។ ក្នុងចំណោមស្តេចអាណាចក្រដ៏ធំបំផុតដែលគាត់បានផ្ញើសារលិខិតទៅកាន់នាសម័យកាលនោះមានដូជា អាណាចក្ររ៉ូម ពែក ហាបាស្សះ។ បើសិនជាការអំពាវនាវរបស់គាត់ពុំមានលក្ខណៈជាសកលទេនោះ ម្ល៉េះគាត់មិនអនុវត្តនូវកិច្ចការទាំងនេះឡើយ។ ពីព្រោះគាត់ដឹងច្បាស់ថាការងារនេះនឹងធ្វើឱ្យកើតមានចលនាតស៊ូប្រឆាំង និងការប្រឈមពីខាងក្រៅជាមួយនឹងអាណាចក្រទាំងនោះដែលមានកងទ័ព និងសព្វាវុធខ្លាំងជាងគាត់។ ម្យ៉ាងវិញទៀតស្ថានភាពខាងក្នុងក៏ពុំទាន់មានស្ថេរភាពនៅឡើយដែរ។ ចុះហេតុអ្វីបានជាគាត់ហ៊ានប្រឈមនឹងគ្រោះថ្នាក់ ហើយធ្វើកិច្ចការទាំងនោះ? ក៏ប៉ុន្តែ សារនិងការតែងតាំងព្យាការី ជាកត្តាចាំបាច់ត្រូវផ្សព្វផ្សាយឥស្លាមទៅកាន់មនុស្សលោកទាំងមូល។

ចូរស្តាប់ប្រសាសន៍របស់គាត់យ៉ាងមុតមាំ និងមានទំនុកចិត្តថា៖

قال رسول الله صلى الله عليه وسلم : ( لَيَبْلُغَنَّ هَذَا الأَمْرُ مَا بَلَغَ اللَّيْلُ وَالنَّهَارُ وَلَا يَتْرُكُ اللَّهُ بَيْتَ مَدَرٍ وَلَا وَبَرٍ إِلَّا أَدْخَلَهُ اللَّهُ هَذَا الدِّينَ بِعِزِّ عَزِيزٍ أَوْ بِذُلِّ ذَلِيلٍ عِزًّا يُعِزُّ اللَّهُ بِهِ الْإِسْلَامَ وَذُلًّا يُذِلُّ اللَّهُ بِهِ الْكُفْرَ ) مسند الإمام أحمد ج 4 ص 103 رقم الحديث 16998

មានន័យថា៖ «កិច្ចការនេះ (ការអំពាវនាវឥស្លាម)នឹងទៅដល់ទីណាដែលមានយប់និងថ្ងៃ អស់ឡោះមិនទុកចោលផ្ទះនៅទីក្រុង និងនៅតាមទីជនបទ លើកលែងតែទ្រង់ឱ្យសាសនានេះចូលទៅដល់ជាឥស្សរ

ភាពរបស់ឥស្សរជន ឬជាភាពអប្បយសរបស់ជនថោកទាប។ ជាឥស្សរភាពដែលអស់ឡោះតម្កើងដោយឥស្លាម ហើយជាភាពអប្បយសដែលអល់ឡោះទ្រង់ធ្វើឱ្យអាប់ឱនដោយភាពគ្មានជំនឿ»។

**សេចក្តីបញ្ចប់**

បងប្អូនអ្នកអានជាទីមេត្រី ពិតប្រាកដ ច្បាប់ស្សារីអាត់ឥស្លាមជាសារដែលបញ្ចុះពីលើមេឃមកដោយពេញលេញ ជាធម្មនុញ្ញសម្រាប់ជីវិតដ៏មានសុភបង្គលទាំងក្នុងលោកីយ៍ និងជីវិតអមតៈនៅថ្ងៃបរលោក។ បើទោះជាអ្នកបានឃើញអ្នកមូស្លីមខ្លះមានចរិតប្រាសចាកខុសឆ្គង ខ្វះសីលធម៌ ចូរជ្រាបចុះថា ឥស្លាមស្អាតស្អំពីចរិតខុសឆ្គងទាំងនោះ។ មូលហេតុមកពីភាពអវិជ្ជាមិនយល់ពីការកិច្ចសាសនា ឬមានជំនឿខ្សោយ ដែលនាំឱ្យពួកគេធ្វើបែបនេះ។ គេពុំត្រូវវិនិច្ឆ័យទៅលើឥស្លាមតាមរយៈការវិនិច្ឆ័យទៅលើសាសនិកឥស្លាមមួយចំនួន។ ការបោះពុម្ពផ្សាយដ៏តូចស្តួចស្តើងនេះ ជាគន្លឹះនៃការចាប់ផ្តើមសិក្សាស្រាវជ្រាវអំពីជាតុពិតដែលត្រូវប្រកាន់យក៖

- ជម្រះសម្អាតឱ្យអស់នូវទំនើចិត្តបុគ្គលនិយម និងសាសនានិយម។
- មានបំណងពិតប្រាកដដើម្បីរកឱ្យឃើញ និងយល់ដឹងពីការពិតពុំមែនតាមប្រមាញ់ចាប់កំហុស និងតាមដាមរកចំណុចអវិជ្ជមាននោះឡើយ។
- មានឯករាជ្យភាពក្នុងការគិត កុំឱ្យការវិនិច្ឆ័យរបស់អ្នកលើអ្វីមួយគ្រាប់តាមការវិនិច្ឆ័យរបស់អ្នកដទៃ។